

# រស់នៅក្នុងភពអន្ធការ



## ការវាយប្រហារដោយអាស៊ីតនៅប្រទេសកម្ពុជា

រៀបរៀងរបាយការណ៍ដោយអង្គការ លីកាដូ ឆ្នាំ២០០៣

- **រូបថតនៅក្របខាងក្រៅ**

***ដោយ តាំង ឈិនសុភី***

ស្ត្រីកម្ពុជាវ័យក្មេងម្នាក់ ដែលជាជនរស់រានមានជីវិតពីការវាយប្រហារដោយទឹកអាស៊ីតគ្របកន្សែងទទូរក្បាលនៅពេលនាងធ្វើដំណើរចាកចេញមកក្រៅផ្ទះ ដើម្បីបិទបាំងសំលាកស្នាមដ៏អាក្រក់នៅផ្ទៃមុខនាង។ ស្ត្រីរងគ្រោះដោយអាស៊ីតម្នាក់ទៀតកំពុងស្នាក់នៅជាមួយប្អូនស្រី ដែលជាអ្នករាំរបាំអប្សរា។ ស្ត្រីទាំងពីរជាអ្នករស់រានមានជីវិតពីការវាយប្រហារដោយទឹកអាស៊ីតបានធ្វើឱ្យភ្នែកទាំងពីររបស់ពួកគេពិការជារៀងរហូត។

---

**របាយការណ៍នេះបោះពុម្ពដោយ ការិយាល័យកម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម**

**អង្គការ សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ**

អាសយដ្ឋានៈ ផ្ទះលេខ ១០៣ ផ្លូវ ៩៧ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា. ប្រអប់សំបុត្រផ្ញើលេខៈ ៤៩៩

លេខទូរស័ព្ទៈ(៨៥៥) ២៣ ៣៦០ ៩៦៥. ទូរសារៈ (៨៥៥) ២៣ ២១៧ ២៦២. អ៊ីមែលៈ licadho@camnet.com.kh

# មាតិការឿង

ទំព័រ


១. សេចក្ដីផ្ដើម: ១

- តើការវាយប្រហារដោយទឹកអាស៊ីតមានអត្ថន័យយ៉ាងណាដែរ? ១
- តើបញ្ហានេះមានប៉ុន្មានករណី ហេតុអ្វីបានជាវាកើតឡើងមកបាន? ២
- តើគេប្រើអាស៊ីតប្រភេទណាខ្លះ ? ៤

២. ករណីឧទាហរណ៍ : រឿងពិតនៃការវាយប្រហារដោយទឹកអាស៊ីត ៦

៣. ស្ថិតិនៃការវាយប្រហារទឹកអាស៊ីតដកស្រង់ចេញពីកាសែតនានា ១០

- តើមានការវាយប្រហារដោយទឹកអាស៊ីតប៉ុន្មានករណីមកហើយ ១០
- តើនរណាខ្លះជាជនរងគ្រោះដោយការវាយប្រហារទឹកអាស៊ីតនេះ ? ១១
- នរណាខ្លះជាជនល្មើសក្នុងការជះទឹកអាស៊ីត ហេតុអ្វីក៏គេធ្វើយ៉ាងនេះ? ១៣
- របួសស្លាកស្នាមដែលជនរងគ្រោះទទួលបានដោយការរលាកទឹកអាស៊ីត ១៧

៤. ផលប៉ះពាល់លើរាងកាយជនរងគ្រោះដោយការរលាកទឹកអាស៊ីត ១៨

- ស្នាមរបួស ១៨
- ការព្យាបាល ២១
- សេវាកម្មក្នុងមន្ទីរពេទ្យ ២៣

៥. ផលវិបាកផ្សេងៗទៀតរបស់ជនរងគ្រោះដោយការរលាកទឹកអាស៊ីត ២៦

- ផលវិបាកខាងផ្លូវចិត្ត ២៦
- ជនរងគ្រោះបានរងទុក្ខវេទនាជាច្រើនបែបយ៉ាង ២៦
- ផលវិបាកខាងសង្គម និងសេដ្ឋកិច្ច ២៧

៦. ខាងផ្លូវច្បាប់ ៣១

- តើត្រូវផ្ដន្ទាទោសជនដៃដល់ដូចម្ដេច? ៣១
- តើច្បាប់ត្រូវគេអនុវត្តន៍ដែរឬទេ? ៣១
- គំនិតផ្ដើមច្បាប់ដ៏មានសារៈសំខាន់ ៣៤

៧. បទពិសោធនៅប្រទេសបង់ក្លាដែស ៣៤

៨. អានុសាសន៍: ៣៦

## ១.សេចក្តីផ្តើម:

> *បូផល[1] នាងមានអាយុទើបតែ ២៤ឆ្នាំ ប៉ុណ្ណោះ ប៉ុន្តែមើលទៅនាងហាក់បីដូចជាមនុស្សដែលកំពុងទន្ទឹងរង់ចាំតែថ្ងៃស្លាប់មកដល់ ។ ថ្ងៃនិមួយៗដែលកន្លងផុតទៅជាថ្ងៃនៃការឈឺចាប់រងទុក្ខវេទនាខ្លោចផ្សា និងពោរពេញទៅដោយក្តីអាម៉ាស់សំរាប់រូបនាង ។ បីឆ្នាំមុននេះ នាងត្រូវបានគេយកទឹកអាស៊ីតពីរដបមកចាក់ពីលើក្បាល និងខ្លួនប្រាណរបស់នាង ។ បច្ចុប្បន្ននេះ ផ្ទៃមុខ ដៃ និងខ្នងរបស់នាងគ្របដណ្តប់ទៅដោយស្លាកស្នាមកំពឹកកំពកគគ្រាតគគ្រើមដ៏គួរអោយរន្ធត់ ហើយក្បាលមួយចំហៀងរបស់នាងទំពែកជ្រុះសក់អស់ ។ មួយថ្ងៃៗ នាងពួនសម្ងំយំលាក់ខ្លួនពីពិភពលោកខាងក្រៅ នាងមានការភ័យខ្លាចក្នុងការដើរចេញទៅខាងក្រៅ ។ នាងមិនទាន់ស្លាប់នៅឡើយទេ តែក៏គ្មានជីវិតពេញលេញដូចគេឯងដែរ ។ នាងតែងតែ និយាយប្រាប់អ្នកដែលទៅសួរសុខទុក្ខនាងថា* ***"ឥឡូវនេះ ខ្ញុំមានរូបរាងពាក់កណ្តាលជាខ្មោច ពាក់កណ្តាលជាមនុស្ស ។ អ្នកដែលធ្វើអំពើនេះមកលើខ្ញុំ ហេតុម្តេចក៏មិនសម្លាប់ខ្ញុំតែម្តងភ្លាមទៅ ឬបាញ់សម្លាប់ ឬចាក់សម្លាប់ខ្ញុំទៅ ? ហេតុអ្វីបានជាគេទុកអោយខ្ញុំរស់នៅក្នុងសភាពឈឺចាប់យ៉ាងនេះទៅវិញ?"*** ។

### ▪ តើការវាយប្រហារដោយទឹកអាស៊ីតមានអត្ថន័យយ៉ាងណាដែរ?

ការជះទឹកអាស៊ីតជាឧក្រិដ្ឋកម្មដ៏អាក្រក់មួយដែលមនុស្សបានប្រព្រឹត្តិឡើង។ ជនដៃដល់គ្មានចិត្តចង់សម្លាប់ជនរងគ្រោះទេ តែចង់ទុកអោយជនរងគ្រោះរស់នៅលំបាកជាងស្លាប់ទៅទៀត ពោលគឺធ្វើអោយជនរងគ្រោះរងទុក្ខវេទនាជារៀងរហូត ។ អាស៊ីតរំលាយសាច់ និងឆ្អឹងរបស់មនុស្ស បណ្តាលអោយមានការឈឺចាប់ និងការភ័យខ្លាចឥតគណនា ហើយដែលបន្សល់អោយជនរងគ្រោះនូវការខូចខាតរាងកាយរូបសម្ផស្សពីកំណើត និងបន្សល់ស្លាកស្នាមអស់មួយជីវិត ។ ជនរងគ្រោះខ្លះធ្លាក់ខ្លួនពិការជារៀងរហូត ដូចជាខ្វាក់ភ្នែក ។

ការជះទឹកអាស៊ីតច្រើនតែជាអំពើនៃការសងសឹក ដែលបណ្តាលមកពីការប្រច័ណ្ឌ ឬការស្អប់ខ្ពើមដែលកើតចេញមកអំពីបញ្ហាទំនាក់ទំនងបុគ្គល ដូចជាបញ្ហាស្នេហាត្រីកោណ ឬអាពាហ៍ពិពាហ៍បែកបាក់ ការផិតក្បត់ ការបោះបង់ចោលជាដើម ។ ក្នុងអំពើនៃការសងសឹកនេះ ជនដៃដល់បានជះកំហឹងទៅលើជនរងគ្រោះ ថាជាអ្នកដែលបង្កើតអោយមានបញ្ហាខាងលើនេះឡើង ហេតុនេះជនដៃដល់ចង់បង្កអោយមានសេចក្តីឈឺចាប់វេទនាបំផុតទាំងផ្លូវកាយ និងផ្លូវចិត្តដល់ជនរងគ្រោះ ។ ដើម្បីអោយសំរេចគោលបំណងនេះ ជនដៃ

[1] នេះមិនមែនជាឈ្មោះពិតរបស់នាងឡើយ តែគឺជាឈ្មោះដែលប្រើប្រាស់សំរាប់លាក់អត្តសញ្ញាណពិតរបស់នាង ។

ដល់ តែងតែជះទឹកអាស៊ីតលើផ្ទៃមុខរបស់ជនរងគ្រោះ ពោលគឺគេចង់បំផ្លាញសម្ផស្សពីកំណើតនឹងធ្វើអោយជនរងគ្រោះមានរូបរាងដូចសត្វចម្លែកម៉្យាងដែលគ្មានអ្នកណាគេមកស្រឡាញ់ជនរងគ្រោះជារៀងរហូត ។

មូលហេតុផ្សេងៗទៀតនៃការវាយប្រហារដោយទឹកអាស៊ីត (ក្នុងករណីខ្លះ) រួមមានអំពើឆក់ប្លន់ ឬជម្លោះរវាងអ្នកជិតខាង ។

អ្នកជះទឹកអាស៊ីតបញ្ចេញសកម្មភាពដោយចេតនានឹងយ៉ាងឃោរឃៅ ។ ការវាយប្រហារដោយទឹកអាស៊ីតមិនមែនជាអំពើដែលធ្វើឡើងដោយសារការខឹងមួយឆាបនោះទេតែជនដៃដល់ត្រូវរៀបចំផែនការវាយប្រហារមួយដូចជាការរកត្រៀមទឹកអាស៊ីត ការយកអាស៊ីតជាប់តាមខ្លួនដោយសុវត្ថិភាពនឹងរង់ចាំឱកាសជះទឹកអាស៊ីតដាក់លើជនរងគ្រោះ ។

សំរាប់ជនរងគ្រោះវិញ ការជះទឹកអាស៊ីតគឺជាប្រភេទនៃអំពើទារុណកម្មមួយដែលទទួលការឈឺចាប់គ្មានទីបញ្ចប់ (មិនអាចបញ្ចប់ដោយងាយឡើយ) ហើយជាការខូចខាតរូបរាងកាយនឹងបន្សល់របួសស្លាកស្នាមអស់មួយជីវិត ព្រមជាមួយគ្នានេះដែរ ជនរងគ្រោះទទួលរងទុក្ខវេទនា ឈឺចាប់បណ្តាលមកពីបញ្ហាផ្សេងៗទៀតគ្មានថ្ងៃស្រាកស្រាន្តសោះឡើយ ។ ពួកជនរងគ្រោះទាំងនេះរស់នៅក្នុងសភាពសោកសៅ មានអារម្មណ៍ថាខ្លួនបាត់តម្លៃអស់ជាមនុស្ស មានទុក្ខកង្វល់ និងភាពអាម៉ាស់ជាប់ខ្លួនជាប្រចាំ ។ ពួកគេអាចក្លាយទៅជាជនឯកោ សម្ងំលាក់ខ្លួនដោយសារការភ័យខ្លាច ការសំឡក់សំឡឹង ការសើចចំអក ឬការពេបជ្រាយផ្សេងៗបណ្តាលមកពីមូលហេតុនៃការវាយប្រហារដោយទឹកអាស៊ីត ។ ជនរងគ្រោះអាចនឹងមិនបានរៀបអាពាហ៍ពិពាហ៍ ឬមិនអាចមានកូនចៅតពូជពង្សវង្សត្រកូល ហើយសូម្បីតែបំពេញការងារងាយៗ ដូចជាទៅផ្សារទិញអីវ៉ាន់អាចជារឿងអាម៉ាស់ ឬជារឿងគួរអោយភ័យខ្លាចសំរាប់ពួកគេ ។ ពួកគេអាចនឹងបាត់បង់លទ្ធភាពធ្វើការ ឬត្រូវបានគេបដិសេធមិនផ្តល់ការងារធ្វើ- ដូច្នេះពួកគេនឹងរស់នៅក្នុងសភាពទុរគតជននៃការតស៊ូដើម្បីបានរស់ ។

គ្មានអ្នកណាម្នាក់សមនឹងទទួលរងការវាយប្រហារដោយទឹកអាស៊ីតនោះទេ ។ ជនរងគ្រោះមិនត្រូវទទួលការពេបជ្រាយ ឬស្តីបន្ទោសនោះទេ ។ ពួកគេត្រូវការការព្យាបាលវេជ្ជសាស្ត្រ និងជំនួយដើម្បីកសាងជីវិតរបស់ពួកគេឡើងវិញ ហើយនឹងគួរតែអាចប្រកបការងារ រៀនសូត្រ និងទទួលបាននូវឱកាសផ្សេងៗ ដូចជាមនុស្សផងទាំងពួងដែរ ។ ឯជនដៃដល់វិញ ត្រូវតែចាប់មកផ្តន្ទាទោសតាមច្បាប់ ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងដើម្បីជាសក្ខីភាពនៃការជួយរំលែកទុក្ខវេទនា និងការឈឺចាប់របស់ជនរងគ្រោះ ។

## ▪ តើបញ្ហានេះមានប៉ុន្មានករណី ហេតុអ្វីបានជាវាកើតឡើងមកបាន?

យ៉ាងហោចណាស់ ក៏មាន ៤៤ ករណីនៃការវាយប្រហារដោយទឹកអាស៊ីតក្នុងប្រទេសកម្ពុជាត្រូវបានគេរាយការណ៍ក្នុងរយៈពេលបីឆ្នាំមុន ដោយគិតមកទល់នឹងខែវិច្ឆិកា ឆ្នាំ ២០០២កន្លងទៅ ដែលក្នុងនោះមានមនុស្ស ៦០នាក់បានរងរបួស និង៣នាក់បានស្លាប់ ។ នេះមានន័យថា ជាមធ្យមមានការវាយប្រហារដោយទឹកអាស៊ីតមួយករណីរៀងរាល់ ២៥ថ្ងៃ។ អង្គការលីកាដូ បានចងក្រងស្ថិតិនេះចេញពីសេចក្តីរាយការណ៍

តាមកាសែតតែប៉ុណ្ណោះ ឯតួលេខពិតប្រាកដនោះអាចខ្ពស់ជាងនេះទៅទៀត ព្រោះថាកាសែតក៏មិនអាចរាយការណ៍ ឬចុះផ្សាយរាល់ករណីនៃការវាយប្រហារដោយទឹកអាស៊ីតនោះទាំងអស់ទេ ។ ប្រមាណជាមួយភាគបីនៃជនរងគ្រោះដោយការវាយប្រហារទឹកអាស៊ីត គឺរងគ្រោះដោយចៃដន្យ ។ នេះគឺដោយសារទឹកអាស៊ីតជាអាវុធមួយបាចសាច ដែលអាចធ្វើអោយរងគ្រោះក្នុងអំឡុងពេលនៃការវាយប្រហារនោះ អ្នកដែលឈរក្បែរៗទីនោះទទួលរងគ្រោះដោយអចេតនា ។ ឧទាហរណ៍កុមារពីរនាក់បានទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរក្នុងឧប្បត្តិហេតុជះទឹកអាស៊ីតមួយដែលបណ្តាលអោយម្តាយរបស់កុមារទាំងពីរនាក់នោះស្លាប់ ។ ក្នុងករណីមួយទៀត ស្ត្រីម្នាក់បានជះទឹកអាស៊ីតលើប្តីរបស់នាង តែទឹកអាស៊ីតនោះបានជះត្រូវកូនអាយុប្រាំឆ្នាំរបស់នាងផងដែរ ។

គោលដៅភាគច្រើននៃការវាយប្រហារទឹកអាស៊ីតគឺស្ត្រី តែបុរសក៏ជាគោលដៅនៃការវាយលុកដោយចេតនាផងដែរ ។ ជនប្រព្រឹត្តបទល្មើសជះទឹកអាស៊ីតមានទាំងបុរស និងមានទាំងស្ត្រីផងដែរ ។

ការវាយប្រហារភាគច្រើនបានធ្វើឡើងដោយសារមានបញ្ហា ឬជំលោះទាក់ទងនឹងគ្រួសារ ឬបុគ្គល ។ មូលហេតុទូទៅនៃការវាយប្រហារគឺ :

- ប្រពន្ធជះទឹកអាស៊ីតលើស្រីកំណាន់ ឬប្រពន្ធចុងរបស់ប្តីខ្លួន : ជាការសងសឹកនិងការបំផ្លាញរូបសម្ផស្សរបស់ជនរងគ្រោះ ដើម្បីអោយប្តីរបស់ខ្លួនលែងស្រឡាញ់ស្រីទាំងនោះតទៅទៀត ។
- ប្តីជះទឹកអាស៊ីតដាក់ប្រពន្ធរបស់ខ្លួន ឬអតីតប្រពន្ធរបស់ខ្លួន : ដើម្បីជាទណ្ឌកម្មដល់ពួកស្ត្រីទាំងនោះក្នុងបទដែលពួកគេត្រូវបានប្តីចោទប្រកាន់ថាបានធ្វើកំហុសឆ្គង ឬភាពមិនស្មោះត្រង់ ឬក៏ដោយសារការប្រច័ណ្ឌ ឬកំហឹងកើតចេញពីការចែកផ្លូវ ឬការលែងលះគ្នា ។

មូលហេតុនៃការជះទឹកអាស៊ីតមួយទៀតដែលមិនសូវទូទៅ តែក៏ជារូបភាពនៃការវាយប្រហារមួយដ៏សំខាន់ដែរនោះ គឺប្រពន្ធជះទឹកអាស៊ីតមកលើប្តីរបស់ខ្លួន ដោយសារប្តីនោះបានវាយដំ ធ្វើបាប រំលោភផ្លូវភេទ ប្រព្រឹត្តអំពើហិង្សាដាក់នាង ។ នេះបានបង្ហាញអោយឃើញនូវរឿងរ៉ាវអាចកើតចេញមកនៅពេលដែលគេមិនបានបញ្ឈប់អំពើហិង្សាក្នុងគ្រួសារបាន ហើយទទ្ទឹមគ្នានោះ ជនរងគ្រោះមានអារម្មណ៍ថាខ្លួនគ្មានវិធីណាផ្សេងក្រៅតែពីជះទឹកអាស៊ីតដើម្បីការពារខ្លួន ។ ការជះទឹកអាស៊ីតស្តែងអោយឃើញនូវបញ្ហាធ្ងន់ធ្ងរក្នុងសង្គមជាតិ និងសង្គមគ្រួសារខ្មែរ ។ ឫសគល់នៃបញ្ហាទាំងឡាយនៃការប្រើទឹកអាស៊ីតវាយប្រហារគ្នានេះ រួមមានអំពើហិង្សា និងបញ្ហាសង្គមឈានដល់កំរិតខ្ពស់មួយក្នុងសង្គមកម្ពុជា ហើយនិងការរីករាលដាលធំឡើងនៃការប្រកាន់រើសអើងចំពោះស្ត្រីភេទ ។

កត្តាសង្គ្រាមអូសបន្លាយរាប់ទសវត្សរ៍ ការប្រល័យពូជសាសន៍ និងភាពក្រីក្របានបំផ្លាញសីលធម៌សង្គម បំផ្លាញគោលការរបស់ព្រះពុទ្ធសាសនា និងតម្លៃសង្គមគ្រួសារមនុស្ស ហើយផ្ទុយមកវិញកត្តាទាំងនេះនាំមកនូវអំពើហិង្សា និងឧក្រិដ្ឋកម្មផ្សេងៗក្នុងសង្គមទៅវិញ ។ មនុស្សជាច្រើនបានប្រើប្រាស់អំពើហិង្សាជាមធ្យោបាយដើម្បីដោះស្រាយបញ្ហា ឬទំនាស់របស់ពួកគេ ។ អំពើហិង្សាជារឿងធម្មតាមួយក្នុងសង្គមគ្រួសារកម្ពុជា ហើយក៏ដូចជាបញ្ហាសង្គមមួយចំនួនទៀតដែរ ដូចជាការស្រវឹងខួប ជម្លោះចេញពីអាពាហ៍ពិពាហ៍ អំពើសាហាយស្មន់ក៏ទៅជារឿងធម្មតានៅក្នុងសង្គមដែរ ។ បុរសមួយចំនួនវាយដំច្រំធាក់ប្រពន្ធរបស់ខ្លួន ឬ

លួចមានស្រីកំណាន់ ឬប្រពន្ធចុងច្រើននាក់ ។ ស្ត្រីជាប្រពន្ធមានអំណាចតិចតួចណាស់មិនអាចអោយពួកគេបញ្ឈប់ទង្វើអសីលធម៌របស់ប្តីនាងទាំងនេះបាន ឬក៏មិនអាចទាមទាររកយុត្តិធម៌សំរាប់ខ្លួននាងបានឡើយ ។ ស្ថិតក្នុងស្ថានភាពនេះ គេក៏ជ្រើសរើសយកវិធីជះទឹកអាស៊ីតជំនួសអោយមធ្យោបាយសន្តិវិធី ឬមធ្យោបាយស្របច្បាប់ដើម្បីបញ្ចប់នូវការឈ្នានីស កំហឹង ឬព្យាយាមរកការដោះស្រាយបញ្ហារបស់គេនោះឡើយ ។

កត្តាផ្សេងៗទៀតដែលនាំដល់ការវាយប្រហារទឹកអាស៊ីតនោះរួមមាន អាស៊ីតជាអាវុធមួយដែលមានតម្លៃថោក ងាយរកទិញបាន និងងាយប្រើប្រាស់ទៀតផង បើប្រៀបទៅនឹងកាំភ្លើង កាំបិត ឬគ្រាប់បែក ។ បញ្ហាមួយទៀត គឺភាពទន់ខ្សោយនៃនយោបាយគ្រប់គ្រង និងប្រព័ន្ធតុលាការពុករលួយ គ្មានប្រសិទ្ធិភាព ឬបំពាក់ទៅដោយធនធានកង្វះសមត្ថភាពគ្រប់គ្រាន់ ជាមូលហេតុធ្វើអោយអ្នកជះទឹកអាស៊ីត និងពួកឧក្រិដ្ឋជនផ្សេងៗមានលទ្ធភាពគេចចេញពីរង្វង់អំណាចច្បាប់បានដោយងាយ ។ ជាពិសេសគឺពួកជនអ្នកមានលុយកាក់ ឬអំណាចខ្លាំងជាងជនរងគ្រោះនោះ ។ ប្រសិនបើជនល្មើសមិនត្រូវបានគេដាក់ទោសទេនោះ វាជាកត្តាមួយជួយជំរុញអោយមនុស្សដែលមានបំណងរំលោភច្បាប់គិតថា ពួកគេក៏អាចប្រព្រឹត្តបទឧក្រិដ្ឋដូចគេឯងបានដែរ ហើយក៏ទទួលបាននូវនិរទណ្ឌភាពដូចគេឯងផងដែរ ។

បើគ្មានវិធានការម៉ឺងម៉ាត់ចំពោះអ្នកជះទឹកអាស៊ីតទេនោះ ករណីជះទឹកអាស៊ីតប្រហែលជានឹងកើនឡើង ហើយការជះទឹកអាស៊ីតក៏នឹងកើនឡើងដោយសារកើតចេញពីមូលហេតុផ្សេងៗច្រើនយ៉ាង ។ ដូចគេបានឃើញរួចជាស្រេចមកហើយថា មិនមែនបញ្ហាគ្រួសារតែមួយប៉ុណ្ណោះទេដែលឈានទៅដល់ការជះទឹកអាស៊ីតដាក់គ្នានោះ ។ មានករណីមួយចំនួននៃការជះទឹកអាស៊ីតកើតចេញមកពីអំពើប្លន់ ឬជំលោះបុគ្គលដែលមិនទាក់ទងទាល់តែសោះទៅនឹងបញ្ហាគ្រួសារ ។ តាមពតិមានចេញពីវេជ្ជបណ្ឌិតតាមបណ្តាមន្ទីរពេទ្យមួយចំនួនថា ពួកគាត់បានជួបករណីជះទឹកអាស៊ីតខ្លះមានការពាក់ព័ន្ធទៅនឹងរឿងជំលោះវិវាទដីធ្លី ឬកម្មសិទ្ធិ ។

ប្រទេសកម្ពុជាគួរតែរៀនសូត្រស្វែងយល់មេរៀនពីប្រទេសដ៏ទៃ ដូចជា ប្រទេសបង់ក្លាដេសជាដើម ដោយសារតែ គ្មានការដាក់ទោសដល់ជនល្មើសសោះនោះហើយបានជាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ អំពើហិង្សានៃការជះទឹកអាស៊ីតនេះបានកើនឡើងយ៉ាងខ្លាំងក្លា ។ នៅពេលដែលការជះទឹកអាស៊ីតក្លាយទៅជារឿងធម្មតាក្នុងសង្គមបង់ក្លាដេសនោះ ហើយដែលនាំអោយប្រភេទនៃជនរងគ្រោះ និងមូលហេតុនៃការជះទឹកអាស៊ីតកើនចំនួនឡើង ។ កាលពីគ្រាមុននេះ គេជះទឹកអាស៊ីតទៅលើតែស្ត្រីពីសំណាក់ពួកបុរសដែលប្រច័ណ្ឌ ឬមានកំហឹងទៅលើស្ត្រីទាំងនោះ ។ ឥឡូវនេះមានជាង ៣០ភាគរយនៃជនរងគ្រោះជាបុរសភេទ ហើយករណីជំលោះដីធ្លី គឺជាមូលហេតុចម្បងបំផុតនៃការជះទឹកអាស៊ីត ។

## ■ តើគេប្រើអាស៊ីតប្រភេទណាខ្លះ ?

អ្នកជះទឹកអាស៊ីតភាគច្រើនប្រើប្រាស់អាស៊ីតស៊ុលភួរិច ឬអាស៊ីតនីទ្រិច ដែលជាអាស៊ីតខ្លាំងបំផុតដែលអាចស៊ីរំលាយស្បែក សាច់ដុំ រហូតដល់ឆ្អឹងមនុស្សទៀតផង ។

អាស៊ីតស៊ុលភួរិចជាអាស៊ីតមួយ ដែលគេនិយមប្រើដោយសារវាជាប្រភេទអាស៊ីតមួយដែលគេប្រើប្រាស់សំរាប់ចាក់អាគុយឡាន និងម៉ូតូ ។ អាស៊ីតនៅក្នុងអាគុយជាអាស៊ីតល្បាយលាយ វាមានលាយទឹកពី ៧០ ទៅ ៨០ ភាគរយ ដូចនេះវាជាអាស៊ីតមួយខ្សោយ នឹងមានប្រតិកម្មយឺតកាលណាវាប៉ះលើស្បែកមនុស្សយើង ។ អ្នកជះទឹកអាស៊ីតត្រូវការអាស៊ីតណាដែលខ្លាំងជាងអាស៊ីតចាក់អាគុយនេះ ពោលគឺអាស៊ីតស៊ុលភួរិចមេ ។ អាស៊ីតស៊ុលភួរិចមេមានដាក់តាំងលក់ក្នុងទីក្រុងភ្នំពេញក្នុងតម្លៃប្រហែល ៣.០០០ រៀលក្នុងមួយលីត្រ រីឯអាស៊ីតរាវសំរាប់ចាក់អាគុយវិញមានតម្លៃ ៥០០ ទៅ ៦០០ រៀលក្នុងមួយលីត្រ ។ ជួនកាលអាស៊ីតស៊ុលភួរិចត្រូវគេយកមកប្រើប្រាស់សំរាប់លាយធ្វើជាទឹកខ្មេះផងដែរ ទោះជាអាជ្ញាធរខាងសុខមាលភាពបានបង្រ្កាបលើការប្រើប្រាស់ទឹកខ្មេះបែបនេះដែលនាំអោយខូចសុខភាពដល់អ្នកទទួលទានក៏ដោយ ឬជួនកាលទៀតគេប្រើអាស៊ីតស៊ុលភួរិចមេនេះ ដើម្បីរំលាយវត្ថុដែលនៅកកស្ទះក្នុងបំពង់លូផ្លាស្ទិកសំរាប់បង្ហូរទឹក ។

ក្នុងប្រទេសកម្ពុជា ជាងមាសប្រើប្រាស់អាស៊ីតនីទ្រិចសំរាប់បន្សុទមាស ចំរាញ់មាសចេញអំពីប្រាក់ និងលោហៈធាតុផ្សេងៗទៀត ។ អាស៊ីតនីទ្រិចលក់ក្នុងតម្លៃប្រហែល ៦.០០០ រៀលក្នុងមួយលីត្រ ។

អាស៊ីតមួយប្រភេទទៀត ដែលអ្នកជះទឹកអាស៊ីតធ្លាប់បានប្រើប្រាស់ដែរនោះ គឺអាស៊ីតក្លរីទ្រិច តែអាស៊ីតប្រភេទនេះមិនសូវបានអ្នកជះទឹកអាស៊ីតនិយមប្រើជាទូទៅនោះទេ ។ ក្នុងប្រទេសកម្ពុជា គេប្រើប្រាស់អាស៊ីតប្រភេទនេះសំរាប់ដុសខាត់គ្រឿងអល័ង្កាអោយថ្មី ហើយអាស៊ីតនេះក៏ត្រូវបានគេយកមកប្រើប្រាស់សំរាប់ធ្វើទឹកស៊ីអ៊ីវ និងសំរាប់កែឆ្នៃអនុផលព្រៃឈើ (សារធាតុពណ៌លឿងដែលមានក្នុងវល្លិរមៀត) ដើម្បីធ្វើជាគ្រឿងសំអាងនឹងធ្វើជាឱសថបុរាណ ។ អាស៊ីតក្លរីទ្រិច និងអាស៊ីតស៊ុលភួរិចត្រូវបានគេប្រើប្រាស់ដោយខុសច្បាប់សំរាប់ផលិតថ្នាំញៀនអំហ្វេតាមីន ដែលគេជឿថាប្រភេទថ្នាំគ្រឿងញៀននេះកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ។

ក្នុងដើមឆ្នាំ២០០០ កន្លងទៅនេះ សាលាក្រុងភ្នំពេញបានចាត់វិធានការការពារកុំអោយមានការវាយប្រហារដោយទឹកអាស៊ីត បានចេញបញ្ជាអោយអាជ្ញាធរមានសមត្ថកិច្ចព្រមានដល់អ្នកលក់ទឹកអាស៊ីតកុំអោយលក់អាស៊ីតមេទៅអ្នកទិញ លើកលែងតែអ្នកទិញដែលមានអាជ្ញាប័ណ្ណ ហើយដែលយកអាស៊ីតនេះទៅសំរាប់បំរើមុខជំនួញរបស់ពួកគេ ។ តែបំរាមនេះមិនត្រូវបានគេអនុវត្តអោយមានប្រសិទ្ធិភាពនោះទេ ហើយអ្នកជះទឹកអាស៊ីតនៅតែរកទិញបានអាស៊ីតមេយកមកប្រើប្រាស់ដើម្បីសំរេចបំណងអាក្រក់របស់ខ្លួនដដែល ។

ម្ចាស់ហាងលក់អាគុយមួយនៅក្នុងក្រុងភ្នំពេញបាននិយាយថាក្នុងមួយអាទិត្យ យ៉ាងហោចណាស់មានមនុស្សពីពីរ ទៅបីនាក់ដែរមកសួររកទិញអាស៊ីតមេដែលមិនទាន់លាយទឹក។ ម្ចាស់ហាងនោះបាននិយាយបន្ថែមទៀតថា គាត់ដឹងថាពួកគេចង់យកអាស៊ីតនេះទៅប្រើប្រាស់ក្នុងបំណងអាក្រក់ ដូច្នេះគាត់បដិសេធមិនលក់ទឹកអាស៊ីតនោះអោយទេ។ ប៉ុន្តែមិនមែនគ្រប់តែអ្នកលក់ទឹកអាស៊ីតទាំងអស់គិតពិចារណាថា តើអ្នកណាខ្លះ ពួកគាត់គួរលក់ទឹកអាស៊ីតអោយ ឬពួកគេយកទឹកអាស៊ីតទៅប្រើប្រាស់ក្នុងគោលបំណងអ្វីនោះទេ ។

## ២.ករណីឧទាហរណ៍ ៖ រឿងពិតនៃការវាយប្រហារដោយទឹកអាស៊ីត

នៅថ្ងៃមួយនាខែ ឧសភា ឆ្នាំ ២០០២ម្តាយបានប្រាប់ទៅកូនប្រុសអាយុ១៣ឆ្នាំរបស់គាត់អោយជិះម៉ូតូទៅជាមួយគាត់ទៅភូមិក្បែរនោះ ។ ស្ត្រីជាម្តាយនោះ ដែលមានយួរដបទឹកក្រូចផ្លាស្ទិចមួយនៅនឹងដៃផងនោះ បានមកសំកុករង់ចាំជាមួយកូនប្រុសរបស់គាត់នៅជិតកូនផ្ទះជួលមួយ ។ ស្ត្រីក្មេងមានផ្ទៃពោះ៨ខែបានដើរចេញពីក្នុងផ្ទះជួលនោះមកក្រៅរកមើលទិញផ្លែឈើត្រាំ ដែលមានដាក់លក់នៅក្នុងតូបក្បែរកូនផ្ទះជួលនោះ ។ រំពេចនោះស្ត្រីជាម្តាយបានហុចដបទឹកក្រូចដែលគាត់យួរនៅនឹងដៃនោះអោយទៅកូនប្រុសរបស់គាត់ដោយចង្អុលទៅស្ត្រីក្មេងដែលមានផ្ទៃពោះ៨ខែនោះ ។ កូនប្រុសបានអនុវត្តតាមអ្វីដែលម្តាយរបស់ខ្លួនបានប្រាប់ គឺគេបានរត់សំដៅទៅរកស្ត្រីមានផ្ទៃពោះនោះ ហើយជះទឹកអាស៊ីតសំដៅទៅរកផ្ទៃមុខរបស់នាង ដែលទឹកអាស៊ីតបានស្រោចស្រពពេញផ្ទៃមុខរបស់នាងនឹងបាចសាចទៅត្រូវដៃ និងផ្ទៃពោះរបស់នាង ។ ក្រោយពីជះចប់សព្វគ្រប់ហើយកូនប្រុសនោះរត់មករកម៉ូតូដែលមានម្តាយរបស់ខ្លួនអង្គុយចាំនៅលើនោះ ជាស្រេចរួចហើយជិះចេញទៅភ្លាម ។ កូនប្រុសនោះមិនប្រាកដជាបានដឹងដែរ ឬអត់ដឹងថាវត្ថុរាវនៅក្នុងដបទឹកក្រូចនោះគឺជាទឹកអាស៊ីត ។ ម្តាយរបស់ក្មេងប្រុសនោះបានប្រើប្រាស់កូនរបស់ខ្លួនសំរាប់វាយប្រហារស្រីកំណាន់របស់ប្តីខ្លួនដោយចេតនា។ ក្រោយពីម៉ូតូបាននាំយកពីរនាក់ម្តាយកូនចេញផុតទៅ បន្សល់ទុកនូវស្រីក្មេងរងគ្រោះនោះស្រែកទ្រហោយំដោយការឈឺចុកចាប់ដោយសារអាស៊ីតបានស៊ីចូលដល់សាច់របស់នាង។ ផ្ទៃមុខរបស់នាងបានរលាកឡើងពណ៌ខ្មៅរោល ហើយភ្នែក និងត្រចៀកម្ខាងរបស់នាងត្រូវទឹកអាស៊ីតស៊ីដាច់បាត់ភ្លាម។ ពេលនោះគេឃើញម្តាយរបស់នារីរងគ្រោះចេញមកជួយកូនស្រីរបស់គាត់ ដោយហៅរកម៉ូតូឌុបអោយយកកូនគាត់ទៅកាន់មន្ទីរពេទ្យជាបន្ទាន់ ។

រឿងរ៉ាវនៃការជះទឹកអាស៊ីតបានចាប់ផ្តើមកាលពីពីរឆ្នាំមុន ពេលនាងសោភា[២] មានអាយុទើបតែ១៨ឆ្នាំ ហើយដែលកាលនោះនាងបំរើការជាស្រីអ្នកលក់ស្រាបៀរក្នុងភោជនីយដ្ឋានមួយ ។ នាងបានស្គាល់នឹងចងមិត្តភាពជាមួយអ្នករត់ម៉ូតូឌុបម្នាក់មានអាយុ ៣៤ឆ្នាំ ដែលតែងតែមកដឹកនាងទៅមកពីផ្ទះជួលរបស់នាងមកកន្លែងធ្វើការជាទៀងទាត់ ។ សោភាបានរៀបរាប់ប្រាប់អ្នករត់ម៉ូតូឌុបនោះនូវរឿងរ៉ាវស្តីពីភាពក្រីក្ររបស់គ្រួសារនាងនៅខេត្តព្រៃវែង ដែលភាពក្រីក្រនេះបានបង្ខំអោយនាងមកធ្វើការជាស្រីលក់ស្រាបៀរក្នុងខេត្តកំពង់ចាម ។ បុរសរត់ម៉ូតូឌុបនោះ ក្រោយពីស្តាប់រឿងរ៉ាវរបស់នាងហើយ ក៏ពោលថាគាត់មានការអាណិតអាសូរ

[2] សោភាមិនមែនជាឈ្មោះពិតរបស់នាងទេ នេះគ្រាន់តែជាឈ្មោះប្រើប្រាស់ដើម្បីលាក់អត្តសញ្ញាណពិតរបស់នាង ។

នាងខ្លាំងណាស់ ។ ក្រោយមកបុរសនោះការផ្តើមទំនាក់ទំនងជាមួយនាងសោភា ទោះជាបុរសនោះបានរៀបការរួចហើយព្រមទាំងមានកូនប្រុស-ស្រីពីរនាក់ទៀតក៏ដោយ ។

សម្ព័ន្ធភាពនេះមានអាយុកាលជិតពីរឆ្នាំមុនពេលបែកការណ៍ដល់ប្រពន្ធបុរសនោះ ។ នាងជាប្រពន្ធនោះបានប្រាប់អោយបុរសជាប្តីនាងបញ្ចប់ចំណងស្នេហាជាមួយនាងសោភា តែបុរសជាប្តីមិនបានផ្តាច់ការទាក់ទងជាមួយនាងឡើយ ពោលគឺទាំងបុរសជាប្តី និងនាងសោភាបានបន្តទំនាក់ទំនងស្នេហារបស់ពួកគេដូចសព្វមួយដង ។

ក្រោយពីនាងសោភាមានផ្ទៃពោះ នាង និងបុរសនោះបានពង្រត់គ្នាទៅរស់នៅទីឆ្ងាយឯខេត្តព្រៃវែង បួនខែក្រោយមក បងប្អូនខាងប្រពន្ធរបស់បុរសនោះបានមកតាមរកពួកគេឃើញ ហើយបានប្រាប់អោយបុរសនោះត្រឡប់ទៅខេត្តកំពង់ចាមរួមរស់ជាមួយប្រពន្ធរបស់គាត់វិញ ។ បុរសនោះក៏បានវិលត្រឡប់ទៅរស់នៅជាមួយប្រពន្ធរបស់គាត់វិញ ។ ស្របពេលនោះដែរនាងសោភាក៏បានចាកចេញពីខេត្តព្រៃវែងមករស់នៅក្នុងទឹកដីខេត្តកំពង់ចាមវិញដែរ ។ ថ្វីត្បិតតែបុរសនោះមករស់នៅជាមួយប្រពន្ធគាត់ក៏ពិតមែន តែគាត់នៅបន្តទំនាក់ទំនងស្នេហាជាមួយនាងសោភាដោយលួចលាក់នៅក្នុងផ្ទះជួលរបស់នាង ។

នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០២ នាងជាប្រពន្ធបានរកឃើញលំនៅដ្ឋានជួលរបស់នាងសោភា ហើយថែមទាំងបានឃើញប្តីរបស់គាត់នៅក្នុងផ្ទះនោះជាមួយគ្នាទៀត ។ ឃើញដូចនោះនាងជាប្រពន្ធខឹងខ្លាំងណាស់ក៏ទះនាងសោភាមួយកំភ្លៀង ដែលកាលនោះនាងសោភាកំពុងមានផ្ទៃពោះ ៨ខែ ។ ប្តីដែលនៅក្នុងផ្ទះនោះដែរ ក៏ផ្ទុះកំហឹងឡើងលាយឡំ និងភាពអាម៉ាស់ផងក៏ទះកំភ្លៀងស្ត្រីប្រពន្ធដើមនោះវិញ ។ នាងជាប្រពន្ធនោះក៏បានដើរចេញបាត់ទៅ ។

ថ្ងៃបន្ទាប់មកបុរសជាប្តីបានវិលត្រឡប់មកផ្ទះប្រពន្ធដើមរបស់ខ្លួនវិញ ។ នាងជាប្រពន្ធដើមនោះស្រែកឡូឡាស្តីបន្ទោសដល់គាត់ តែបុរសនោះមិនអើពើឡើយ ពោលគឺបុរសនោះដើរចេញទៅលេងបុកប៊ីយ៉ាជាមួយអ្នកជិតខាងគាត់ធ្វើព្រងើយ ។ នាពេលថ្ងៃត្រង់នៃថ្ងៃនោះ បងប្រុសរបស់គាត់រត់មកប្រាប់គាត់ថានាងសោភាត្រូវបានគេយកទឹកអាស៊ីតមកជះស្រោចលើខ្លួននាងហើយ ។

ក្រោយពីការវាយប្រហារនោះមក នាងសោភាត្រូវបានគេនាំទៅកាន់មន្ទីរពេទ្យ ឯប្រពន្ធដើម និងកូនប្រុសអាយុ ១៣ឆ្នាំរបស់គាត់ត្រូវបានប៉ូលីសឃាត់ខ្លួនទុក ។ ក្នុងអំឡុងពេលនៃការឃុំខ្លួននេះ ប្រពន្ធដើមមានបញ្ហាសុខភាពក៏ត្រូវបានប៉ូលីសបញ្ជូននាងទៅកាន់មន្ទីរពេទ្យខេត្តដែលជាទីកន្លែងដែលនាងសោភាកំពុងសំរាកព្យាបាលដែរ តែពួកគេទាំងពីរនាក់នេះស្នាក់នៅបន្ទប់ខុសគ្នា ។

ថ្ងៃបន្ទាប់មកទៀត ប៉ូលីសបានបញ្ជូនករណីជះទឹកអាស៊ីតនេះទៅតុលាការខេត្ត ។ តុលាការក៏បានសួរចំលើយជនជាប់សង្ស័យនោះ តែដោយបញ្ហាសុខភាពស្ត្រីជាប្រពន្ធដើមនោះរើឡើងវិញត្រូវតុលារអនុញ្ញាតអោយត្រឡប់ទៅសំរាកពេទ្យវិញ ឯកូនប្រុសនោះត្រូវបានបញ្ជូនខ្លួនទៅកាន់មន្ទីរឃុំឃាំងជាបណ្តោះអាសន្ន ។

ឪពុករបស់ប្រពន្ធដើមបានជួលមេធាវីនៅខេត្តកំពង់ចាមម្នាក់ ។ មេធាវីនេះនឹងប្តីរបស់ជនដៃដល់ (ជាអ្នកដែលបង្កើតចំណងស្នេហ៍ជាមួយនាងសោភា) បានទៅបញ្ចុះបញ្ចូលម្តាយនាងសោភាអោយដកពាក្យបណ្តឹង

ចេញពីតុលាការវិញ ដោយគេយល់ព្រមសងសំណងព្យាបាល ។ ម្តាយនាងសោភាបានទទួលប្រាក់១០០ដុល្លាម្តង និងម្តងទៀត ១០០.០០០រៀល ។ មន្ត្រីតុលាការយល់ព្រមអោយដកពាក្យបណ្តឹងនោះ ទោះបីជាច្បាប់មិនបានអនុញ្ញាតអោយករណីព្រហ្មទណ្ឌអាចត្រូវដោះស្រាយបានតាមរយៈការព្រមព្រៀងគ្នាក្រៅផ្លូវតុលាការក៏ដោយ ។

នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ ក្មេងប្រុសអាយុ ១៣ឆ្នាំដែលបានជះទឹកអាស៊ីតលើនាងសោភាត្រូវបានដោះលែងចេញពីពន្ធនាគារ ។ម្តាយរបស់ក្មេងប្រុសនេះបាននាំគេ និងប្អូនស្រីរបស់គេផ្លាស់ទៅនៅទីកន្លែងថ្មីមួយទៀត ។

សោភាបានសំរាកពេទ្យអស់រយៈពេល៧សប្តាហ៍ ។ ច្រមុះនាងត្រូវអាស៊ីតស៊ីរលេះរលួយបាត់ទាំងស្រុង ភ្នែកនាងទាំងសងខាងខ្វាក់ជារៀងរហូត ឯត្រចៀកស្តាំរបស់នាងវិញស្ទើរតែត្រូវអាស៊ីតស៊ីអស់ទាំងស្រុង ។ មុខរបស់នាងក៏ដូចជាស្មាស្តាំ និងដៃពោរពេញទៅដោយស្លាកស្នាមអាក្រក់គួរអោយខ្លាច ។

ប្រាំមួយសប្តាហ៍ក្រោយពីការវាយប្រហារដោយទឹកអាស៊ីតនោះមក នាងសោភាបានប្រសូតទារិកាមួយ ។ នាងសោភាមិនអាចមើលឃើញមុខកូនស្រីរបស់នាងទេ នាងមានតែយកដៃទៅស្ទាបរាប់ម្រាមដៃម្រាមជើងនឹងស្ទាបរកមើលភ្នែក ច្រមុះ និងមាត់របស់កូនស្រីនាង ដើម្បីមើលអោយដឹងថាកូននាងមានរូបរាងពេញលេញជាមនុស្សដូចគេឯងដែរ ។ ព្រោះនាងព្រួយបារម្ភថាទឹកអាស៊ីតនោះអាចមានផលប៉ះពាល់ដល់កូនរបស់នាង តែទារកនេះទំនងដូចជាមិនអីទេ ។ នាងសោភាបានមើលថែទាំកូនរបស់នាងដោយយកចិត្តទុកដាក់ និងដោយក្តីស្រឡាញ់ថ្នាក់ថ្នម នាងបីបំពេរកូនរបស់នាងក្នុងរង្វង់ដៃរបស់នាងទាំងទ្វេរ ។ តែគួរអោយអាសូរនាងណាស់ សុភមង្គលតូចមួយដែលនាងទើបតែបានទទួលនេះមិនបានស្ថិតស្ថេរជាមួយនាងទេ។ បួនថ្ងៃក្រោយមក បុត្រីសំណប់ចិត្តរបស់នាងក្តៅខ្លួនយ៉ាងខ្លាំង ព្រមទាំងប្រកាច់ រួចហើយក៏លាចាកលោកនេះទៅ ។ គ្មានអ្នកណាគេបានដឹងពីមូលហេតុពិតប្រាកដនៃការស្លាប់របស់ទារិកានេះនៅឡើយទេ ។

ក្រោយពេលចាកចេញពីមន្ទីរពេទ្យមក នាងសោភាបានត្រឡប់មករស់នៅជាមួយម្តាយបង្កើតរបស់នាងវិញ ។ ម្តាយនាងជាស្ត្រីមេម៉ាយរស់នៅក្នុងផ្ទះជួលមួយ ។ មន្ទីរពេទ្យបានទារប្រាក់ថ្លៃឈ្នួលព្យាបាលពីនាងសោភាតម្លៃ ២០០.០០០រៀលតែដោយមើលឃើញថាគ្រួសារនាងក្រីក្រខ្លាំងពេកមន្ទីរពេទ្យក៏បានលើកលែងមិនយកប្រាក់ពីនាងទេ ។ តែទោះជាយ៉ាងនេះក៏ដោយ ម្តាយរបស់នាងសោភាបានចំណាយប្រាក់អស់ ៥០០.០០០ រៀលរួចជាស្រេចដែរក្នុងការទិញថ្នាំមកព្យាបាលនាងនៅក្នុងមន្ទីរពេទ្យ ។ មកដល់ផ្ទះវិញម្តាយនាង និងនាងសោភាប្រឹងត្រដររស់យ៉ាងត្រដាបត្រដួស ។ នាងសោភាពឹងផ្អែកទាំងស្រុងលើម្តាយរបស់នាងក្នុងការរកប្រាក់មកទិញអាហារ និងសំរាប់ចំណាយផ្សេងៗទៀតជាហេតុធ្វើអោយប្រាក់សំណងដែលបានទទួលពីជនដៃដល់មកនោះអស់យ៉ាងឆាប់រហ័ស ។ ប្រាក់ចំណូលដែលរកបានពីការលក់ចាហួយកែវរបស់ម្តាយនាងសោភាមានចំនួនតិចតួចមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពគ្រួសារនាងទេ ។

ប្តីរបស់ជនដៃដល់បានមកនៅកំដរនាងសោភាគ្រាដែលនាងស្នាក់នៅក្នុងមន្ទីរពេទ្យ ក្រោយមកបានមកនៅកំដរនាងមួយរយៈខ្លីទៀតក្រោយពីនាងបានចាកចេញពីមន្ទីរពេទ្យ ។ បុរសនោះបាននិយាយប្រាប់គេ

ឯងថា គាត់ដឹងថាសាច់ញាតិខាងប្រពន្ធដើមគាត់នឹងមិនអធ្យាស្រ័យអោយគាត់ឡើយ ។ គាត់បន្ថែមទៀតថា ឥឡូវនេះគាត់គ្មានអ្វីជាប់នឹងខ្លួននោះទេ ហើយក៏មិនទាន់ដឹងថាគាត់ត្រូវរស់នៅដោយរបៀបណាដែរ ។ ប្រពន្ធដើមរបស់គាត់ និងឪពុករបស់នាងបានប្រមូលយករបស់របរសព្វសារពើរទាំងអស់នៅក្នុងផ្ទះ នៅពេលដែលពួកគេបានផ្លាស់ផ្ទះទៅនៅទីកន្លែងថ្មី ។ បុរសជាប្តីអាចនឹងបាត់បង់សំបកផ្ទះនិងដីដែលសង់ផ្ទះនោះដោយសារការរឹបអូសនៃការជំពាក់បំណុលធនាគារអេស៊ីលីដា ដែលគ្រួសារគាត់បានខ្ចីយកមកប្រកបមុខរបរខ្នាតតូចមួយ ។បុរសនោះបានសំរេចថាមកស្នាក់នៅជាមួយនាងសោភា ហើយដើររកការងារធ្វើតែគាត់បារម្ភថាភាពអត់ឃ្លាននឹងអាចជំរុញអោយគាត់ក្លាយទៅជាចោរប្លន់ ឬចោរលួចក៏ថាបាន ។

បួនខែក្រោយពីការជះទឹកអាស៊ីតនោះមក ម្តាយរបស់នាងសោភាបានជូននាងមកកាន់មន្ទីរពេទ្យភ្នំពេញ ដើម្បីតាមដានមើលការរះរបស់នាងបន្ត ពេលនោះម្តាយរបស់នាងក៏បានទុកនាងចោលដោយគាត់រត់តាមមិត្តប្រុសថ្មីរបស់គាត់ ។ ម្តាយរបស់នាង និងមិត្តប្រុសរបស់គាត់នោះបានមកផ្ទះជួលរបស់នាងដែលនៅខេត្តកំពង់ចាម ហើយប្រមូលយកទ្រព្យសម្បត្តិក្នុងផ្ទះទាំងអស់ ហើយនាំគ្នាទៅរស់នៅក្នុងខេត្តព្រៃវែងបាត់ទៅ ។ ពីរខែក្រោយមក ម្តាយរបស់នាងសោភាបានជះទឹកអាស៊ីតលើមិត្តប្រុសរបស់គាត់ ក្រោយពីពួកគេបានឈ្លោះប្រកែកទាស់ទែងគ្នាមក ។ ជាភ័ព្វសំណាងទឹកអាស៊ីតដែលម្តាយនាងបានយកមកប្រើនោះជាប្រភេទអាស៊ីតខ្សោយដែលគេប្រើសំរាប់ចាក់អាគុយ ហេតុនេះវាមិនបានធ្វើអោយមិត្តប្រុសគាត់ខ្វាក់ភ្នែក ឬបង្ករបួសអ្វីធ្ងន់ធ្ងរនោះទេ ។ ខាងប៉ូលីសមានបំណងចង់ចាប់ឃាត់ខ្លួនម្តាយនាង តែមិត្តប្រុសរបស់ម្តាយនាងបានសុំអង្វរកុំអោយប៉ូលីសចាប់ខ្លួនគាត់អី ។

ទីបញ្ចប់ម្តាយនាងបានវិលមករួមរស់ជាមួយនាងសោភា និងប្តីរបស់ជនដៃដល់ដែលបានជះទឹកអាស៊ីតដាក់នាង ដែលកំពុងរស់នៅកំដរនាងនាក្រុងភ្នំពេញក្នុងខណៈពេលដែលម្តាយរបស់នាងរត់ចោលទៅរស់នៅជាមួយមិត្តប្រុសរបស់គាត់នៅឯខេត្តព្រៃវែង ។ ដោយមានការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលមួយបានជួលផ្ទះតូចមួយ ដើម្បីអោយនាងសោភាស្នាក់នៅបណ្តោះអាសន្ន ។ តែម្ចាស់ផ្ទះជួលរបស់នាងនោះមាក់ងាយនាងណាស់នឹងបានដើរខ្សឹបខ្សៀវនិយាយដើមនាង ដោយសារតែនាងបានរងគ្រោះដោយការជះទឹកអាស៊ីត ។ នាងក៏បានចាកចេញទៅរស់នៅផ្ទះជួលមួយទៀត ដែលម្ចាស់ផ្ទះក្រោយនេះមានចិត្តអាណិតអាសូរដល់រូបនាងខ្លះដែរ ។

នាងសោភាបានរស់ប្រឈមមុខនឹងទុក្ខវេទនារួមទាំងការស្រេកឃ្លាន ។ នាងត្រូវរៀនរស់ក្នុងភពងងឹតអន្ធការក្រោយពីនាងបានបាត់បង់ភ្នែកទាំងគូរបស់នាងមក ហើយជាមួយគ្នានេះមុខមាត់នាងពោរពេញទៅដោយស្លាកស្នាមអាក្រក់គួរអោយខ្លាច។ ដោយសារទុក្ខព្រួយ និងភាពអស់សង្ឃឹមពីមួយថ្ងៃទៅមួយថ្ងៃនាងអង្គុយសំរក់ទឹកភ្នែកឥតឈប់ឈរឡើយ ។ នាងមិនទាន់ដឹងថា តើនាងត្រូវរស់នៅយ៉ាងដូចម្តេចនោះទេ ។

# ៣. ស្ថិតិនៃការវាយប្រហារទឹកអាស៊ីតដកស្រង់ចេញពីកាសែតនានា

## ▪ តើមានការវាយប្រហារដោយទឹកអាស៊ីតប៉ុន្មានករណីមកហើយ

យ៉ាងហោចណាស់ក៏មានការវាយប្រហារទឹកអាស៊ីត ៤៤ ករណី ដែលត្រូវបានគេរាយការណ៍តាមសារពត៌មានក្នុងស្រុក ក្នុងរយៈពេលបីឆ្នាំគិតចាប់ពីខែ ធ្នូ ឆ្នាំ ១៩៩៩ មកទល់ខែ វិច្ឆិកាឆ្នាំ២០០២[៣] ។

ការវាយប្រហារនៅភ្នំពេញបានកើតឡើង ២៤ករណី នៅខេត្តកំពង់ចាម ៧ករណី នៅខេត្តកណ្ដាល ៤ ករណី នៅខេត្តព្រៃវែង ២ករណី នៅខេត្តបាត់ដំបង ២ករណី នឹងនៅខេត្តកំពង់ឆ្នាំង កំពង់ធំ សៀមរាប ក្រុងព្រះសីហនុ កំពង់ស្ពឺ កើតមាន ១ករណីក្នុងខេត្តនិមួយៗ ។

ចំនួននៃការវាយប្រហារទឹកអាស៊ីត គណនាក្នុងខ្នាតមធ្យមរាល់ពេល ៦ ខែ សំរាប់អំឡុងពេលជាងបីឆ្នាំ បានយកមកបកស្រាយបង្ហាញជូនតាមតារាងខាងក្រោមនេះ[៤] ។




[3] អង្គការលីកាដូបានចាប់ផ្ដើមកត់ត្រាការវាយប្រហារដោយទឹកអាស៊ីតចេញពីការចុះផ្សាយលើសារពត៌មានក្នុងស្រុកពីរ គឺកាសែតរស្មីកម្ពុជា និងកោះសន្តិភាព ចាប់ពីខែធ្នូឆ្នាំ១៩៩៩ ក្នុងរបាយការណ៍នេះ ពត៌មានបន្ថែមស្ដីការវាយប្រហារទឹកអាស៊ីតនេះ បានត្រូវដកស្រង់ចេញអំពីប្រភពកាសែតផ្សេងៗ ឬពីការស្រាវជ្រាវស៊ើបអង្កេតផ្ទាល់របស់អង្គការលីកាដូ ។

[4] ក្រាហ្វិកខាងលើនេះ មិនរាប់បញ្ចូលការវាយប្រហារពីរលើក ដែលបានកើតឡើងក្នុងខែ តុលា និងវិច្ឆិកា ឆ្នាំ១៩៩៩ ដោយសារករណីទាំងពីរនេះមិនមានរាយការណ៍នៅក្នុងសារពត៌មានលុះដល់ក្រោយខែធ្នូ ឆ្នាំ១៩៩៩ ។

តាមការបង្ហាញក្នុងក្រាហ្វិកខាងលើ មានសេចក្តីរាយណ៍អំពីការវាយប្រហារជាច្រើនកើតឡើងក្នុងខែ ធ្នូ ១៩៩៩ និង ឧសភា ២០០០ ដែលមានចំនួនវាយប្រហារសរុបចំនួន ១៩លើក ត្រូវនឹង៣៥ ភាគរយ នៃការវាយប្រហារសរុបដែលគេបានរាយការណ៍ក្នុងរយៈពេលបីឆ្នាំ ។ ការវាយប្រហារ ៦ ដង នៃការវាយប្រហារខាងលើបានកើតឡើងក្នុងខែ ធ្នូ ឆ្នាំ១៩៩៩ ដែលជាចំនួននៃការវាយប្រហារខ្ពស់បំផុតតែក្នុងរយៈពេលមួយខែក្នុងអំឡុងពេលបីឆ្នាំខាងលើ ។

គេមិនទាន់បានដឹងអោយពិតប្រាកដនូវមូលហេតុដែលនាំអោយមានការវាយប្រហារដ៏ច្រើនបែបនេះក្នុងរយៈពេលនោះឡើយ ។ តែទំនងថាវាអាចមានការទាក់ទងបន្ទាប់ទៅនឹងហេតុការវាយប្រហារដោយទឹកអាស៊ីតលើអ្នកចំរៀងការ៉ាអូខេ ឈ្មោះ តាត ម៉ារីណា ដែលត្រូវបានកើតឡើងក្នុងថ្ងៃ ទី ៥ ខែធ្នូ ឆ្នាំ ១៩៩៩ នោះដែរ ។ ការវាយប្រហារលើកញ្ញា តាត ម៉ារីណា នេះត្រូវបានលេចឮយ៉ាងសុះសាយ ហើយជនដៃដល់ និងអ្នកផ្សំគំនិតក្នុងការវាយប្រហារនេះមិនត្រូវបានឃាត់ខ្លួន ឬនាំមកតុលាការដើម្បីវិនិច្ឆ័យទោសនៅឡើយ ។ តែក៏ជាការទំនងមួយដែរ ដែលថាចំនួននៃការវាយប្រហារដោយទឹកអាស៊ីតមិនបានកើនឡើង ក្រោយពីករណីនាង តាត ម៉ារីណានេះ ឬដោយសារអ្នកសារពត៌មានមិនសូវមានការចាប់អារម្មណ៍ដូចមុនហើយត្រឡប់ទៅចុះផ្សាយករណីផ្សេងៗវិញ ។ ទោះជាយ៉ាងណាក៏ដោយ គេនៅតែអាចសន្និដ្ឋានបានថា ករណីរបស់នាង តាត ម៉ារីណា នេះពិតជារួមចំណែកដល់ការកើនឡើងនៃការវាយប្រហារទឹកអាស៊ីត ដោយសារមនុស្សភាគច្រើនមើលឃើញគំរូនេះថា ការជះទឹកអាស៊ីតដាក់គ្នាមិនបណ្តាលអោយមានទោសពៃរ៍អ្វីតាមផ្លូវច្បាប់នោះបានជំរុញអោយពួកគេហ៊ានប្រព្រឹត្តអំពើឧក្រិដ្ឋជះទឹកអាស៊ីតដាក់គ្នាបន្តតាមគំរូដូចពោលមកខាងលើ ។

## ▪ តើនរណាខ្លះជាជនរងគ្រោះដោយការវាយប្រហារទឹកអាស៊ីតនេះ ?

មានមនុស្សសរុប ៦៣ នាក់ បានរងគ្រោះដោយការជះទឹកអាស៊ីតក្នុងរយៈពេលបីឆ្នាំកន្លងមកនេះដែលក្នុងចំណោមនោះមានជនរងគ្រោះ ៣១នាក់ជាបុរស និង ៣០នាក់ទៀតជាស្ត្រី ហើយមាន ២នាក់ទៀតសារពត៌មានមិនបានបញ្ជាក់អំពីភេទរបស់ជនរងគ្រោះនោះទេ ។

យ៉ាងហោចណាស់ក៏មានជនរងគ្រោះ ១៨នាក់ដែរ ( ត្រូវជា ២៩ភាគរយ) ដែលមិនមែនជាគោលដៅនៃការវាយប្រហារ តែត្រូវបានទទួលរងគ្រោះដោយចៃដន្យ ។ ពួកគេគឺជាមិត្តភក្តិ ឬក្រុមគ្រួសារជនរងគ្រោះនិងជាអ្នករត់ម៉ូតូឌុបដែលកំពុងតែឌុបជនរងគ្រោះក្នុងពេលដែលគេជះទឹកអាស៊ីត ហើយក្រៅពីនោះ ពួកគេជាអ្នកឈរក្បែរទឹកន្លែងកើតហេតុ ។ ជនរងគ្រោះទាំង ១៨នាក់ខាងលើមាន ១២នាក់ជាបុរស និង៤នាក់ទៀតជាស្ត្រីភេទ (រួមទាំងជនរងគ្រោះពីរនាក់ ដែលគេមិនបានរាយការណ៍អំពីភេទរបស់ពួកគាត់) ដែលជាការបង្ហាញអោយគេឃើញថា ជនដែលជាគោលដៅគ្រោងទុកភាគច្រើនជាស្ត្រីភេទ តែអ្នករងគ្រោះដោយចៃដន្យដោយសារការជះទឹកអាស៊ីតភាគច្រើនជាបុរសទៅវិញ ។

ស្ត្រីដែលរងគ្រោះដោយការជះទឹកអាស៊ីតមានអាយុពី ៥ ទៅ ៤៥ ឆ្នាំ ឯបុរសរងគ្រោះវិញ មានអាយុពី ៥ ទៅ ៥៣ឆ្នាំ ។ ជនរងគ្រោះភាគច្រើន ( ទាំងបុរស និងស្ត្រី) ស្ថិតនៅក្នុងវ័យពី ១៨ ទៅ ៣៣ឆ្នាំ ( សូមពិ

និត្យមើលក្រាហ្វិកខាងក្រោមនេះ[5]) ។ អាយុជាមធ្យមនៃជនរងគ្រោះគឺ ២៤ឆ្នាំចំពោះស្ត្រី និង២៩ឆ្នាំចំពោះបុរស ។




មានអនិតិជន (អាយុក្រោម១៨ឆ្នាំ) ៦ នាក់ ស្ថិតនៅក្នុងចំណោមជនរងគ្រោះដែរ ។ មានពីរករណីជាស្ត្រីវ័យក្មេងអាយុ ១៦ និង ១៧ឆ្នាំដែលទទួលរងការវាយប្រហារទឹកអាស៊ីតដោយចេតនាពីស្ត្រីវ័យចំណាស់ដែលសង្ស័យពួកនាងថាបានទាក់ទងជាមួយប្តីរបស់ពួកគាត់ ។ ក្រៅពីនោះកុមារបួននាក់ទៀតមាន អាយុពី ៤ ទៅ ១២ឆ្នាំបានទទួលរងគ្រោះដោយអចេតនាក្នុងគ្រាជះទឹកអាស៊ីត ។ ជនរងគ្រោះដែលមានវ័យក្មេងជាងគេបំផុតគឺកុមារីអាយុ ៤ឆ្នាំ នោះជាជនរងគ្រោះក្នុងចំណោមជនរងគ្រោះទាំង ៦នាក់ខាងលើដែលបានទទួលរងគ្រោះ នៅពេលដែលស្ត្រីម្នាក់ជះទឹកអាស៊ីតដាក់ប្តីរបស់គាត់ក្នុងឱកាសបុណ្យខួបកំណើតកុមារម្នាក់ទៀត ។

### ស្ត្រីម្នាក់ជះទឹកអាស៊ីតលើកូនប្រុសរបស់ខ្លួនឯង

*ភោគ វាសនា ជាស្ត្រីមានអាយុ ៣២ ឆ្នាំ បានយកទឹកអាស៊ីតទៅជះលើប្តីរបស់គាត់ក្នុងលំនៅដ្ឋាននាទីក្រុងភ្នំពេញរបស់ពួកគេ កាលពីឆ្នាំ២០០២ ក្រោយពីស្ត្រីនោះលេចឮពាក្យចចាមអារ៉ាមថាប្តីរបស់គាត់មានទំនាក់ទំនងជាមួយស្រីផ្សេង ។ ប្តីរបស់នាងបានរងរលាកអាស៊ីតស៊ីមុខ និងដើមទ្រូងយ៉ាងធ្ងន់ធ្ងរ ។ ក្នុងពេលនោះទឹកអាស៊ីតខ្លះបានខ្ចាយទៅប៉ះកូនប្រុសរបស់ពួកគេដែលមានអាយុ ៥ឆ្នាំ ។ នាងវាសនាបានត្រូវឃាត់ខ្លួនដើម្បីយកទៅឃុំឃាំង ហើយឯប្តី និងកូនរបស់គាត់ត្រូវគេនាំយកទៅកាន់មន្ទីរពេទ្យ ។ នាង វាសនា បានប្រាប់ទៅប៉ូលិសថា នាងគ្មានចេតនាបង្ករបួសស្នាមដល់កូនប្រុសរបស់នាងឡើយ តែអាស៊ីតបានខ្ទាតទៅត្រូវ*

[5] ក្រាហ្វិកនេះ មិនរាប់បញ្ចូលស្ត្រីរងគ្រោះពីរនាក់ ដោយសារមិនបានដឹងពីអាយុរបស់ពួកគេ ។

> *កូននាងរួចបាត់ទៅហើយ ។ អ្នកជិតខាងនាងបាននិយាយថាពួកគេមិនដែលឃើញ ឬឮថាប្តីនាងមានប្រពន្ធថ្មីទៀតអ្វីសោះឡើយ ហើយពួកគេក៏មានការងឿងឆ្ងល់ថាហេតុអ្វីបានជានាងវាសនា ប្រព្រឹត្តអំពើឆ្កួតៗដោយសារតែឮពាក្យចចាមអារ៉ាមបែបនេះ ។*

## ▪ នរណាខ្លះជាជនល្មើសក្នុងការជះទឹកអាស៊ីត ហេតុអ្វីក៏គេធ្វើយ៉ាងនេះ?

មានរបាយការណ៍នៃការជះទឹកអាស៊ីតសរុបទាំងអស់ ៤៤ លើក ដែលក្នុងនោះ ២៣ លើកជនដៃដល់ជាស្ត្រីភេទ ហើយ ១៧ លើកជាបុរសជាអ្នកប្រព្រឹត្ត នឹង ៤លើកទៀតគេមិនបានស្គាល់ជនដៃដល់ [6] ។

ភាគច្រើនលើសលុបនៃការវាយប្រហារទឹកអាស៊ីតនេះ (៣២ ករណីក្នុងបណ្តា ៤៤ ករណី) ត្រូវបានទទួលការចោទប្រកាន់ថាបណ្តាលមកអំពីបញ្ហាគ្រួសារ ឬទំនាក់ទំនងបុគ្គល ។ រីឯមូលហេតុនៃការជះទឹកអាស៊ីតក្នុង ៦ករណីផ្សេងទៀតនៃបណ្តាករណីខាងលើបណ្តាលមកអំពីមូលហេតុផ្សេងៗ ។ ចំណែកឯ ៦ ករណីទៀតគេមិនបានរាយការណ៍អំពីមូលហេតុនោះទេ (សូមពិនិត្យមើលតារាងខាងក្រោម) ។

| **មូលហេតុជំរុញអោយជនដៃដល់ធ្វើការវាយប្រហារដោយទឹកអាស៊ីតទាំង** | **៤៤ លើក** |
|---|---|
| ប្រពន្ធវាយប្រហារលើស្ត្រីម្នាក់ទៀត (ដោយសង្ស័យថា) ជាគូកំណាន់ឬប្រពន្ធចុងរបស់ប្តីខ្លួន | ១៣ ករណី |
| ប្តីវាយប្រហារលើប្រពន្ធ ឬអតីតប្រពន្ធរបស់ខ្លួន | ៦ ករណី |
| ស្ត្រីវាយប្រហារលើប្តី ឬឪពុកចុងដែលបានប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារមកលើនាង | ៤ ករណី |
| ប្រពន្ធវាយប្រហារលើប្តីរបស់នាងដោយសារមូលហេតុផ្សេងៗ (ជំលោះអាពាហ៍ពិពាហ៍ លែងលះគ្នា ឬសង្ស័យថាផិតក្បត់គ្នា) | ២ ករណី |
| ស្ត្រីលែងលះប្តីវាយប្រហារលើស្ត្រីម្នាក់ទៀតដែលនាងសង្ស័យថាបានទាក់ទងជាមួយអតីតប្តីនាង | ១ ករណី |
| ប្តីមុនវាយប្រហារលើប្តីក្រោយរបស់អតីតប្រពន្ធខ្លួន | ១ ករណី |
| មិនដឹងមូលហេតុច្បាស់លាស់តែគេសង្ស័យថាមានបញ្ហាពាក់ព័ន្ធនឹងគ្រួសារ ឬសម្ព័ន្ធភាពសហព័ទ្ធ | ៥ ករណី |
| **មូលហេតុពាក់ព័ន្ធនឹងបញ្ហាគ្រួសារ ឬសម្ព័ន្ធភាពផ្ទាល់ខ្លួន សរុប** | **៣២ ករណី** |
| ការឈ្លោះប្រកែកគ្នា ជំលោះ ការសងសឹក ឬអំពើប្លន់ | ៦ ករណី |
| **មូលហេតុផ្សេង សរុបៈ** | **៦ ករណី** |
| **មិនដឹងមូលហេតុជាក់លាក់ សរុបៈ** | **៦ ករណី** |
| **ចំនួនសរុប :** | **៤៤ ករណី** |

ប្រភេទនៃការវាយប្រហារកើតឡើងញឹកញាប់នោះគឺប្រពន្ធជះទឹកអាស៊ីតលើស្រីកំណាន់ ឬប្រពន្ធចុងរបស់ប្តីខ្លួន ។

[6] ស្ថិតិនេះសំដៅលើជនជាប់សង្ស័យ និងជនដែលគេរកឃើញថាមានទោស ។ លើសពីនេះទៅទៀតស្ថិតិនេះ លើកយកមកបង្ហាញជូនតែតួលេខជនដៃដល់សំខាន់ៗ ឬក៏មេក្លោង ដែលបង្កអោយមានការវាយប្រហារទឹកអាស៊ីត តែមិនលើកយកមកបង្ហាញនូវអ្នកផ្សំគំនិតក្នុងការវាយប្រហារទេ ។ តួលេខជនដៃដល់ស្ត្រីនេះមានរាប់បញ្ចូលករណីមួយដែលបុរសជាអ្នកបង្កហេតុការជះទឹកអាស៊ីត តែគេជឿថាគាត់បានជួលស្ត្រីម្នាក់អោយជះទឹកអាស៊ីតនេះជំនួសគាត់ទៅវិញ ។

ប្តីវាយប្រហារលើប្រពន្ធ ឬអតីតប្រពន្ធរបស់ខ្លួន ជាប្រភេទនៃការវាយប្រហារដែលកើតឡើងញឹកញាប់បន្ទាប់ពីប្រភេទដូចពោលខាងលើ ។ ប្តីប្រភេទនេះច្រើនតែធ្លាប់មានប្រវត្តិវាយដំ ច្រំធាក់ ធ្វើបាបប្រពន្ធខ្លួន ។ ប្តីជះទឹកអាស៊ីតលើប្រពន្ធ ដើម្បីជាទណ្ឌកម្មដល់អ្វីដែលប្រពន្ធបានធ្វើ ឬដោយសារការចែកផ្លូវ ឬលែងលះគ្នា ។ ឧទាហរណ៍ ជនរងគ្រោះម្នាក់ជាស្ត្រីដែលព្យាយាមលែងលះប្តីរបស់នាង ដោយសារប្តីនោះបានវាយធ្វើបាបនាង និងបានចាប់រំលោភនារីម្នាក់នៅក្នុងភូមិ ។ ប្តីនាងចោទប្រកាន់នាងថាមានសហាយ ហើយបានកាន់កាំភ្លើងដេញតាមនាង រួចជះទឹកអាស៊ីតដាក់លើមុខរបស់នាង ។ មានករណីមួយទៀត បុរសម្នាក់ជះទឹកអាស៊ីតលើប្រពន្ធរបស់ខ្លួនក្រោយពីប្រពន្ធនោះមិនព្រមអោយលុយ ៥០០ រៀលទៅប្តីនោះ ដើម្បីយកមកទិញបារីជក់ ហើយប្រពន្ធនោះថែមទាំងរារាំងប្តីនោះមិនអោយវាយកូនប្រុសរបស់ពួកគេទៀតផង ។

មានករណីមួយគឺប្តីមុនដែលបានលែងលះគ្នាហើយ បានជះទឹកអាស៊ីតលើប្តីក្រោយរបស់ប្រពន្ធខ្លួន ។

**ចំណងអាពាហ៍ពិពាហ៍កាត់ផ្តាច់ដោយសារទឹកអាស៊ីត**

*ចិន្តា[7] មានអាយុ១៦ឆ្នាំនៅពេលដែលម្តាយឪពុករបស់នាងបានអោយនាងរៀបការជាមួយបុរសម្នាក់ដែលជានាយទាហានមានឋានៈថ្នាក់វរសេនីយ៍ឯកនៃក្រសួងការពារជាតិហើយគាត់មានអាយុជាង ៥០ឆ្នាំ ។*

*លោកនាយទាហាននោះបានយល់ព្រមសង់ផ្ទះមួយខ្នងអោយនាងលើដីរបស់ក្រុមគ្រួសារនាង ហើយលោកនាយទាហានក៏នឹងមករួមរស់ជាមួយនាងចិន្តាក្នុងផ្ទះនេះជាមួយម្តាយឪពុករបស់នាងដែរ ។ លោកថែមទាំងបាននិយាយទៀតថា លោកនឹងមើលថែទាំនាងចិន្តាលុះគ្រាអវសាន្ត ហើយនឹងសន្យាថានឹងស្វះស្វែងរកគ្រូពេទ្យល្អៗមកព្យាបាលភ្នែកម្តាយនាងចិន្តា ដើម្បីអោយម្តាយកូនបានមើលឃើញគ្នាឡើងវិញទៀតផង ។*

*ក្រោយពីពួកគេបានរៀបការហើយប្រសូត្របានបុត្រាមួយ លោកនាយទាហានជាប្តីនោះបានប្រព្រឹត្តមិនគួរគប្បីជាច្រើនមកលើរូបនាង និងក្រុមគ្រួសារ ។ បុរសនោះបានជេរប្រទេចផ្តាសានាង ហើយជួនកាលទៀតមិនអនុញ្ញាតអោយនាងបានជួប ឬបំបៅកូននាងឡើយ ។ បុរសជាប្តីនោះប្រច័ណ្ឌនាងខ្លាំងណាស់ គាត់ជេរប្រទេចផ្តាសានាងនៅពេលណាដែលគាត់ឃើញនាងនិយាយទៅកាន់អ្នកក្រៅ ឬនាងត្រឡប់មកពីផ្សារយឺតយូរជាងសព្វមួយដង ។ មាយាទអាក្រក់របស់គាត់ចេះតែបន្តអស់រយៈកាលជាច្រើនឆ្នាំមកទល់ឆ្នាំ ២០០០ ដែលពេលនេះពួកគេរៀបការរួមរស់ជាមួយគ្នាអស់រយៈពេលបួនឆ្នាំ គាត់បានក្លាយទៅជាមនុស្សកំរោលចូលខ្លាំងឡើងៗ ។ គាត់បានគំរាមកំហែងដោយប្រើពាក្យសំដីថាបំផ្លាញសម្ផស្សនាងចិន្តាជាច្រើនលើកច្រើនសារ នឹងជួលគេអោយមកធ្វើបាបនាងទៀតផង ពាក្យគំរាមកំហែងរបស់គាត់ត្រូវបានឪពុកម្តាយ និងអ្នកជិតខាងរបស់នាងចិន្តាដឹងឮជារឿយៗ ។*

*ដោយមានការភ័យខ្លាចបារម្ភដល់សុវត្ថិភាពរបស់នាងចិន្តា ថ្ងៃមួយឪពុកម្តាយរបស់នាងបានចាក់សោរទ្វាររបងមិនអោយប្តីនាងចូលផ្ទះបាន ។ បុរសជាប្តីនោះបានឆ្លើយតបចំពោះហេតុការនេះដោយការដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីសុំលែងលះនាងនឹងសុំចែកទ្រព្យសម្បត្តិគ្នា ។*

---

[7] នេះមិនមែនជាឈ្មោះពិតរបស់នាងឡើយ តែជាឈ្មោះប្រឌិតដើម្បីលាក់អត្តសញ្ញាណពិតរបស់នាង ។

*ពីរបីសប្តាហ៍ក្រោយមក មានបុរសវ័យក្មេងពីរនាក់ជះទឹកអាស៊ីតលើនាងចិន្តានៅខណៈពេលដែលនាងកំពុងជិះកង់មកផ្ទះជាមួយប្អូនស្រីរបស់នាង ។ នាងចិន្តាមានអារម្មណ៍ឆេះក្តៅរោលរាលលើផ្ទៃមុខនឹងបរិវេណជុំវិញភ្នែករបស់នាង សម្លៀកបំពាក់របស់នាងចាប់ផ្តើមផុយជ្រុះ ហើយទឹកអាស៊ីតខ្លះបានខ្ទាតទៅប៉ះខ្នង និងស្មារបស់ប្អូនស្រីនាង ។ បងប្អូនពីរនាក់នេះបានរត់ចូលផ្ទះអ្នកភូមិនៅក្បែរនោះដើម្បីជុសលាងខ្លួន សំអាតទឹកអាស៊ីតរួចហើយរួសរាន់ទៅកាន់មន្ទីរពេទ្យជាបន្ទាន់ ។ នាងចិន្តាបានសំរាកពេទ្យ៣ថ្ងៃ ហើយចំណាយពេលអស់ជាច្រើនសប្តាហ៍ទៀតដើម្បីអោយស្នាមរបួសនាងបានជាសះស្បើយ ។ តែទោះជាយ៉ាងនេះក៏ដោយ នាងមានសំណាងល្អដោយសារអាស៊ីតនោះជាប្រភេទអាស៊ីតចាក់អាគុយ ដែលវាជាអាស៊ីតខ្សោយត្រូវបានគេលាយទឹកច្រើនភាគរយ ។ នាងមិនពិការភ្នែកទេ ឯផ្ទៃមុខរបស់នាងវិញបានបន្សល់ទុកនូវស្លាកស្នាមអុចៗ តែមិនមែនជាស្នាមធំ ឬការខូចទ្រង់ទ្រាយមុខគួរអោយខ្លាចនោះទេ ។ ប្រសិនបើ អាស៊ីតដែលគេជះមកលើនាងនោះជាទឹកអាស៊ីតខ្លាំងវិញនោះម៉្លេះសមនាងទទួលរងគ្រោះធ្ងន់ធ្ងរជាងនេះដែល មិនអាចប៉ាន់ស្មានបានផងក៏មិនដឹង ។*

*ដប់ថ្ងៃក្រោយពីការវាយប្រហារនេះមក នៅក្នុងខណៈពេលដែលមុខរបស់នាងចិន្តានៅរលាក និងមានការឈឺចាប់នៅឡើយ តុលាការខេត្តបានបើកសវនាការសំរេចក្តីសុំលែងលះរបស់ប្តីនាង ហើយនឹងបានសំរេចអោយប្តីនាង មើលថែទាំកូនប្រុសអាយុបីឆ្នាំរបស់គេនោះ ។ តុលាការក៏បានសំរេចអោយប្តីរបស់នាងមករស់នៅផ្ទះរបស់ពួកគេនោះវិញ ដោយអោយប្តីនាងនៅជាន់ខាងលើ ឯចិន្តានិងឪពុកម្តាយរបស់នាងរស់នៅជាន់ក្រោម ។ ប្តីនាងបានត្រឡប់មករស់នៅក្នុងផ្ទះនោះវិញ ហើយកូនប្រុសរបស់គេក៏បានទៅរស់នៅជាមួយខាងប្តីដែរ ។*

*ចិន្តា និងឪពុកម្តាយរបស់នាងបានដាក់ពាក្យប្តឹងអំពីករណីជះទឹកអាស៊ីតលើនាងចិន្តា ប៉ុន្តែគ្មានអ្នកណាម្នាក់ត្រូវបានឃាត់ខ្លួននោះឡើយ ។ ចិន្តា និងឪពុកម្តាយរបស់នាងមិនដែលឃើញមានប៉ូលីសណាម្នាក់មកសួរនាំប្តីនាងឡើយ ទោះជាប្តីនោះធ្លាប់បានគំរាមថាជួលគេអោយមកធ្វើបាបនាងក៏ដោយ ។ ក្នុងឆ្នាំ ២០០១ សាលាក្តីឧទ្ធរណ៍បានសវនាការសំរេចអោយនាងចិន្តាជាអ្នកគ្រប់គ្រងកូនប្រុសនាង ហើយអោយនាងជាកាន់កាប់ផ្ទះទាំងមូល ។ ប្តីរបស់នាងបានប្តឹងតវ៉ាទៅតុលាការកំពូល ដែលមកទល់នឹងពេលនេះមិនបានសំរេចរឿងក្តីនេះនៅឡើយទេ ។ តែប្តីនោះបានចុះចេញពីផ្ទះទៅរស់នៅជាមួយប្រពន្ធថ្មីម្នាក់ទៀត ហើយបាននាំយកកូនប្រុសនោះទៅជាមួយផងដែរ ។ នាងចិន្តាក៏លែងបានឃើញមុខកូននាងតាំងពីពេលនោះរៀងរហូតមកហើយ នាងមិនដឹងថាពេលណាទើបនាងបានជួបមុខកូនប្រុសរបស់នាងជាថ្មីឡើងវិញនោះ ។*

ករណីស្ត្រីជះទឹកអាស៊ីតលើប្តីរបស់ពួកនាងរួមមាន ករណីមួយនោះប្រពន្ធសង្ស័យថាប្តីមានស្រី និងមួយករណីទៀតដោយសារប្រពន្ធមានកំហឹងលើប្តី ពីព្រោះមានបំណងលែងលះជាមួយនាង ។ ក្នុងករណីមួយទៀត ស្ត្រីម្នាក់ដែលបានលែងលះជាមួយប្តីនាងរួចរាល់ហើយ ដែលក្រោយមកនាងនោះបានជះទឹកអាស៊ីតលើស្ត្រីម្នាក់ទៀតដែលសង្ស័យថាជាមិត្តស្រីថ្មីរបស់អតីតប្តីនាង ។

មានករណីចំនួន៤ ដែលជនរងគ្រោះជះទឹកអាស៊ីតលើជនប្រព្រឹត្តអំពើហឹង្សាក្នុងគ្រួសារ ៖ មានស្ត្រីរៀបការបីនាក់ហើយដែលបានជះទឹកអាស៊ីតលើប្តីរបស់ពួកនាងដែលតែងតែវាយដំច្រំធាក់នាង ហើយនឹងមាន

មួយករណីទៀតស្ត្រីវ័យក្មេងម្នាក់បានជះទឹកអាស៊ីតលើឪពុកចុងរបស់នាងដែលតែងតែវាយធ្វើបាប នឹងប៉ុនប៉ងចាប់រំលោភនាង ។

## អំពើហិង្សាក្នុងគ្រួសារឈាននៅការជះទឹកអាស៊ីត

*យោធារំសាយម្នាក់អាយុ៣៣ឆ្នាំ តែងតែវាយដំប្រពន្ធគាត់ជារឿយៗ នៅក្នុងផ្ទះរបស់គាត់នៅខេត្តកណ្តាល ។ គាត់គ្មានមុខរបរណាមួយពិតប្រាកដដើម្បីរកបានប្រាក់ចំណូលមកចិញ្ចឹមប្រពន្ធ និងកូនស្រីតូចមួយរបស់គាត់ឡើយ តែគាត់មានប្រាក់កាសសំរាប់សេពសុរាស្រវឹងរាល់ថ្ងៃនឹងមានលុយសំរាប់លេងល្បែងស៊ីសងទៀតផង ។ រាល់ពេលដែលគាត់ស្រវឹងគាត់តែងតែស្រែកឡូឡាជេរនឹងវាយធ្វើបាបប្រពន្ធកូនរបស់គាត់ ។ វាទៅជារឿងធម្មតាទៅហើយដែលគាត់តែងតែលើកដៃវាយទះតប់ និងលើកជើងទាត់ធាក់ ហើយជួនកាលទៀតយកដំបងវាយប្រពន្ធគាត់ ហើយថែមទាំងបោកកំទេចទ្រព្យសម្បត្តិក្នុងផ្ទះទៀតផង ។ អ្នកភូមិផងរបងជាមួយជុំវិញផ្ទះរបស់បុរសនោះ និងអាជ្ញាធរមូលដ្ឋានសុទ្ធតែបានដឹងឮរឿងនេះគ្រប់ៗគ្នាថា បុរសនេះតែងតែវាយដំច្រំធាក់ប្រពន្ធនឹងបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះរៀងរាល់ពេលដែលគាត់ស្រវឹងស្រា ។ ប្រពន្ធគាត់ក៏បានសំរេចចិត្តទុកអាស៊ីតមួយលីត្រនៅក្នុងផ្ទះ ដើម្បីជាអាវុធសំរាប់ការពារខ្លួននាង ។ នាថ្ងៃមួយក្នុងឆ្នាំ ២០០០ ប្តីរបស់នាងបានវាយដំ ទាត់ធាក់នាងយ៉ាងខ្លាំងក្លា ព្រមទាំងយកដំបង និងកាំបិតមកវាយនាងថែមទៀតផង ។ សាច់ញាតិនាង និងអ្នកភូមិជិតខាងក្បែរៗផ្ទះនោះបាននាំគ្នាចោមរោមមើលប្តីនាងធ្វើបាបនាងតែគ្មានអ្នកណាម្នាក់ហ៊ានចូលជួយនាងឡើយ ។ ទ្រាំទៀតមិនបាននាងជាប្រពន្ធក៏បានរត់សំដៅទៅរកទឹកអាស៊ីតដែលនាងបានលាក់ទុកនោះយកមកជះដាក់ប្តីរបស់នាងទៅ ។ ទឹកអាស៊ីតនោះបានស៊ីដាច់ផ្ទៃមុខបុរសជាប្តីនោះយ៉ាងធ្ងន់ធ្ងរដោយបានបំផ្លាញភ្នែកម្ខាង និងផ្នែកខ្លះនៃច្រមុះរបស់គាត់យ៉ាងធ្ងន់ធ្ងរ ។ នាក្នុងគ្រានោះដែរ ទឹកអាស៊ីតខ្លះបានខ្ទាតទៅត្រូវសម្លៀកបំពាក់សាច់ញាតិខាងប្រពន្ធក្នុងនោះមានទាំងម្តាយបង្កើត និងក្មួយស្រីរបស់នាងផងដែរ ។ ប៉ូលីសបានចាប់ឃាត់ខ្លួនស្ត្រីជាប្រពន្ធទៅកាន់ប៉ុស្តិ៍ប៉ូលីស រួចបញ្ជូនទៅតុលាការ នាងបានបំភ្លឺប្រាប់ប៉ូលីសថា នាងគ្រាន់តែចង់ផ្តល់មេរៀនខ្លះៗដល់ប្តីរបស់នាង ដើម្បីកុំអោយថ្ងៃក្រោយគាត់វាយធ្វើបាបនាងទៀត ។ នាងជាប្រពន្ធនោះ ត្រូវបានតុលាការកាត់ទោសអោយជាប់ពន្ធនាគារបួនឆ្នាំ ឯប្តីរបស់នាងវិញមិនត្រូវបានប៉ូលីសសួរនាំពីការដែលវាយដំ ធ្វើបាបប្រពន្ធរបស់គាត់ឡើយ ។*

ក្នុង៥ករណីផ្សេងទៀត មូលហេតុដែលជំរុញអោយជនដៃដល់ជះទឹកអាស៊ីតនោះមិនត្រូវបានកាសែតរាយការណ៍អោយបានច្បាស់លាស់នោះទេ តែទំនងមើលទៅហាក់ដូចជាការវាយប្រហារនោះ កើតចេញមកអំពីបញ្ហាប្រច័ណ្ឌ ឬគំនុំចេញពីសម្ព័ន្ធភាព ។ ឧទាហរណ៍ គូសង្សារវ័យក្មេងមួយគូត្រូវបានគេជះទឹកអាស៊ីតដាក់ក្នុងខណៈពេលដែលពួកគេកំពុងជិះម៉ូតូជឹកគ្នា ក្រោយពីពួកគេបានភ្ជាប់ពាក្យនឹងគ្នារួចមក ។ ករណីមួយទៀត គឺជាការវាយប្រហារទៅលើស្ត្រីវ័យក្មេងម្នាក់ដែលនាងបានពាក់ព័ន្ធមេត្រីភាពនឹងមន្ត្រីរាជការថ្នាក់ខ្ពស់ល្មមម្នាក់ដែលមានប្រពន្ធរួចទៅហើយ ឯរូបនាងផ្ទាល់វិញត្រូវបានប្រុសកម្លោះៗជាច្រើនតាមសុំសេចក្តីស្នេហាមិនឈប់ឈរ តែនាងពុំដែលបានយល់ព្រមចំពោះសំណើរទាំងនោះឡើយ ។

មាន ៦ ករណីនៃការជះទឹកអាស៊ីតត្រូវបានធ្វើឡើងដោយហេតុផលខុសគ្នាផ្សេងពីខាងលើ ដែលមិនមានការពាក់ព័ន្ធនឹងចំណងគ្រួសារ ឬសម្ព័ន្ធភាពប្រុសស្រីអ្វីទាំងអស់ ។ ករណីទាំងនេះរួមមាន :

- នាយប៉ងម៉ឹតមួយ បុរសម្នាក់បានជះទឹកអាស៊ីតទៅលើអ្នកជិតខាងរបស់គាត់ដោយសារតែពួកគេបានទាស់ទែងនឹងគ្នាអំពីរឿងកង់ តែទឹកអាស៊ីតនោះបែរជាទៅប៉ះត្រូវមនុស្សផ្សេងទៅវិញ ។
- ប្រធានពុទ្ធិកសមាគមម្នាក់បានជះទឹកអាស៊ីតទៅលើព្រះសង្ឃ ដែលបង្កអោយមានរបួសស្រាលដល់ព្រះសង្ឃមួយអង្គ ដោយសារតែមានទំនាស់ពីរឿងទ្រព្យសម្បត្តិក្នុងវត្ត ។
- ករណីពីរទៀតគេជឿថាជាអំពើចោរប្លន់យកម៉ូតូពីជនរងគ្រោះ ។ ករណីទាំងពីរនេះ ជនដៃដល់បានគេចរួចខ្លួនដោយមិនបានយកម៉ូតូទៅជាមួយឡើយ ដោយសារជនរងគ្រោះមានការឈឺចាប់ខ្លាំងពេកស្រែកទ្រហោអោយគេជួយ ហើយអ្នកភូមិក៏រត់ចេញឈូឆរមកជួយទាន់ពេលវេលា ។

## ■ របួសស្លាកស្នាមដែលជនរងគ្រោះទទួលបានដោយការលោកទឹកអាស៊ីត

យ៉ាងហោចណាស់ក៏មានជនរងគ្រោះដោយទឹកអាស៊ីតបីនាក់បានស្លាប់ ដែលអ្នកទាំងនេះបានស្លាប់ក្នុងពេលដែលទទួលរងទឹកអាស៊ីត ឬពីរ-បីម៉ោងក្រោយពីការរងការវាយប្រហារដោយទឹកអាស៊ីតមក :

- ស្រ្តីម្នាក់អាយុ ៣៣ឆ្នាំរស់នៅក្នុងខេត្តកំពង់ចាម ត្រូវបានទទួលរងទឹកអាស៊ីតជះដោយស្រ្តីម្នាក់ទៀតដែលបានលែងលះជាមួយប្តីរបស់គាត់ ហើយដែលស្រ្តីដៃដល់ជឿថាអតីតប្តីរបស់គាត់មានទំនាក់ទំនងជាមួយស្រ្តីរងគ្រោះ ។
- បុរសអាយុ ៣៤ឆ្នាំម្នាក់រស់នៅក្នុងខេត្តព្រៃវែង ត្រូវបានប្រពន្ធរបស់គាត់យកអាស៊ីត ១លីត្រមកចាក់ពីលើគាត់ ដោយសារគាត់បានវាយដំប្រពន្ធរបស់គាត់ព្រមទាំងម្តាយក្មេក ។
- បុរសអាយុ៣៥ឆ្នាំ ម្នាក់រស់នៅក្នុងខេត្តកំពង់ចាម ដែលបានយកច្រវាក់មកវាយលើក្បាលប្រពន្ធរបស់គាត់ ។ នៅពេលដែលប្រពន្ធនោះចេញពីមន្ទីរពេទ្យក្រោយពីសំរាកព្យាបាលខ្លួននាងក៏យកទឹកអាស៊ីតមកចាក់លើខ្លួនប្តីរបស់នាងវិញ ។

មានមនុស្ស ៦០ នាក់ទៀតបានទទួលរងគ្រោះដោយសារទឹកអាស៊ីត ដែលយ៉ាងហោចណាស់ក៏មាន ៣៩នាក់ក្នុងចំណោមមនុស្សខាងលើបានទទួលរងគ្រោះធ្ងន់ធ្ងរលើផ្ទៃមុខ លើខ្លួនប្រាណ និងដៃជើងរបស់ពួកគេ ។ អ្នករងរបួសលើផ្ទៃមុខ ភាគច្រើនជាស្រ្តីភេទ ។ យ៉ាងហោចណាស់ក៏មានមនុស្សបួននាក់បានពិការភ្នែកម្ខាង ឬទាំងសងខាង ហើយមនុស្ស ១១នាក់ទៀតបានទទួលគ្រោះថ្នាក់ដល់ភ្នែក ដែលគេមិនបានដឹងថាពួកគេទាំងនោះពិការភ្នែកជារៀងរហូតដែរឬក៏អត់ទេ ព្រោះសារពតិមានមិនបានរាយការណ៍បញ្ជាក់អោយបានច្បាស់លើចំណុចនេះ ។

# ៤ ~ ផលប៉ះពាល់លើរាងកាយជនរងគ្រោះដោយការលោកទឹកអាស៊ីត

ការរលាកដោយសារទឹកអាស៊ីតបានស៊ីជារបួសមួយ ដែលមានការឈឺចុកចាប់បំផុតដល់ខ្លួនប្រាណមនុស្សលោកយើងនេះ ។ ផ្ទៃមុខ និងខ្លួនប្រាណជនរងគ្រោះត្រូវបានទទួលទារុណ្ណកម្មពីទឹកអាស៊ីតដែលជាទារុណ្ណកម្មនេះបន្សល់ទុកនូវស្លាកស្នាមដ៏គួរអោយខ្លាច ហើយបានប្តូរភិនភាគរូបរាងជាមនុស្សរបស់ពួកគេអស់មួយជីវិត ។ ការពិការភ្នែក និងភាពថ្លង់គក៏អាចនឹងកើតមានផងដែរ ដោយសារជនដៃដល់តែងតែជះទឹកអាស៊ីតតំរង់ទៅរកផ្នែកក្បាលនៃជនរងគ្រោះជានិច្ច ។

ជនរងគ្រោះឆ្លងកាត់ការឈឺចាប់ ខ្សោះកំលាំងក្នុងខ្លួនរយៈពេលយូរមុននឹងខ្លួនបានជាសះស្បើយពីស្នាមរបួសនោះ ការដែលទឹកអាស៊ីតស៊ីរលាកចូលទៅជ្រៅក្នុងសាច់ ធ្វើអោយមានការលំបាកក្នុងដំណើរជាសះស្បើយនឹងត្រូវប្រឈមជាមួយការងាយឆ្លងមេរោគផ្សេង១ ព្រមទាំងងាយរងគ្រោះដោយបញ្ហាផ្សេង១ទៀតផងដែរ ។ ជាធម្មតាជនរងគ្រោះត្រូវចំណាយពេលវេលាជាច្រើនសប្តាហ៏ ឬខែសំរាកព្យាបាលខ្លួនក្នុងមន្ទីរពេទ្យ រហូតទាល់តែស្លាកស្នាមរបួសពួកគេបានជាសះស្បើយនឹងការប្រឈមមុខការឆ្លងមេរោគផ្សេង១តាមស្នាមមុខរបួសដែលមិនអាចកើតមានតទៅទៀតបាន ។ ស្ទើតែពួកគេទាំងអស់អាចនឹងត្រឡប់មកកាន់មន្ទីរពេទ្យវិញជាច្រើនលើកច្រើនសារ ដើម្បីព្យាបាលបន្ថែម ឬធ្វើការវះកាត់ច្រើនឆ្នាំបន្តទៀត ។

ដោយសារជំនាញវេជ្ជសាស្ត្រ និងឧបករណ៏ពេទ្យក្នុងប្រទេសកម្ពុជាមានភាពខ្សត់ខ្សោយ ជាហេតុបណ្តាលអោយមហន្តរាយធ្ងន់ធ្ងរដែលរលាកមកពីទឹកអាស៊ីតមិនអាចធ្វើអោយបានប្រសើរទាំងស្រុងឡើយ ។ ជនរងគ្រោះនឹងមិនអាចវិលទៅរករូបរាងដើមរបស់គេបានឡើយ ទោះបីជាក្រោយពីការព្យាបាលសះស្បើយហើយក៏ដោយ ។ ជនរងគ្រោះ ត្រូវបង់ថ្លៃដើម្បីទទួលបាននូវការព្យាបាលវេជ្ជសាស្ត្រ ។ គុណភាពនៃការព្យាបាលវិញ គឺវាអាស្រ័យតែនឹងទឹកប្រាក់ដែលជនរងគ្រោះមាន ។ ដោយសារការព្យាបាលនៅតាមមន្ទីរពេទ្យមានតំលៃខ្ពស់ ហេតុនេះបានធ្វើអោយជនរងគ្រោះមួយចំនួនមកសម្ងំព្យាបាលរបួសរបស់គេនៅតាមផ្ទះផ្ទាល់ខ្លួន ឬទៅព្យាបាលនៅតាមគ្លីនិកជិត១ផ្ទះ ឬទៅរកគ្រូខ្មែរព្យាបាលអោយវិញ ។

## ■ ស្លាមរបួស

ទឹកអាស៊ីតស៊ីស្បែក និងសាច់ម្តងមួយស្រទាប់១ ដែលបណ្តាលអោយមានការចុកចាប់ពើតផ្សាក្រៃលែង។ ទឹកអាស៊ីតវាស៊ីទំលុះស្បែកទាំងពីរស្រទាប់ ចូលទៅក្នុងស្រទាប់ខ្លាញ់ និងសាច់ដុំនៅពីក្រោមស្បែក ហើយជួនកាលទៀតវាស៊ីចូលរហូតទៅដល់ឆ្អឹងទៀតផង ។ ឯជំរៅស្នាមរបួសវិញ គឺវាអាស្រ័យលើប្រភេទកំឡាំងអាស៊ីតនឹងរួមផ្សំរយៈពេលដែលអាស៊ីតបានប៉ះពាល់ស្បែកផង - ការឆេះរលាកនៃអាស៊ីតនឹងឈប់នៅពេលណាដែលគេបានប្រើទឹក ឬទឹកលាយសាប៊ូមកដុសលាងសំអាតជាតិអាស៊ីតនោះចេញ។

នៅពេលដែលទឹកអាស៊ីតត្រូវបានគេជះមកប៉ះផ្ទៃមុខភ្លាម ទឹកអាស៊ីតនោះបានស៊ីចូលទៅក្នុងភ្នែក ត្រចៀក ច្រមុះ និងមាត់យ៉ាងលឿន ។ ឯការឈឺចាប់វិញគឺមានទំហំមិនអាចគណនាបានឡើយ ប្រៀបបីដូចជាកាំបិតដែលគេដុតរាប់រយអង្សាហើយយកមកចាក់ចូលទៅក្នុងសាច់អញ្ចឹង ។ ត្របកភ្នែក និងបបូមាត់អាចនឹងត្រូវឆេះដាច់បាត់ទាំងស្រុង ។ ច្រមុះអាចនឹងរលាយជិតទន្ទអស់ ឯត្រចៀកវិញអាចរួញស្វិតតូច ។ អាស៊ីតអាចស៊ីបំផ្លាញភ្នែកយ៉ាងលឿនដែលអាចធ្វើអោយជនរងគ្រោះពិការភ្នែកបានយ៉ាងងាយ ។ ស្បែកនៃឆ្អឹងក្បាល ថ្ងាស់ ថ្ពាល់ និងចង្កាអាចរលាយចូលគ្នា ។ ដូចជាផ្ទៃមុខអញ្ចឹងដែរ ទឹកអាស៊ីតដែលតែងតែស្រក់លើដងក ដើមទ្រូង ខ្នង និងអវៈយវៈដៃ ឬជើង ហើយទឹកអាស៊ីតនេះស៊ីផ្តាច់ ឬស៊ីចូលជ្រៅដល់ទីណានៃសរីរាង្គជនរងគ្រោះ ។

គ្រោះថ្នាក់ធំបំផុតសំរាប់ជនរងគ្រោះនោះគឺការមិនអាចដកដង្ហើមបាន ។ ការស្រូបយកចំហាយអាស៊ីតចូលទៅក្នុងសួតអាចបណ្តាលអោយមានបញ្ហាពីរ : វាធ្វើអោយមានប្រតិកម្មជាតិពុលនៅក្នុងសួត ឬធ្វើអោយរលាកហើមបំពង់កដែលធ្វើអោយផ្លូវដកដង្ហើមរួមតូចហើយបន្ថប់ផ្លូវដកដង្ហើមជនរងគ្រោះ ។ ជនរងគ្រោះជនជាតិខ្មែរម្នាក់បានស្លាប់ដោយសារអាស៊ីតហូរចូលតាមច្រមុះមកក្នុងបំពង់ផ្លូវដកដង្ហើមគាត់ ។

ប៉ុន្តែជាទូទៅ ជនរងគ្រោះមិនស្លាប់ទេ ។ គោលបំណងនៃការវាយប្រហារទឹកអាស៊ីតភាគច្រើនគឺមិនមែនដើម្បីសំលាប់ជនរងគ្រោះឡើយ តែធ្វើអោយពិការនឹងបំផ្លាញរូបសម្ផស្សជនរងគ្រោះ ។ ជនដៃដល់ចង់អោយជនរងគ្រោះរស់នៅដោយមានមុខមាត់អាក្រក់ដូចបិសាចនឹងត្រូវទទួលរងឈឺចាប់ឥតស្រាកស្រាន្តអស់មួយជីវិត ។

## ផលវិបាកខាងផ្លូវកាយនៃការរលាកទឹកអាស៊ីត

*ដោយសារមុខរបួសនៃការរលាកដោយទឹកអាស៊ីតបានបង្កអោយមានក្រមរយ៉ាងក្រាស់ ហើយប្រទាញស្បែកដ៏ទៃទៀតអោយតឹងបណ្តាលអោយខូចទ្រង់ទ្រាយស្បែកសភាពដើមយ៉ាងធ្ងន់ធ្ងរ ។ ឧទាហរណ៍-ការទាញស្បែកត្របកភ្នែកមិនអាចបិទបាន មិនអាចបើកមាត់រយៈពេលយូរ ស្បែកចង្កាប្រទាញជាប់ទៅនឹងដើមទ្រូង ។*

*ពត៌មានខាងក្រោមនេះ ទទួលបានមកអំពីអង្គការក្រៅរដ្ឋាភិបាលនៃអង្គការគ្រូពេទ្យពិភពលោកបំរើការងារនៅមន្ទីរពេទ្យកាល់ម៉ែត្រនាទីក្រុងភ្នំពេញ ។*

***ក្បាល :*** *អាចនឹងត្រូវបានបំផ្លាញផ្នែកខ្លះៗ ឬត្រូវប្តូរទ្រង់ទ្រាយ ។ ឯសក់អាចលែងដុះមកវិញ ។*

***ថ្ងាស់ :*** *ស្បែកអាចជ្រួញ ដូចគេចាប់ទាញមួយទំហឹង ហើយអាចមានសំលាក ។*

***ត្រចៀក :*** *រួញឡើង ហើយអាចធ្វើអោយខូចទ្រង់ទ្រាយ ។ ភាពថ្លង់អាចកើតមានភ្លាម១ ឬមួយរយៈពេលបន្តិចម្តង១ក្រោយមក ។ ឆ្អឹងត្រចៀកអាចត្រូវបំផ្លាញដោយផ្នែក ឬទាំងស្រុង ដែលអាចធ្វើអោយប្រហោងត្រចៀកងាយឆ្លងមេរោគ ឬស្តាប់អ្វីលែងឮ ។*

***ភ្នែក :*** *ការប៉ះពាល់អាស៊ីតផ្ទាល់ ឬចំហាយអាស៊ីតអាចធ្វើអោយខូចភ្នែក ឬបណ្តាលអោយខ្វាក់ ។ ទោះបីជា ភ្នែកបានរួចគេចផុតពីការវាយប្រហារក៏ដោយ ភ្នែកទាំងពីរនោះងាយទទួលរងគ្រោះថ្នាក់ផ្សេង១ទៀតក្នុងអំឡុងពេលនៃការព្យាបាលខ្លួនរបស់ជនរងគ្រោះ ។ ត្របកភ្នែកអាចនឹងត្រូវឆេះដាច់អស់ ឬធ្វើអោយខូចទ្រង់ទ្រាយដោយសំលាកប្រទាញត្របកភ្នែក ដែលធ្វើអោយគ្រាប់ភ្នែកងាយស្ងួតជាតិទឹកនឹងឈានទៅរកពិការភាព ។ ហេតុការនេះមិនងាយនឹងផ្តល់កិច្ចការពាភ្នែកបានទេ ។*

***ច្រមុះ :*** *រួញហើយខូចទ្រង់ទ្រាយ ។ រន្ធច្រមុះអាចនឹងរួញជិតទាំងស្រុង ដោយសារឆ្អឹងខ្ចីនៃច្រមុះត្រូវបានបំផ្លាញ ។*

***ថ្ពាល់ :*** *ជ្រីវជ្រួញនឹងខូចទ្រង់ទ្រាយទាំងស្រុង ។*

***មាត់ :*** *ជ្រីវជ្រួញនឹងស្វិតរួញតូច ហើយអាចបាត់រូបរាងដើមទាំងស្រុង ។ បបូរមាត់អាចនឹងត្រូវបានបំផ្លាញដោយផ្នែក ឬទាំងស្រុង ។ មាត់អាចនឹងសើយចេញធ្មេញមកក្រៅ ។ ចលនាបបូរមាត់មាត់ និងមុខអាចទទួលការខូចខាត ។ ការទទួលទានអាហារអាចជួបប្រទះការលំបាកច្រើន ។*

***ចង្កា :*** *មានសំលាកជ្រីវជ្រួញ ហើយធ្លាក់ចុះនឹងខូចទ្រង់ទ្រាយ ដូចជាចង្កានោះចង់ធ្លាក់ចុះក្រោមស្បែកចង្ការលាយចូលជាប់ដងក ឬដើមទ្រូង ។*

***ដងក:*** *តែងតែខូចខាតយ៉ាងធ្ងន់ធ្ងរ ។ វាអាចមានដុំសំលាកសាច់មួយភ្ជាប់ពីផ្នែកខាងក្រោមចង្កាទៅដើមទ្រូង ឬក៏មានសំលាកសាច់ដុះព័ទ្ធជុំវិញមួយចំហៀងក ជនរងគ្រោះជួនកាលមិនអាចងាកដងក ឬងាកដងកចុះឡើងបាន ឬជួនកាលទៀតក្បាលផ្អៀងជាប់ទៅមួយចំហៀងដោយសារការប្រទាញពីបន្ទះសំលាកសះនៃមុខរបួស ។*

***ដើមទ្រូង :*** *ជាទូទៅមានស្លាកស្នាមយ៉ាងក្រវេមក្រវ៉ាមប្រទាក់គ្នា ។ ដើមទ្រូងអាចនឹងមានស្នាមឆ្នូត១ តូច១ ឬធំបណ្តាលមកពីទឹកអាស៊ីតហូរកាត់ ឬស្រក់មកលើ ។ ចំពោះកុមារី និងស្ត្រីវ័យក្មេងវិញការវិវត្តនៃការលូតលាស់សុដនអាចនឹងឈប់មាន ឬជួនកាលសុដនរបស់គេត្រូវបានបំផ្លាញទាំងស្រុង ។*

***ស្មា :*** *អាចនឹងមានស្លាកស្នាមយ៉ាងអាក្រក់ ជាពិសេសនៅបរិវេណជុំវិញក្លៀក ដែលអាចធ្វើអោយជនរងគ្រោះពិបាកកំរើកដៃ ។ ជួនកាលទៀត ដើមដៃម្ខាង ឬដៃទាំងពីររបស់ជនរងគ្រោះជាប់គ្នាមកនឹងខ្លួនប្រាណប្រៀបបានដូចគេយកជ័រកាវមកបិតភ្ជាប់ ។*

## ▪ ការព្យាបាល

ការព្យាបាលជាដំបូងនោះគឺគេត្រូវតែយកទឹកមកលាងសំអាតបរិវេណសាច់ដែលរលាកអាស៊ីតអោយបានឆាប់យ៉ាងហោចណាស់ក៏ ៦០នាទីដែរ ដើម្បីលាងជំរះចោលអាស៊ីតនឹងបញ្ឈប់ការរលាកបន្ត ។

ការព្យាបាលបន្ទាន់ក្នុងមន្ទីរពេទ្យត្រូវមានទាំងការលាងសំអាត និងការរុំរបួស ហើយសំរួលបញ្ហាផ្លូវដកដង្ហើមដែលបណ្តាលមកពីចំហាយអាស៊ីត ។ វេជ្ជបណ្ឌិតអាចសំរេចធ្វើការវះកាត់បំពង់ក ឬដាក់បំពង់ទុយោទៅក្នុងបំពង់ក ដើម្បីជួយអោយជនរងគ្រោះអាចដកដង្ហើមបាន ។

វេជ្ជបណ្ឌិតត្រូវវះកាត់យកចេញនូវកំទេចកោសិកា ឬកោសិកាងាប់នៅជុំវិញរបួស ដូចជាសាច់នៅជាប់តាម ដងបំពង់ក ខ្នង ដើមទ្រូង ដៃ និងរហូតដល់មុខ ឬត្រចៀក ។ ដំបៅក្លាយជាគ្រោះថ្នាក់ដ៏ធំមួយសំរាប់ជនរងគ្រោះ ដោយសារកោសិកាងាប់នៅជុំវិញបរិវេណរបួសធ្ងន់ៗអាចនឹងងាយឆ្លងមេរោគបាន ។ ការឆ្លងមេរោគទៅជាដំបៅរលួយក្លាយ អាចរារាំងមិនអោយរបួសអាចជាសះស្បើយបានឆាប់ ហើយថែមទាំងធ្វើអោយមានដំបៅរីករាលដាលទៅបរិវេណកោសិកាល្អ ដែលអាចធ្វើអោយជនរងគ្រោះស្លាប់បាន ។ ដំបៅរលួយក្លាយអាចសំលាប់ជនរងគ្រោះពេលណាមួយក៏បានក្នុងរយៈកាលនៃការព្យាបាល ដើម្បីអោយបានសះស្បើយពីការរលាកទឹកអាស៊ីតនេះ ។ គេត្រូវចាំបាច់ថែទាំរបួសអោយបានស្អាតជានិច្ច ហើយនឹងប្រើថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីប្រឆាំងការរីកឆ្លងរាលដាល ។ ហើយប្រសិនបើ ដំបៅរលួយរីករាលដាលធំឡើងៗនោះ វេជ្ជបណ្ឌិតអាចសំរេចថានឹងធ្វើការវះកាត់យកសាច់រលួយចេញបន្ថែមទៀត ។

វេជ្ជបណ្ឌិតត្រូវធ្វើការវះកាត់យកស្រទាប់ស្បែកពីកន្លែងដ៏ទៃនៃផ្នែករាងកាយជនរងគ្រោះ ដើម្បីយកមកប៉ះភ្ជិតលើទីកន្លែងដែលរងរលាកធំៗ ជាទូទៅគេតែងតែវះកាត់ពីសាច់ស្បែកភ្លៅ ។ ការរលាកធំៗហើយជ្រៅ មិនងាយសះស្បើយដោយឯកឯងទេ វិធីវះកាត់ផ្សាំស្បែក គឺជាមធ្យោបាយជួយបិតភ្ជិតមុខរបួសការពារដំបៅរលួយរាលដាលនឹងជួយអោយមុខរបួសងាយសះស្បើយឆាប់រហ័ស ។ វិធីវះកាត់ផ្សាំស្បែកមានអាការៈរមាស់ ឈឺចាប់នៅពេលដំណើរការសះស្បើយនៃផ្នែកស្បែកផ្សាំនេះ ។

ការរលាកជារបួសមួយដែលមានការឈឺចាប់បំផុតដល់មនុស្ស ហេតុនេះថ្នាំបំបាត់ការឈឺចាប់មានសារៈសំខាន់ណាស់ ។ ជួនកាលបំបៅដែលបណ្តាលមកពីអាស៊ីតស៊ីចូលជ្រៅនោះគ្មានការឈឺចាប់ទេ ដោយសារសរសៃប្រសាទនៅទីនោះត្រូវបានបំផ្លាញ តែបរិវេណជុំវិញមុខរបួសនោះមានការឈឺចាប់ខ្លាំងណាស់ ។ ជំហាននិមួយៗនៃការព្យាបាល ពោលគឺពីការលាងសំអាតរបួស ឬឈានទៅដល់ការវះកាត់អាចបណ្តាលអោយមានការចុកចាប់ខ្លាំងឡើងៗ ។

វេជ្ជបណ្ឌិតត្រូវតែយកចិត្តទុកដាក់ជាពិសេសក្នុងការជួយសង្គ្រោះភ្នែក ច្រមុះ មាត់ នេះបើយោងតាមដំបូន្មានវេជ្ជបណ្ឌិតរបស់អង្គការគ្រូពេទ្យពិភពលោកដែលបានផ្តល់ការព្យាបាលដល់ជនរងគ្រោះដោយទឹកអាស៊ីតនៅមន្ទីរពេទ្យកាល់ម៉ែត្រនាទីក្រុងភ្នំពេញ។ គេអាចស៊កឧបករណ៍នៅចន្លោះបបូរមាត់ ដើម្បីអោយមាត់បើកចំហរក្នុងរូបរាងធម្មតារបស់មាត់ នឹងស៊កបំពង់តូចមួយចូលតាមរន្ធច្រមុះដើម្បីការពារវាកុំអោយជិត

រន្ធច្រមុះ ។ ភ្នែកងាយឆ្លងមេរោគនឹងកើតមានបញ្ហាផ្សេងៗណាស់ ដែលអាចបណ្តាលអោយខ្វាក់បាន។ សំខាន់បំផុតនោះ គឺត្រូវធ្វើយ៉ាងណាអោយជនរងគ្រោះអាចបើកបិទភ្នែករបស់គេបាន ដើម្បីការពារភ្នែកនោះមិនអោយឆ្លងមេរោគនឹងភាពស្ងួត។ គ្រូពេទ្យអាចធ្វើការវះកាត់ដើម្បីស្តារត្របកភ្នែកឡើងវិញ ប្រសិនបើត្របកភ្នែកត្រូវបានស៊ីបំផ្លាញដោយទឹកអាស៊ីត ឬក៏ចៀរយកសាច់ជ្រីវជ្រួញនៅតាមស្បែករង្វង់ភ្នែកចេញ នៅពេលដែលរបួសបានជាសះស្រួលបួលហើយ ។

ការទទួលទានអាហារគ្រប់គ្រាន់មានសារៈប្រយោជន៍ណាស់សំរាប់ជនរងគ្រោះ ដោយសារខ្លួនប្រាណគេត្រូវការថាមពលច្រើនដើម្បីប្រយុទ្ធទប់ទល់នឹងដំបៅរលួយក្លាយ និងដើម្បីព្យាបាលរបួសផង ។ ជនរងគ្រោះដោយការរលាកត្រូវការកាឡូរីអាហារយ៉ាងតិចណាស់ក៏ពីរដងច្រើនជាងជនធម្មតាដែរ ។ នេះវាអាចជាការលំបាកមួយដែរ ប្រសិនបើជនរងគ្រោះរលាកជុំវិញមាត់នឹងមានការពិបាកក្នុងការលេបអាហារ ឬក៏គ្មានប្រាក់គ្រប់គ្រាន់សំរាប់ទិញម្ហូបអាហារ ។ ពេលនោះជនរងគ្រោះអាចជាប់វិលវល់ក្នុងចរន្តនៃកង្វះជីវជាតិអាហារ ហើយដំបៅរលួយក្លាយនឹងអាចឈានទៅរកការអន្តរាយបន្ថែមទៀតដល់ស្បែក ។

ដំបៅរលួយនឹងអាចជាសះស្បើយក្នុងរយៈពេលពី ៣ ទៅ ១២ខែ ពោលគឺក្នុងរយៈពេលនេះស្បែកនិងកោសិកាអាចដុះឡើងមកវិញ ។ តែស្បែកសំលាកអាចនឹងដុះវិវឌ្ឍន៍ក្នុងរយៈពេលពី១-២ឆ្នាំ ។ ដោយវាដុះឡើងវិញជាស្បែកក្រមរក្រាស់ៗនឹងប្រទាញរញ៉េរញ៉ៃ ដែលបណ្តាលអោយមានពិការភាពជាអចិន្ត្រៃយ៍ដោយសារការជាប់គាំងពីការមិនកំរើកចលនា ដូចជាសំលាកស្បែកប្រទាញដងកទៅនឹងដងស្មាអាចធ្វើអោយជនរងគ្រោះមិនអាចងាកក្បាល ឬកំរើកដៃបានងាយស្រួល។ លោកវេជ្ជបណ្ឌិតត្រូវធ្វើការវះកាត់យកចេញនូវក្រមរស្បែក ដើម្បីបន្ធូរចលនាស្បែក និងវះកាត់ផ្សាំស្បែកលើមុខរបួសទាំងនោះអោយបានច្រើនលើកច្រើនសារ។ ស្បែកសំលាកពីការសះស្បើយនោះ ក៏នឹងអាចដុះគ្របរន្ធច្រមុះ និងរន្ធត្រចៀកផងដែរ ក្នុងស្ថានភាពបែបនេះគេត្រូវតែធ្វើការវះកាត់ជាចាំបាច់ ដើម្បីចៀរយកស្បែកដុះមិនប្រក្រតីទាំងនេះចេញ ។

ការព្យាបាលលើសរីរាង្គកាយដោយសល្យសាស្ត្រត្រូវធ្វើអោយបានញឹកញាប់ គឺជាការចាំបាច់ណាស់ដើម្បីកាត់បន្ថយភាពអសកម្មចលនាជនរងគ្រោះ ដែលបណ្តាលមកពីសំលាកក្រមរសះស្បើយពីមុខរបួសដោយឡែកការប្រើបង់រឹតឃឹតក៏អាចជួយកាត់បន្ថយរឹតបង្រួមក្រមរក្រាស់រឹងបានផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ការរៀបចំមធ្យោបាយព្យាបាល គឺមានការលំបាកច្រើននៅប្រទេសកម្ពុជា។ ប្រេងក្រមួនលាបស្បែកអាចជួយកាត់បន្ថយភាពរមាស់ពីការសះស្បើយមុខរបួសដែរ តែវាមានតំលៃថ្លៃសំរាប់ជនរងគ្រោះខ្លះ ។

ដំណាក់កាលចុងក្រោយនៃការព្យាបាលគឺការព្យាយាមស្តារភិនភាគផ្ទៃមុខ និងរូបរាងរបស់ជនរងគ្រោះឡើងវិញតាមលទ្ធភាពដែលគេអាចធ្វើទៅបាន ។ នៅក្នុងដំណាក់កាលនេះ ដំបៅអាចជាសះស្បើយទាំងស្រុង ហើយស្លាកស្នាម និងកំហូចទ្រង់ទ្រាយនៃខ្លួនប្រាណលេចចេញមកយ៉ាងច្បាស់ ។ ជនរងគ្រោះអាចនឹងត្រូវការការវះកាត់ច្រើនលើកច្រើនសារក្នុងរយៈពេលពីរ-បីឆ្នាំបន្តគ្នា។ ស្បែកដុះក្រាស់អាចនឹងត្រូវវះយកចេញ ឬស្នាមរបួសអាចនឹងគ្របដណ្តប់ដោយស្បែកល្អដែលគេយកចេញពីផ្នែកណាមួយនៃខ្លួនប្រាណជនរង

គ្រោះ ។ សល្យបណ្ឌិតត្រូវព្យាយាមកែកុនទ្រង់ទ្រាយបបូរមាត់ ត្របកភ្នែក ថ្ពាល់ និងផ្នែកផ្សេងៗទៀតនៃផ្ទៃមុខ ទោះបីជាជំនាញនេះនៅមានកំរិតទាបនៅក្នុងប្រទេសកម្ពុជាក៏ដោយ ។

ទោះបីជាក្រោយពេលដែលរបួសរបស់ជនរងគ្រោះបានជាសះស្បើយទាំងស្រុងហើយក៏ដោយ ជនរងគ្រោះនឹងអាចមានការឈឺចុកចាប់ និងការលំបាកក្នុងខ្លួននៅឡើយ ។ ភាគច្រើននៃជនរងគ្រោះតែងតែនិយាយថាស្លាកស្នាមដំបៅរបស់ពួកគេរមាស់នឹងឈឺផ្សា រីឯអ្នកខ្លះទៀតបាននិយាយថា ពួកគេមានការលំបាកក្នុងការដកដង្ហើម ឬមានបញ្ហាសុខភាពផ្សេងៗ ។ ជនរងគ្រោះម្នាក់បានពោលថា ***"នៅពេលដែលខ្ញុំឈឺផ្សាហើយស្នាមដំបៅរបស់ខ្ញុំរមាស់ និងមានការពិបាកក្នុងការដកដង្ហើម ពេលនោះហើយដែលខ្ញុំពិបាកទ្រាំណាស់ ។ ខ្ញុំមិនអាចនឹងរៀបរាប់ពីការឈឺចាប់ ភាពវេទនាដែលខ្ញុំកំពុងទទួលនោះបានឡើយ ហើយគ្មានអ្វីមួយអាចមកជួយរំលែកយកការឈឺចាប់ និងទុក្ខវេទនានេះចេញពីខ្ញុំបានទៀតផង ។"***

## ■ សេវាកម្មក្នុងមន្ទីរពេទ្យ

សេវាកម្មវេជ្ជសាស្ត្រក្នុងមន្ទីរពេទ្យសំរាប់ជនរងគ្រោះដោយរលាកទឹកអាស៊ីតនៅមានកំរិតទាបខ្លាំងណាស់ ។ នៅទីក្រុងភ្នំពេញ ជនរងគ្រោះភាគច្រើនទៅទទួលការព្យាបាលនៅមន្ទីរពេទ្យព្រះកុសមៈ ដែលមន្ទីរពេទ្យនេះបានព្យាបាលជនរងគ្រោះដោយការរលាកជាច្រើនឆ្នាំមកហើយ ដែលក្នុងពេលបច្ចុប្បន្ននេះមន្ទីរពេទ្យនេះបានបើកអង្គភាពជំនាញពិសេសព្យាបាលខាងដំបៅរលាក ឬការរលាក ។ អង្គភាពនេះទទួលព្យាបាលការរលាកសព្វសារពើ ហើយក៏ជាអង្គភាពជំនាញតែមួយគត់នៅក្នុងប្រទេសកម្ពុជានេះ ។ នៅក្នុងមន្ទីរពេទ្យនេះអង្គភាពនេះមានតែគ្រែពីរសំរាប់ទទួលអ្នកជំងឺ និងមានសល្យបណ្ឌិត ៣នាក់ គិលានុប្បដ្ឋាក ៣នាក់ ។ នៅក្រុងភ្នំពេញមានមន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យព្រះសីហនុ មជ្ឈមណ្ឌលនៃក្តីសង្ឃឹមជូនកាលទទួលព្យាបាលអ្នករងគ្រោះដោយរលាកទឹកអាស៊ីតផងដែរ ។ ឯនៅតាមខេត្តវិញអ្នករងគ្រោះបានស្វះស្វែងរកការព្យាបាលពីមន្ទីរពេទ្យខេត្ត ដែលមន្ទីរពេទ្យទាំងនេះមានប្រដាប់ឧបករណ៍តិចតួចសំរាប់ព្យាបាលរបួសប្រភេទនេះ ឬជួនកាលជនរងគ្រោះ ត្រូវបានគេបញ្ជូនមកកាន់ទីក្រុងភ្នំពេញ ប្រសិនបើជនរងគ្រោះមានសោហ៊ុយគ្រប់គ្រាន់ ឬជួនកាលទៀតគេគ្រាន់តែជួយចេញសោហ៊ុយដឹកជញ្ជូនជនរងគ្រោះមកមន្ទីរពេទ្យទីក្រុងភ្នំពេញ ។

ជនរងគ្រោះអាចនឹងសំរាកព្យាលបាលខ្លួនក្នុងមន្ទីរពេទ្យច្រើនសប្តាហ៍ ឬច្រើនខែអាស្រ័យទៅតាមសភាពនៃរបួសរបស់គេ ។ ក្រោយពីគ្រូពេទ្យអនុញ្ញាតអោយចេញពីមន្ទីរពេទ្យ ពួកគេអាចនឹងត្រឡប់មកមន្ទីរពេទ្យជាថ្មីម្តងទៀត ឬទៅជួបអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដើម្បីធ្វើការវះកាត់បន្ថែម ។ ជនរងគ្រោះខ្លះបានទទួលការធ្វើសល្យកម្មតាមដានពីមជ្ឈមណ្ឌលវះកាត់ **ROSE** (កូឡាប) នៅគៀនឃ្លាំង ពីអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ដូចជាអង្គការគ្រូពេទ្យពិភពលោក ដែលជួនកាលអង្គការនេះបានបញ្ជូនក្រុមសល្យបណ្ឌិតមកបំពេញបេសកកម្មរយៈពេលខ្លីនៅប្រទេសកម្ពុជា ។

ដោយសារតែកង្វះជំនាញ និងឧបករណ៍ មន្ទីរពេទ្យមិនអាចធ្វើអ្វីបានក្រៅតែពីផ្តល់ការព្យាបាលប្រឆាំងចំពោះការរីករាលដាលនៃដំបៅរលួយ ហើយនឹងជួយដល់ការផ្សះមុខរបួសរួមទាំងការធ្វើសល្យកម្មមូលដ្ឋានប៉ុណ្ណោះ។ សល្យកម្មទំនើប ដូចជាការវះកាត់ជួសជុលត្រចៀក និងច្រមុះឡើងវិញនៅមិនទាន់អាចធ្វើបាននៅឡើយ ។

ជាធម្មតា ជនរងគ្រោះត្រូវតែបង់ថ្លៃសេវាព្យាបាលវេជ្ជសាស្ត្រនៅតាមបណ្តាមន្ទីរពេទ្យរដ្ឋ ទោះជាមានមន្ទីរពេទ្យមួយចំនួនប្រហែលជាអាចនឹងមិនយកប្រាក់ពីជនក្រីក្រក៏ដោយ ។ រយៈពេលដែលជនរងគ្រោះអាចស្នាក់នៅក្នុងមន្ទីរពេទ្យ និងគុណភាពនៃសេវាកម្មវេជ្ជសាស្ត្រដែលជនរងគ្រោះអាចនឹងទទួលបានវាអាស្រ័យទាំងស្រុងទៅនឹងថវិកាដែលជនរងគ្រោះនោះមានសំរាប់ចំណាយ ។ ក្រុមវេជ្ជបណ្ឌិតដែលកំពុងបំរើការនៅតាមបណ្តាមន្ទីរពេទ្យរដ្ឋក្នុងទីក្រុងភ្នំពេញបានប្រាប់អោយដឹងថា ពួកខ្លួនបានផ្តល់ដំបូន្មានអោយក្រុមគ្រួសារជនរងគ្រោះរកទិញថ្នាំល្អនៅខាងក្រៅមន្ទីរពេទ្យ ប្រសិនបើក្រុមគ្រួសារជនរងគ្រោះនោះមានលុយកាក់ធូរធា។ ជនរងគ្រោះដែលមានលទ្ធភាពខាងផ្នែកថវិកា អាចនឹងធ្វើដំណើរទៅព្យាបាលខ្លួននៅគ្លីនិកឯកជន ឬទៅប្រទេសវៀតណាម ឬទៅប្រទេសផ្សេងៗដើម្បីព្យាបាលដោយខ្លួនគេ ។

ការចំណាយផ្នែកវេជ្ជសាស្ត្រមិនមែនចប់ត្រឹមជនរងគ្រោះចាកចេញពីមន្ទីរពេទ្យនោះទេ ។ ជនរងគ្រោះអាចនឹងត្រូវការបង់រុំរបួស ថ្នាំអង់ទីប៊ីយ៉ូទិក ឬឧសថផ្សេងៗទៀតសំរាប់ព្យាបាលខ្លួនគេនៅឯផ្ទះ ។ គេក៏ត្រូវចំណាយលើការធ្វើដំណើរ ជាពិសេសសោហ៊ុយធ្វើដំណើរសំរាប់ជនរងគ្រោះមកទទួលការតាមដានព្យាបាលវះកាត់នៅទីក្រុងភ្នំពេញ ។ ហើយជនរងគ្រោះដែលជាធម្មតាមិនមានលទ្ធភាពនឹងប្រកបការងារ ដើម្បីបានប្រាក់ចំណូលស្រាប់ហើយនោះ ក៏ត្រូវការទទួលទានអាហារ និងការចំណាយផ្សេងៗក្នុងជីវភាពប្រចាំថ្ងៃ ។ ជនរងគ្រោះរស់នៅក្នុងគ្រួសារក្រីក្រអាចនឹងត្រូវបង្ខំចិត្តលក់ម៉ូតូ ដីធ្លី ឬទ្រព្យសម្បត្តិផ្សេងៗទៀត ដើម្បីបង់ថ្លៃចាយវាយខាងលើទាំងអស់នេះ ដែលជាកត្តាមួយជំរុញពួកគេអោយឈានចូលទៅជ្រៅក្នុងភាពក្រីក្រ ។

ជនរងគ្រោះខ្លះមិនបានរួសរាន់ទៅមន្ទីរពេទ្យភ្លាមៗទេ ក្រោយពីខ្លួនរងការវាយប្រហារដោយទឹកអាស៊ីត គឺពួកគេបែរជាប្រឹងប្រែងធ្វើការព្យាបាលដោយខ្លួនឯងទៅវិញ ឬក៏ទៅរកឧសថការីក្នុងមូលដ្ឋានគាត់រស់នៅ ឬទៅរកគ្រូខ្មែរ ។ យោងតាមវេជ្ជបណ្ឌិតដែលបំរើការនៅមន្ទីរពេទ្យកាល់ម៉ែត្រ បានអោយដឹងថា យ៉ាងហោចណាស់មានជនរងគ្រោះដោយសារទឹកអាស៊ីត ១៦ នាក់ មកសំរាកព្យាបាលនៅមន្ទីរពេទ្យនេះ ហើយដែលពួកគេមិនបានប្រញាប់មកមន្ទីរពេទ្យភ្លាមនោះទេ ក្រោយពីគេរលាកទឹកអាស៊ីតភ្លាមៗនោះ ។ ជនរងគ្រោះទាំងនោះបានបង្អែបង្អង់អស់ពេលយ៉ាងតិចណាស់ក៏មួយខែ ហើយជួនកាលទៀតមានរយៈពេលដល់ទៅ ៦ខែមុននឹងពួកគេសំរេចថាត្រូវមកកាន់មន្ទីរពេទ្យកាល់ម៉ែត្រ ។ ជនរងគ្រោះទាំងឡាយណាដែលមិនបានមកព្យាបាលសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យត្រឹមត្រូវទេនោះ ច្រើនតែមានបញ្ហាសុខភាពធ្ងន់ធ្ងរមានស្លាកស្នាមច្រើននឹងបណ្តាលអោយខូចទ្រង់ទ្រាយរូបសម្បត្តិកាន់តែធ្ងន់ធ្ងរ ។

## ម្តាយរងគ្រោះដល់ស្លាប់ ឯកូនវិញត្រូវរងរបួសធ្ងន់ធ្ងរ

*រាត្រីថ្ងៃមួយក្នុងខែធ្នូ ឆ្នាំ ១៩៩៩ មានកុមារាពីរនាក់កំពុងតែនិទ្រាលង់លក់ជាម្តាយនៅក្នុងលំដ្ឋានផ្ទាល់ខ្លួនរបស់ពួកគេឯស្រុកព្រៃឈរខេត្តកំពង់ចាម ។ ក្នុងរាត្រីនោះ មានបុរសបីនាក់មកឈរនៅពីមុខផ្ទះស្រែកហៅម្តាយកុមារាទាំងពីរនាក់នោះអោយបើកទ្វារ ។ នាងជាម្តាយនោះក៏បានងើបអុចចង្កៀងហើយលូកដៃបើកទ្វារឡើង ស្រាប់តែរំពេចនោះមានទឹកអាស៊ីតជះមកលើមុខរបស់នាង ហើយទឹកអាស៊ីតជាច្រើនទៀតបានខ្ចាយទៅស្រោចលើកុមារាអាយុ ១២ឆ្នាំដែលត្រូវជាកូនរបស់ស្ត្រីរងគ្រោះ ដែលកុមារានេះបានងើបក្រោកឡើងនៅខណៈពេលដែលម្តាយរបស់វាបានបើកទ្វារនោះ ។ ឯកុមារាម្នាក់ទៀតដែលកំពុងលង់លក់ក្នុងដំណេកនោះបានទទួលរងរលាកទឹកអាស៊ីតតិចតួច ។*

*ជនដៃដល់បានរត់គេចខ្លួនបាត់ទៅ ក្នុងខណៈពេលដែលម្តាយនោះបានស្រែកភ្លាត់សំលេងឡើងនឹងបំរះនទៀលដោយការឈឺចុកចាប់ ។ បងប្រុសនាងដែលបានរស់នៅផ្ទះជិតខាងក្បែរនោះដែរបានស្ទុះមកជួយប្អូនស្រីរបស់ខ្លួន ។ នាងបានរងរបួសយ៉ាងធ្ងន់ធ្ងរលើមុខ និងដើមទ្រូង ហើយសក់របស់នាងវិញត្រូវបានឆេះខ្លោចដាច់អស់ ។ គ្រានោះខ្លួនប្រាណរបស់នាងបានចាប់ផ្តើមកន្ត្រាក់ប្រកាច់ ហើយនាងរមួលខ្លួនចុះឡើងដោយការឈឺចុកចាប់ពើតផ្សា ឯទឹកនោម និងលាមកបានចេញមកដោយនាងឥតដឹងខ្លួន ។ ពីរម៉ោងក្រោយពីការចុកចាប់មកនាងក៏បានស្លាប់នៅលើផ្ទះរបស់នាង នៅចំពោះមុខសាច់ញាតិរបស់នាងដែលមកចោមរោមចង់ជួយនាងនោះ ។*

*កូនប្រុសច្បង ទឹកអាស៊ីតបានឆេះរលាករោលរាលយ៉ាងធ្ងន់ធ្ងរលើផ្ទៃមុខ ដើម ទ្រូង និងខ្នង ឯកូនប្រុសប្អូនវិញបានរលាកអស់ក្បាលមួយចំហៀង ។ កុមារាទាំងពីរនាក់នោះត្រូវគេនាំយកមកកាន់មន្ទីរពេទ្យស្រុករួចមកកាន់មន្ទីរពេទ្យខេត្ត តែមន្ទីរពេទ្យខេត្តមិនអនុញ្ញាតអោយពួកគេចូលសំរាកព្យាបាលទេដោយសារកុមារាដែលមានអាយុ ១២ឆ្នាំ នោះមានរបួសធ្ងន់ធ្ងរពេក ។ កុមារាទាំងពីរនាក់នោះ ក៏ត្រូវបានគេបញ្ជូនបន្តមកកាន់មន្ទីរពេទ្យនៅក្រុងភ្នំពេញ ។*

*ស្ត្រីដៃដល់ឈ្មោះ វង់ នៀម មានអាយុ ៤៣ឆ្នាំជាអ្នកបានធ្វើការវាយប្រហារនេះជាមួយនឹងអ្នករួមដៃពីរនាក់ទៀត ។ វង់ នៀម បានលែងលះជាមួយប្តីនាងកាលពីប្រមាណ ៦ ខែមុននេះ ។ បីខែមុននៃការវាយប្រហារនេះកើតឡើង វង់ នៀម បានឃើញអតីតប្តីរបស់នាងឈរធ្វើការក្នុងស្រែជាមួយជនរងគ្រោះដែលនាំអោយនាងចាប់ចិត្តសង្ស័យ ថាអ្នកទាំងពីរមានសម្ព័ន្ធភាពអ្វីមួយជាមួយគ្នា ។ នាង នៀម បានព្រមានថា* ***" មីណាយកប្តីអញ ប្រយ័ត្នពោះវៀនហោះប៉ើងឡើងតាមខ្យល់វ៉ឺយ "*** *។*

*នាង វង់ នៀម ត្រូវតុលាការវិនិច្ឆ័យពីបទមនុស្សឃាតដោយប្រើប្រាស់ទឹកអាស៊ីតធ្វើជាអាវុធប្រហារដោយដាក់ទោសអោយជាប់ពន្ធនាគារ ១៨ឆ្នាំ ។ ជនរួមដៃម្នាក់ជាបុរសដែលមានឈ្មោះ សួន ពុត បានទទួលទោសជាប់គុកបីឆ្នាំ ឯជនរួមដៃម្នាក់ទៀតជាប្អូនប្រុសរបស់ សួន ពុត បានរត់គេចខ្លួនបាត់តែត្រូវតុលាការកាត់ទោសកំបាំងមុខអោយជាប់ពន្ធនាគារចំនួន ១៤ឆ្នាំ ។*

*កូនជនរងគ្រោះត្រូវពុះពារអោយខ្លួនបានជាសះស្បើយពីមុខរបួស ដើម្បីមកប្រឈមមុខនឹងក្លាយជាកុមារកំព្រាម្តាយអស់មួយជីវិត ។ កូនប្រុសប្អូន ឥឡូវនេះកំពុងរស់នៅជាមួយសាច់ញាតិឯខេត្តកំពង់ចាម*

*ឯកូនប្រុសបង ដែលទទួលរងរបួសយ៉ាងធ្ងន់ធ្ងរនោះវិញ កំពុងរស់នៅជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយ នៅទីក្រុងភ្នំពេញ ។ មុខមាត់ និងខ្លួនរបស់កុមារាបងនេះ មានការខូចទ្រង់ទ្រាយយ៉ាងធ្ងន់ធ្ងរនៅឡើយ មកទល់នឹងពេលនេះ ។ កុមារានេះបានទទួលការវះកាត់ដើម្បីបន្ថយស្លាកស្នាមដែលបានបន្សល់ទុកដោយការលោកអាស៊ីត ហើយកុមារនេះនៅត្រូវការការវះកាត់ច្រើនទៀតក្នុងពេលអនាគត ។ សុខភាពរបស់វាមានភាពមិនទៀងទាត់ វាតែងតែត្អូញត្អែរថា មានគ្រុនក្តៅ រងារ ក្អក និងរមាស់លើស្នាមដំបៅដែលសះស្បើយ ។*

# ៥. ផលវិបាកផ្សេងៗទៀតរបស់ជនរងគ្រោះដោយការលោកទឹកអាស៊ីត

ចូរលោក-អ្នកសាកទឹកស្រមៃបន្តិចលមើលថា បើលោក-អ្នកមានផ្ទៃមុខពោរពេញទៅដោយស្នាមដែលគួរអោយខ្លាច ។ តើលោក-អ្នកមានអារម្មណ៍យ៉ាងណាដែរ ? តើមនុស្សទូទៅនឹងសំដែងឥរិយាបទយ៉ាងណាខ្លះមកលើអ្នក ? ការវាយប្រហារដោយទឹកអាស៊ីតបានផ្លាស់ប្តូរជីវិតមនុស្សជារៀងរហូតដោយសារ អ្នករងគ្រោះត្រូវទទួលជាប្រចាំនូវទារុណ្ឌកម្មខាងផ្លូវចិត្តព្រមទាំងផលវិបាកខាងសេដ្ឋកិច្ច និងផ្នែកសង្គមរស់នៅ ។

## ▪ ផលវិបាកខាងផ្លូវចិត្ត

ការយកទឹកអាស៊ីតមកវាយប្រហារ វាមិនគ្រាន់តែបំផ្លាញស្បែក និងឆ្អឹងប៉ុណ្ណោះទេ តែវាបានបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ផ្លូវអារម្មណ៍ និងការគិតរបស់ជនរងគ្រោះទៀតផង ។ បញ្ហាវិបត្តិខាងផ្លូវចិត្តនេះ ជនរងគ្រោះបានទទួលចេញពីសេចក្តីភ័យខ្លាចសព្វបែបយ៉ាង ដែលកើតមានឡើងក្នុងអំឡុងពេលនៃការរងទឹកអាស៊ីតដោយហេតុថា ពេលនោះគេបានភ្លក់រសជាតិនៃការរលាយស្បែក ហើយមានរូបរាងដ៏អាក្រក់អាក្រីមួយដែលគេពុំធ្លាប់ជួបប្រទះហើយត្រូវរស់នៅជាមួយស្លាកស្នាមទាំងនេះអស់មួយជីវិត ។

## ▪ ជនរងគ្រោះបានរងទុក្ខវេទនាជាច្រើនបែបយ៉ាង

- **ព្រួយចិត្ត :** មានអារម្មណ៍ពិបាកចិត្ត និងអស់សង្ឃឹម ចេះតែគិតថាគេមិនអាចនឹងរស់នៅក្នុងជីវិតធម្មតាដូចគេឯងបានទេ ។
- **មានគំនិតគិតតែចង់សំលាប់ខ្លួន នឹកគិតព្រួយបារម្ភច្រើនហួសហេតុ។**
- **មានបញ្ហាដំណេក :** ដេកមិនលក់ ឬចេះតែយល់សប្តិអាក្រក់។

- **មានការភ័យខ្លាចៈ** ភ័យខ្លាចជនដៃដល់នោះត្រឡប់មកធ្វើបាបខ្លួនម្តងទៀត ភ័យខ្លាចក្នុងការដើរចេញទៅក្រៅបានជួបមនុស្សផងទាំងពួង ។
- **ឈឺក្បាល ទន់ខ្សោយអស់កំលាំងល្ហិតល្ហៃ ពិបាកក្នុងការប្រមូលអារម្មណ៍ និងភ្លេចភ្លាំងច្រើន** ។

វេជ្ជបណ្ឌិត និងគិលានុបដ្ឋាកនៅមន្ទីរពេទ្យខេត្តកំពង់ចាមនិយាយថា ជនរងគ្រោះដោយទឹកអាស៊ីតតែងតែទទូចថាពួកគេមិនចង់រស់នៅតទៅទៀតទេ ។ ពួកគេមានការពិបាកចិត្ត អៀនខ្មាស់ បារម្ភច្រើន និងមិនអាចតាំងស្មារតីបាន ។ ពួកគេមានការភ័យខ្លាចថាមនុស្សម្នាទាំងអស់នឹងលែងមានអ្នកណាម្នាក់យកចិត្តទុកដាក់ចំពោះពួកគេក្នុងពេលអនាគត លើសពីនេះទៅទៀតពួកគេមានអារម្មណ៍នៅឯកោកណ្តោចកណ្តែង ។

ជីដូនម្នាក់ដែលមានចៅត្រូវបានទទួលរងគ្រោះដោយសារទឹកអាស៊ីតបាននិយាយអោយដឹងថា ចៅស្រីរបស់គាត់ដែលត្រូវបានគេនាំយកមកកាន់មន្ទីរពេទ្យព្រះកុសមៈនៅទីក្រុងភ្នំពេញនោះ បានទទូចសុំអោយក្រុមគ្រួសាររបស់នាងប្រាប់អោយគ្រូពេទ្យចាក់ថ្នាំសំលាប់នាងចោលទៅ ។ ជីដូននោះបានប្រាប់ឱ្យដឹងទៀតថាចៅស្រីរបស់គាត់ឥឡូវនេះ បានត្រូវគ្រូពេទ្យបញ្ចេញពីមន្ទីរពេទ្យហើយ តែនាងនៅតែកើតទុក្ខក្រៀមក្រំមានភាពអាម៉ាស់ជាប់ខ្លួន មានការភ័យខ្លាចនឹងអនាគតរស់នៅរបស់នាង ហើយយំសោកឥតស្រាកស្រាន្ត ។

ជនរងគ្រោះទទួលវិបត្តិផ្លូវចិត្តយូរឆ្នាំ (ប្រសិនបើវិបត្តិនោះមិនស្ថិតស្ថេរមួយជីវិត) ដោយសារពួកគេចេះតែយល់សប្តិអាក្រក់នៅភ្នែកស្រស់រាល់ថ្ងៃ នូវសំលាកស្នាមជិតជាប់នឹងរូបរាងរបស់ពួកគេដែលជាមរតករបស់ទឹកអាស៊ីត ។ ពួកគេប្រហែលជាមិនអាចនឹងស៊ូទ្រាំមើលរូបរាងអាក្រក់របស់ខ្លួននៅក្នុងកញ្ចក់ទេ ឬ មិនហ៊ានអោយអ្នកដទៃសំលឹងមើលពួកគេឡើយ ។ ពួកគេអាចនឹងមានអារម្មណ៍អស់សង្ឃឹម អស់តម្លៃក្នុងឆាកជីវិត ហើយចេះតែគិតថាពួកគេគ្មានអ្វីដែលគួរអោយសោកស្តាយចង់រស់នៅនោះទៀតឡើយ ។ ជនរងគ្រោះម្នាក់ ដែលបានរួចជីវិតពីទឹកអាស៊ីតបាននិយាយថា ***" ខ្ញុំមានរូបរាងដូចខ្មោច ខ្ញុំស្អប់ខ្លួនខ្ញុំខ្លាំងណាស់ ។ ខ្ញុំមានព្រលឹងវិញ្ញាណជាខ្មោចស្រីក្នុងពេលបច្ចុប្បន្ននេះ "*** ។ រីឯស្ត្រីរងគ្រោះម្នាក់ទៀតបាននិយាយថា" ***ខ្លួនប្រាណខ្ញុំនៅមានជីវិតនៅឡើយ តែព្រលឹងវិញ្ញាណខ្ញុំបានស្លាប់ផុតបាត់ទៅហើយ "*** ។

## ■ ផលវិបាកខាងសង្គម និងសេដ្ឋកិច្ច

ជនរងគ្រោះត្រូវរស់ប្រឈមមុខនឹងការរើសអើងពីមនុស្សទូទៅអស់មួយជីវិត ។ ពួកគេអាចទៅជាមនុស្សឯកោ ពោរពេញទៅដោយភាពអាម៉ាស់ ដោយសារមនុស្សផងទាំងពួងអាចនឹងសំឡក់សំឡឹងលើរូបរាងពួកគេ ឬសើចចំអកនឹងរូបរាងទាំងនោះ ហើយស្តីបន្ទោសវាសនាអាក្រក់របស់ពួកគេ ឬជួនកាលទៀតគេនាំគ្នាគេចចេញមិនអោយជួបមុខសោះតែម្តង ។ មិត្តភ័ក្ត និងក្រុមគ្រួសាររបស់ពួកគេអាចនឹងបោះបង់ពួកគេចោល ។ ឯជនរងគ្រោះវិញអាចនឹងមិនចង់ចាកចេញពីក្នុងផ្ទះរបស់ពួកគេ ។ ហើយសូម្បីតែការងារកំប៉ិកកំប៉ុកដូចជាដើរទៅផ្សារ អាចជាការមួយដ៏អាម៉ាស់នឹងភ័យខ្លាចណាស់សំរាប់ពួកគេ ។ ចំពោះជនរងគ្រោះដែលនៅលីវវិញ ច្រើនតែនៅលីវយ៉ាងនេះរហូតអស់មួយជីវិតគ្មានថ្ងៃនឹងបានរៀបការដូចគេឯងឡើយ ។

ការរើសអើងពីសំណាក់មនុស្សទូទៅ ឬក៏ពិការភាព ដូចជាពិការភ្នែក បានបណ្តាលអោយជនរងគ្រោះមានការលំបាកក្នុងការស្វែងរកការងារធ្វើនឹងរកប្រាក់ចំណូល ។ ឧទាហរណ៏ ជនរងគ្រោះម្នាក់បានសង់តូបប្រកបមុខរបរលក់បាយតាមដងផ្លូវត្រូវបង្ខំចិត្តខ្លួនឯងបោះបង់ចោលមុខរបរនេះ ដោយសារ ***"មនុស្សម្នាមានការខ្លាចញញើតនឹងស្អប់ខ្ពើមរូបរាងខ្ញុំខ្លាំងណាស់ ពួកគេមិនហ៊ានចូលមកហូបអាហាររបស់ខ្ញុំលក់ទេ*** " ។ ហេតុដូច្នេះបានជាជនរងគ្រោះភាគច្រើន រស់នៅពឹងអាស្រ័យលើក្រុមគ្រួសាររបស់ពួកគេក្នុងការផ្គត់ផ្គង់ស្បៀងអាហារ និងថវិកាផ្សេងៗដែលនេះជាកត្តាមួយជំរុញអោយគ្រួសារជនរងគ្រោះកាន់តែមានស្ថានភាពក្រលំបាកជាលំដាប់ ហើយដែលនាំអោយគ្រួសារស្ថិតក្នុងស្ថានភាពតានតឹងទាំងខាងផ្លូវកាយ និងខាងផ្លូវចិត្ត ហើយអាចឈានទៅរកជំលោះក្នុងគ្រួសារទៀតផង ។ ហេតុនេះ គេអាចនិយាយបានថាទឹកអាស៊ីតមិនត្រឹមតែធ្វើអោយជនរងគ្រោះផ្ទាល់រងទុក្ខវេទនានោះទេ តែក្រុមគ្រួសាររបស់ជនរងគ្រោះក៏ត្រូវរស់រងនូវសេចក្តីទុក្ខវេទនាច្រើនបែបច្រើនយ៉ាង ។

ហេតុដូច្នេះ ទោះបីជាពួកគេជួបប្រទះការលំបាកច្រើនយ៉ាងណាក៏ដោយ រឿងសំខាន់ដែលគួរត្រូវចងចាំនោះគឺ អ្នករស់រានមានជីវិតដោយទឹកអាស៊ីតសុទ្ធតែអាចកសាងជីវិតពួកគេសារជាថ្មីបានទាំងអស់។ វាជាការងាយពេកហើយ ដែលមនុស្សមួយចំនួនមានទស្សនៈខុសឆ្គងថា អ្នករស់រានមានជីវិតដោយទឹកអាស៊ីតមិនអាចស្វែងរកអនាគតល្អសំរាប់ខ្លួនឯងបានឡើយ ។ ពួកគេអាចមានឱកាសស្វែងរកការងារធ្វើនឹងរស់នៅយ៉ាងរីករាយ-ប្រសិនបើមានការគាំទ្រ លើកទឹកចិត្តនឹងផ្តល់កាលៈទេសៈរៀនមុខជំនាញថ្មីៗជាច្រើន ដើម្បីអោយពួកគេអាចយកការចេះដឹងទាំងនោះទៅជួយទ្រទ្រង់ខ្លួនគេ។

## ពន្លឺនៃសេចក្តីសង្ឃឹមចំពោះអនាគតកាល

*កាលពីឆ្នាំ ១៩៩៣ ក្រោយពេលរូបគាត់ធ្លាក់ខ្លួនពិការភ្នែកទាំងសងខាងដោយសារការវាយប្រហារដោយទឹកអាស៊ីតលើផ្ទៃមុខគាត់ក្នុងហេតុការអំពើចោរកម្មមួយ ។ ប៊ុន ម៉ៅ ចង់តែសំលាប់ខ្លួន ដោយគាត់គិតថារូបគាត់គ្មានតំលៃអ្វីសំរាប់រស់នៅតទៅទៀតឡើយ។ ដប់ឆ្នាំបានកន្លងផុតទៅ ពេលនេះគាត់អាចប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ហើយទទួលបានសញ្ញាប័ត្រពីមហាវិទ្យាល័យទៀតផង។ ម្យ៉ាងវិញទៀត រូបគាត់បានក្លាយជានាយកគ្រប់គ្រងសមាគមមួយដែលទ្រទ្រង់ជួយដល់ជនពិការភ្នែក។*

*លោក ប៊ុន ម៉ៅ មានអាយុ ៣៣ឆ្នាំហើយមកទល់ពេលនេះ ក្រោមការតស៊ូរស់នៅដោយក្តីសង្ឃឹមក្នុងនាមជាអ្នករស់រានមានជីវិតនៅពីការវាយប្រហារដោយទឹកអាស៊ីត។ ថ្វីត្បិតបើ ត្រូវរស់ប្រឈមមុខជាមួយឧបស័គ្គច្រើនជំពូកក្តី តែគាត់អាចធ្វើអ្វីៗបានដោយជោគជ័យដូចមនុស្សដ៏ទៃទៀតផងដែរ។*

*លោក ប៊ុន ម៉ៅ ជានិសិត្សនៅមហាវិទ្យាល័យម្នាក់ក្នុងឆ្នាំ ១៩៩៣ នៅពេលដែលចោរប្លន់បានជះទឹកអាស៊ីតដាក់រូបគាត់ដើម្បីប្លន់យកម៉ូតូរបស់គាត់នៅក្នុងទីក្រុងភ្នំពេញ ។ ម៉ៅ ត្រូវបាននាំទៅកាន់មន្ទីរពេទ្យអ៊ិនតាក់ ហើយបានទទួលការព្យាបាលពីក្រុមគ្រូពេទ្យជនជាតិអាល្លឺម៉ង់។ ក្រុមគ្រូពេទ្យបានលួងលោមនឹងប្រាប់គាត់ថា ភ្នែកគាត់ទាំងពីរនឹងមិនអាចមើលឃើញតទៅទៀតទេ ។ គាត់តក់ស្លុតនឹងអស់សង្ឃឹមយ៉ាងខ្លាំង*

ពេលឮលោកគ្រូពេទ្យប្រាប់គាត់អំពីជំងឺដ៏អកុសលនេះ គាត់ប្រាប់លោកគ្រូពេទ្យអោយសំលាប់គាត់តែម្តងទៅ។ ប៉ុន្តែលោកគ្រូពេទ្យមិនអាចធ្វើតាមការទទួចសុំរបស់គាត់ឡើយ ។ គាត់គិតឃើញថាមានតែធ្វើអត្តឃាតដោយខ្លួនឯងប៉ុណ្ណោះទើបជាមធ្យោបាយ ។ " **ព្រោះខ្ញុំយល់ថា ខ្ញុំជាមនុស្សមិនអាចរស់នៅតទៅទៀតបានជីវិតខ្ញុំគ្មានដួងវិញ្ញាណជាប់នឹងខ្លួនសោះឡើយ ហើយជាមនុស្សមិនអាចពឹងអាស្រ័យខ្លួនឯងបានទៀតទេព្រោះខ្ញុំជាមនុស្សកំព្រាគ្មានឪពុកម្តាយដូចគេឯង ។ តើអោយខ្ញុំរស់នៅទៀតដោយវិធីណា ? ។"**

ប៉ុន្តែម៉ៅ បានជំនះរាល់ឧបស័គ្គដើម្បីការរស់នៅតទៅទៀត-បន្តិចម្តងៗគាត់បានចាត់ចែងផ្លូវជីវិតរស់នៅរបស់គាត់ជាសទ្បីមៗ។ គាត់បានគិតថា- តើត្រូវរៀនថែរក្សាខ្លួនឯងដោយរបៀបណា? ក្នុងនាមជាជនពិការភ្នែកម្នាក់ ដូចជាចំអិនអាហារ បោសសំអាត និងបំពេញការងារសព្វយ៉ាងឯទៀតដូចមនុស្សដ៏ទៃ ។ គាត់បានចូលសិក្សាអស់រយៈពេលបីឆ្នាំនៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មសំរាប់ជនពិការភ្នែក នៅវត្តសារាវ័ន្តតេជោ ដែលគ្រប់គ្រងឧបត្ថមថវិការដោយអង្គការមិនមែនរដ្ឋាភិបាលម៉ារីណុល ។ គាត់បានរៀនភាសាអង់គ្លេស អក្សរស្ទាបដោយដៃ ( ប្រឺល ជាក្បួនអក្សរស្ទាបដោយដៃសំរាប់តែមនុស្សពិការភ្នែករៀន ) រៀនជំនាញប្រើម៉ាស៊ីនអង្គុលីលេខ ព្រមទាំងមុខវិជ្ជាជីវៈដ៏ទៃទៀត ។ ចុងក្រោយបំផុត គាត់បានរៀនការធ្វើសរសៃដោយការប្រើបច្ចេកទេសស្ទាបដោយដៃ ព្រោះមុខវិជ្ជានេះអាចធ្វើអោយគាត់មានលទ្ធភាពរកចំណូលបាននាពេលអនាគត ។

មិនមែនគ្រាន់តែរៀនមុខវិជ្ជាជីវនោះវាគ្រប់គ្រាន់ទេ គាត់ត្រូវកំណត់អោយច្បាស់លាស់នឹងប្រកបដោយទំនុកទុកចិត្តលើជំនាញថ្មីៗទាំងនោះ ។ គាត់ត្រូវជំនះរាល់ការរើសអើងពីមនុស្សដ៏ទៃ ដែលតែងតែមាក់ងាយថា មនុស្សខ្វាក់ដូចរូបគាត់នេះគ្មានសមត្ថភាពធ្វើអ្វីបានទេ ។

**"នៅពេលខ្ញុំចាប់ផ្តើម មានមនុស្សខ្លះបានសើចចំអកអោយរូបខ្ញុំ- គេសួរថាហេតុអ្វីខ្ញុំចាំបាច់រៀនតទៅទៀត ? ។ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តឡើយ ។ ខ្ញុំបានពុះពារដើម្បីផ្លាស់ប្តូរឥរិយាបទពួកគេ ។ ជាសទ្បីមៗឥរិយាបទពួកគេពិតជាបានផ្លាស់ប្តូរ ។ "**

ឆ្នាំ ១៩៩៧ ម៉ៅ និងសិក្សាកាមទាំងអស់បានបង្កើតអោយមានមជ្ឈមណ្ឌលមួយដែលមាន ឈ្មោះថា **"ការចាប់សរសៃដោយដៃ"** នៅទីក្រុងភ្នំពេញ។ ដើម្បីផ្តល់សេវាកម្មខាងចាប់សរសៃ ជូនអតិថិជនជាជនបរទេស និងអតិថិជនខ្មែរ ។ ការប្រកបមុខរបរនេះមានភាពល្បួតលាស់ជាលំដាប់ ឯបុគ្គលិកដែលជាជនពិការភ្នែកក៏បានទទួលចំណូលខាងហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់ការរស់នៅរបស់ពួកគេផងដែរ ដោយពួកគេមិនបាច់ពឹងផ្អែកលើអ្នកដ៏ទៃទៀត។

សព្វថ្ងៃនេះមជ្ឈមណ្ឌល **"ការចាប់សរសៃដោយដៃ"** កើនឡើងចំនួនប្រាំពីរកន្លែង មានបុគ្គលិកចាប់សរសៃដោយដៃជាជនពិការភ្នែកចំនួន ៤០នាក់កំពុងបំរើការងាររាល់ថ្ងៃ ។ យ៉ាងហោចណាស់ពួកគេអាចទទួលកំរៃចាប់ពី ៥០ ទៅ ២០០ ដុល្លាក្នុងមួយខែ ដោយរួមទាំងមនុស្ស ១៣នាក់ផ្សេងទៀត។

នៅឆ្នាំ ១៩៩៩ ម៉ៅ បានទៅធ្វើកម្មសិក្សាផ្នែកជំនាញខាងកុំព្យូទ័រនៅប្រទេសថៃឡង់ដ៏ ( ការប្រើម៉ាស៊ីនដែលអាចដជែកឆ្លងឆ្លើយគ្នាសំរាប់ជនពិការភ្នែកប្រើប្រាស់បាន) នឹងជំនាញលើកិច្ចដឹកនាំ ។ ក្រោយពេលវិលមកប្រទេសកម្ពុជាវិញ ម៉ៅបានក្លាយជាជនពិការភ្នែកដំបូងគេដែលត្រូវបានអោយចូលរៀននៅមហាវិទ្យាល័យភ្នំពេញ ហើយពេលថ្មីៗនេះគាត់បានទទួលរង្វាន់បរិញ្ញាប័ត្រខាងភាសាអង់គ្លេស ។

*លោក ម៉ៅ ចង់ជួយអ្នកដទៃផ្សេងទៀត មិនមែនគ្រាន់តែរូបគាត់ម្នាក់ទេ ។ នៅឆ្នាំ ២០០០ គាត់បានរួមចំណែកបង្កើតសមាគមនៃជនពិការភ្នែកកម្ពុជា គឺជាអង្គការសំរាប់ជនពិការភ្នែកជួយទ្រទ្រង់ជនពិការភ្នែកដូចគ្នា ។ រូបគាត់ត្រូវបានជ្រើសរើសនិងតែងតាំងជានាយកគ្រប់គ្រងនៅទីនោះរហូតមក ។*

*លោក ម៉ៅ មានជំនឿយ៉ាងមុតមាំថា វាមានសារៈសំខាន់ណាស់ដែលអ្នករស់រានមានជីវិតពីការវាយប្រហារដោយអាស៊ីត និងជនពិការភ្នែកគ្រប់រូបត្រូវតែស៊ូ ប្រឹងប្រែងរៀនសូត្រមុខជំនាញថ្មីៗ ដើម្បីអាចរកកំរៃចិញ្ចឹមជីវិតបានដោយខ្លួនឯង ដោយមិនបាច់ពឹងអាស្រ័យលើអ្នកដទៃ ។*

***"ពិតជាមានការរើសអើងសំរាប់រូបយើងរាល់គ្នា តែវាអាស្រ័យដោយទង្វើរបស់ខ្លួនយើងផ្ទាល់ ថាតើយើងមានជំហររឹងប៉ឹងកំរិតណា ។ ប្រសិនបើយើងគ្មានជំហររឹងប៉ឹងដើម្បីបង្ហាញអោយគេឃើញថា យើងពិតជាមានសមត្ថភាពអាចធ្វើកិច្ចការទាំងនោះ ហើយនៅពេលគេបានឃើញពីសកម្មភាពកិច្ចការរបស់យើងនោះគេនឹងអាចមើលឃើញនូវភាពមិនពឹងផ្អែករបស់ពួកយើង ។ ហេតុនេះតើគេអាចរើសអើងចំពោះយើងដោយវិធីណា ? ។ គេត្រូវតែឈប់នូវសកម្មភាពរើសអើងចំពោះយើងតទៅទៀត ព្រោះយើងមានសមត្ថភាពបំពេញកិច្ចការដូចមនុស្សមានភ្នែកភ្លឺដែរ ។ យើងអាចរកកំរៃបានដោយខ្លួនឯង ដោយការប្រឹងប្រែងធ្វើការងារដោយកំលាំងពលកម្មរបស់យើង ព្រោះយើងមិនមែនជាសូមយាចក ឬ ចោរលួចឡើយ ។"***

*លោក ម៉ៅ ចូលរួមលើកទឹកចិត្តជនរងគ្រោះទាំងឡាយ សូមពុះពាររាល់ឧបស័គ្គ ដើម្បីភាពប្រសើរនៃជីវភាពរស់នៅនឹងសូមជំរុញអោយរដ្ឋាភិបាល មន្ត្រីប៉ូលីស និងមន្ត្រីតុលាការ មេត្តាបំពេញភារៈកិច្ចអោយបានខ្ជាប់ខ្ជួនចំពោះកិច្ចការពារទប់ស្កាត់ការប្រើប្រាស់អាស៊ីតនឹងផ្តន្ទាទោសជនដៃដល់ ដែលប្រើប្រាស់ទឹកអាស៊ីតជាអាវុធវាយប្រហារ ។*

***"ជាបឋម ខ្ញុំសូមអោយគេគិតដល់អំពីអាស៊ីតនឹងមនុស្សដែលកំពុងប្រើប្រាស់អាស៊ីតដើម្បីប្រកបអាជីវកម្មនានា ។ ប្រសិនបើ គេទាំងឡាយចង់ប្រើប្រាស់អាស៊ីតសំរាប់តែផលប្រយោជន៍ជំនួញរកស៊ី គេគួរតែមានលិខិតអនុញ្ញាតទិញដូរអាស៊ីតនេះ ។ ទីពីរ ប្រសិនបើជននោះប្រើប្រាស់អាស៊ីតដើម្បីបំណងគំរាមកំហែងអ្នកដទៃ ជននោះត្រូវតែប្រឈមមុខចំពោះផ្លូវច្បាប់យ៉ាងតឹងរឹងបំផុត គឺក្នុងន័យថា ជនដៃដល់នោះត្រូវតែនាំទៅកាន់តុលាការដើម្បីវិនិច្ឆ័យទោស ។"***

*ថ្វីត្បិតបើរូបគាត់ពិការភ្នែកទាំងសងខាង ហើយផ្ទៃមុខរបស់គាត់ពោរពេញដោយសំលាកស្លាមគួរអោយខ្លាចក៏ដោយ ។ រូបគាត់ក៏ធ្លាប់បានវះកាត់កែលំអទ្រង់ទ្រាយមុខ ច្រមុះ មាត់ និងផ្នែកផ្ទៃមុខដទៃទៀតដែលបំផ្លាញខូចដោយឥទ្ធិពលទឹកអាស៊ីតអស់ប្រាំពីរលើករួចមកហើយ- លោក ម៉ៅ បានដឹងពីវិធី និងហេតុផលជាច្រើន ថាតើត្រូវរស់នៅក្នុងជីវិតពិការភាពបានដោយរបៀបណា ។*

*សូមរំលឹកថា បន្ទាប់ពីគាត់រងគ្រោះដោយការវាយប្រហារដោយអាស៊ីតម៉ៅមានគំនិតចង់តែសំលាប់ខ្លួនឯងប៉ុណ្ណោះ ។ តែពេលនេះ ម៉ៅនិយាយទាំងញញឹមថា* ***"ខ្ញុំសប្បាយចិត្តណាស់ និងការរស់នៅតទៅទៀត ។ ខ្ញុំរីករាយណាស់ ដែលខ្ញុំបានជួយមនុស្សដទៃអោយមានការងារធ្វើ ។ ពេលនេះខ្ញុំមិនគ្រាន់តែញញឹមក្នុងចិត្តខ្ញុំទេ ប៉ុន្តែខ្ញុំបានធ្វើអោយមនុស្សដទៃទៀតញញឹមនៅលើផ្លូវសេចក្តីសង្ឃឹមយ៉ាងមុតមាំឆ្ពោះទៅរកអនាគតកាលដ៏ល្អមួយ ។"***

# ៦ ខាងផ្លូវច្បាប់

## ▪ តើត្រូវផ្តន្ទាទោសជនដៃដល់ដូចម្តេច?

ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាមិនបានបញ្ញត្តិអំពីអំពើហឹង្សាដោយទឹកអាស៊ីតនោះ ។ តែគេអាចចោទប្រកាន់ជនដៃដល់ពីបទបង្ករបួសស្នាម ដែលបទល្មើសនេះអាចអោយមានទោសជាប់ពន្ធនាគាររហូតដល់ដប់ឆ្នាំ ។ ហើយប្រសិនបើជនរងគ្រោះស្លាប់ ឬធ្លាក់ខ្លួនពិការអស់មួយជីវិត នោះគេអាចធ្វើការចោទប្រកាន់លើជនដៃដល់កាន់តែធ្ងន់ទៅទៀត ដោយចោទពីបទឃាតកម្ម ឬការប៉ុនប៉ងធ្វើឃាត ឬមនុស្សឃាត ដែលទោសនេះនឹងត្រូវជាប់ពន្ធនាគារពី ១០ឆ្នាំ ទៅអស់មួយជីវិត ។

## ▪ តើច្បាប់ត្រូវគេអនុវត្តន៍ដែរឬទេ?

ជាទូទៅប៉ូលីសច្រើនចាត់វិធានការតាមដានករណីជះទឹកអាស៊ីតដាក់គ្នានេះ បើយោងតាមសេចក្តីរាយការណ៍ពីកាសែត ។ ប៉ូលីសបានចាប់ឃាត់ខ្លួនយ៉ាងហោចណាស់មនុស្ស ១៣នាក់ ក្នុងបណ្តា ៤៤ករណីដែលបានរាយការណ៍នៅតាមកាសែតក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះ ។ នៅក្នុងករណីផ្សេងក្រៅពី ១៣ខាងលើ មានសេចក្តីរាយការណ៍ពីកាសែតមកថា ប៉ូលីសបានកំពុងស្វែងរកជនជាប់សង្ស័យដែលបានប្រព្រឹត្តបទល្មើសតែកាសែតមិនបានបញ្ជាក់ថាប៉ូលីសបានចាប់ឃាត់ខ្លួនដែរ ឬក៏យ៉ាងណានោះទេ ។

បញ្ហាកើតឡើងជាធម្មតាមួយ គឺជនដៃដល់ព្យាយាមបញ្ចុះបញ្ចូលជនរងគ្រោះអោយដកពាក្យបណ្តឹងចេញពីតុលាការ ដោយភាគីខាងជនដៃដល់សុខចិត្តបង់ប្រាក់ ឬសន្យាចេញថ្លៃព្យាបាលដល់ជនរងគ្រោះ ។ ចំពោះជនរងគ្រោះមានជីវភាពក្រីក្រត្រដាបត្រដួស ហើយត្រូវប្រឈមមុខនឹងការបង់ថ្លៃព្យាបាលខ្លួនដ៏ច្រើនលើសលុបផង រួមទាំងដឹងច្បាស់ថាខ្លួនមិនអាចនឹងរកប្រាក់ចំណូលអ្វីបានទេនាអនាគតនោះ ពួកគេគ្មានជំរើសណា ក្រៅតែអំពីការយល់ព្រមទទួលយកប្រាក់ពីជនដៃដល់នោះទេ ។ ជាអកុសលទៅទៀតនោះ មន្ត្រីប៉ូលីស និងមន្ត្រីតុលាការខ្លះសុខចិត្តទទួលយកដំណោះស្រាយនេះ ទោះបីជាទង្វើនេះវាបានបំពានតួនាទីរបស់ពួកគេតាមផ្លូវច្បាប់ក៏ដោយ ។

គេមិនបានដឹងច្បាស់លាស់ទេថា មានករណីវាយប្រហារទឹកអាស៊ីតប៉ុន្មានមកហើយទេ ដែលត្រូវបានតុលាការយកមកវិនិច្ឆ័យ ហើយមានជនដៃដល់ប៉ុន្មាននាក់ហើយដែលបានជាប់ទោសនោះ ។ អង្គការលីកាដូបានដឹងឮតែទៅលើការកាត់ទោសលើ ៦ ករណីប៉ុណ្ណោះ ហើយជាមួយគ្នានោះអាចមានកាត់ទោសផ្សេងៗទៀតដែលអង្គការលីកាដូមិនបានដឹងឮ ។ ក្នុងករណីមួយចំនួនតូច ដំណើរការកាត់ទោសកំពុងតែត្រូវបានធ្វើ តែមិនទាន់បានយកមកវិនិច្ឆ័យទោសនៅឡើយទេ ។

ករណីទាំង ៦ ដែលឈានទៅរកការកាត់ទោស ដែលជនដៃដល់ត្រូវបានផ្តន្ទាទោសរួមមានៈ

- ស្ត្រីម្នាក់ដែលបានជះទឹកអាស៊ីតទៅប្តីប្រមឹករបស់គាត់ដែលកំពុងវាយធ្វើបាបគាត់ ហើយដែលប្តីគាត់នេះតែងតែវាយធ្វើបាបគាត់ជាធម្មតា (ទឹកអាស៊ីតបានធ្វើអោយប្តីនោះខ្វាក់ភ្នែកម្ខាង) នាងត្រូវតុលាការវិនិច្ឆ័យទោសអោយជាប់គុក ៤ឆ្នាំ ។
- ស្ត្រីម្នាក់ដែលបានជះទឹកអាស៊ីតទៅលើប្តីរបស់គាត់ ដែលបានធ្វើអោយប្តីនោះខ្វាក់ភ្នែកទាំងសងខាង ។ ការជះទឹកអាស៊ីតនេះ ដោយសារបុរសជាប្តីបានលះលែងនាងចោល : នាងត្រូវបានផ្តន្ទាទោសអោយជាប់គុក ១៥ឆ្នាំ ។
- បុរសម្នាក់ដែលជះទឹកអាស៊ីតទៅលើប្រពន្ធរបស់គាត់ ដោយសារនាងបានចាកចោលគាត់ទៅរស់នៅជាមួយបុរសថ្មីម្នាក់ទៀត : គាត់ត្រូវតុលាការកាត់ទោសអោយជាប់ពន្ធនាគារចំនួន ៩ ខែ ។
- ស្ត្រីម្នាក់ដែលជះទឹកអាស៊ីតទៅលើប្រពន្ធចុងរបស់ប្តីខ្លួន ដោយបានបង្ករបួសដ៏ធ្ងន់ធ្ងរដល់ប្រពន្ធចុងនោះ : នាងត្រូវជាប់គុក ៦ឆ្នាំ ពីបទប៉ុនប៉ងធ្វើមនុស្សឃាត ។
- ស្ត្រីម្នាក់ដែលបានសម្លាប់ស្ត្រីម្នាក់ទៀតនឹងបង្ករបួសស្នាមដល់កូនប្រុសពីរនាក់របស់ជនរងគ្រោះដោយសារនាងសង្ស័យថាជនរងគ្រោះមានទំនាក់ទំនងស្នេហាជាមួយអតីតប្តីរបស់គាត់ៈ នាងជាប់គុក ១៨ឆ្នាំ (ជនរួមដៃពីរនាក់បានត្រូវវិនិច្ឆ័យទោសនឹងដាក់ទោស ទោះបីជាមានម្នាក់កំពុងរត់គេចខ្លួនក៏ដោយ) ។
- ស្ត្រីម្នាក់ដែលបានជះទឹកអាស៊ីតលើប្រពន្ធចុងរបស់ប្តីខ្លួន បានបំផ្លាញរូបរាងនាងប្រពន្ធចុងនោះយ៉ាងធ្ងន់ធ្ងរ ហើយព្រមទាំងចាប់ជីវិតទារករបស់ជនរងគ្រោះទៀតផង : ព្យួរទោស ២ឆ្នាំ (ពោលគឺជនដៃដល់មិនបានរស់នៅក្នុងគុក ១ថ្ងៃណាសោះឡើយ) ។

ករណីខាងលើទាំងអស់នេះ ស្តែងអោយឃើញនូវការដាក់ទោសរបស់តុលាការមានគំលាតប្រែប្រួលខុសប្លែកឆ្ងាយពីគ្នាខ្លាំងណាស់ ។ ឧទាហរណ៍ៈ ករណីបីដែលតុលាការខេត្តកំពង់ចាមយកមកវិនិច្ឆ័យតុលាការចេញសាលក្រមសំរេចដូចតទៅ : ជាប់គុក ៩ខែ ជាប់គុក ១៨ឆ្នាំនឹងព្យួរទោស ២ឆ្នាំ ។

មានការដាក់ទោសលើពីរករណី ដែលបង្ហាញអោយឃើញនូវភាពមិនស៊ីសង្វាក់គ្នាក្នុងការចេញសាលក្រមសំរេចដាក់ទោស ហើយដែលការមិនប្រស៊ីគ្នានេះប្រហែលជាចេញមកអំពីការរើសអើងចំពោះស្ត្រីភេទៈ ស្ត្រីជះទឹកអាស៊ីតដាក់ប្តីត្រូវបានកាត់អោយជាប់ពន្ធនាគារ ១៥ឆ្នាំ ឯបុរសជះទឹកអាស៊ីតដាក់ប្រពន្ធខ្លួនវិញ ត្រូវបានកាត់អោយជាប់គុកតែ ៩ខែប៉ុណ្ណោះ ។

នៅក្នុងខណៈពេលដែលជនដៃដល់ជះទឹកអាស៊ីតមួយចំនួនត្រូវបានតុលាការកាត់ទោស ហើយបានបញ្ជូនទៅពន្ធនាគារនោះ ជនដៃដល់មួយចំនួនផ្សេងទៀត ជាពិសេសអ្នកដែលមានលុយ និងអំណាចកំពុងរស់នៅដើរហើរក្រៅគុកយ៉ាងសប្បាយរីករាយ ។ ជាក់ស្តែងស្ត្រីម្នាក់ដែលបានជះទឹកអាស៊ីតលើប្រពន្ធចុងរបស់ប្តី

គាត់ហើយព្រមទាំងចាប់ជំរិតទារករបស់ប្រពន្ធចុងនោះទៀត ដែលក្នុងនេះជនរងគ្រោះទទួលរងរបួសស្នាមអស់មួយជីវិត ហើយឯកូនរបស់នាងវិញមិនដឹងជាគេយកវាទៅដល់ទីណាឡើយ ។ ជនដៃដល់ឈ្មោះ មិញ វីណាត ដែលជាប្រពន្ធនាយទាហានមានឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯក បានត្រូវកាត់ទោសដោយព្យួរទោសតែប៉ុណ្ណោះ ដែលសាលក្រមនោះត្រូវបានចេញដោយចៅក្រមតុលាការខេត្តកំពង់ចាម ។

ឧទាហរណ៍មួយទៀតនោះគឺ ការជះទឹកអាស៊ីតលើអ្នកចំរៀងការ៉ាអូខេ កញ្ញាតាត ម៉ារីណា នៅក្នុងឆ្នាំ ១៩៩៩ ត្រូវបានតុលាការក្រុងភ្នំពេញចេញដីការចាប់ខ្លួនជនដៃដល់ពីបទប៉ុនប៉ងធ្វើមនុស្សឃាត តែជនដៃដល់នោះជាប្រពន្ធរបស់មន្ត្រីរដ្ឋាភិបាលដ៏មានបណ្តាស័ក្តិខ្ពស់ ដូចនេះនាងមិនត្រូវបានគេចាប់ខ្លួនទាល់តែសោះ ។

ការដែលអ្នកមានអំណាចចូលមកជាប់ពាក់ព័ន្ធក្នុងរឿងវាយប្រហារទឹកអាស៊ីតនេះ គឺជាសារដំណឹងមួយបង្ហាញពីគ្រោះថ្នាក់ដល់សង្គមកម្ពុជាថាការជះទឹកអាស៊ីតគឺជាទង្វើមួយដែលសង្គមអាចទទួលយកបាន ។ សារដំណឹងនេះកាន់តែត្រូវបានពង្រឹងបន្ថែមទៀត ប្រសិនបើជនដៃដល់មិនត្រូវបានគេចាប់ខ្លួន ឬផ្តន្ទាទោសអោយបានត្រឹមត្រូវតាមផ្លូវច្បាប់ ។

## តើពួកគេមានយល់ពីការឈឺចាប់របស់ជនរងគ្រោះដែរឬទេ?

*បូផលមិនយល់សោះ ថាតើហេតុអ្វីបានជាមនុស្សអាក្រក់ដែលបានជះទឹកអាស៊ីតមកលើរូបនាង បំផ្លាញមុខមាត់ និងរាងកាយរបស់នាងអស់មួយជីវិតនោះ មិនដែលជាប់គុកបានមួយថ្ងៃណាទាល់តែសោះ ។ គ្មានអ្វីអាចយកមកប្តូរការឈឺចាប់របស់នាងបានឡើយ ហើយ បូផល ចង់អោយអាជ្ញាធរបានយល់អំពីបញ្ហានេះ។ តើមន្ត្រីតុលាការ និងអាជ្ញាធរមានគុណធម៌ មានចិត្តអាណិតអាសូរដល់មនុស្សដែរឬទេ ? តើពួកគេបានដឹងអំពីការឈឺចាប់របស់អ្នករងគ្រោះដែរឬទេ? នាងយំរៀបរាប់អំពីការឈឺចាប់របស់នាង ។ ខ្ញុំឈឺចាប់ខ្លាំងណាស់ មិនអាចយកពាក្យអ្វីមកនិយាយអោយសមស្មើនឹងទំហំនៃការឈឺចាប់នេះបានទេ ។ គ្មានអ្វីអាចយកមកប្រៀបផ្ទឹមនឹងការឈឺចាប់របស់អ្នករងគ្រោះដោយរលាកទឹកអាស៊ីតនោះទេ។ ច្រើនឆ្នាំមកហើយ ក្រោយពេលដែលនាងទទួលរងការជះទឹកអាស៊ីតមក អ្នកប្រព្រឹត្តអាក្រក់មកលើរូបនាងដែលជាជនអ្នកមានលុយកាក់ នោះនៅរស់ដោយសេរី ហើយធ្វើអ្វីបានតាមអំពើចិត្ត ។ ចំណែកឯបូផល ដែលជាជនក្រីក្រត្រូវរស់ក្នុងគំនរទុក្ខសោកវេទនា និងសេចក្តីភ័យខ្លាច ។ នាងដឹងថា នាងមិនអាចលុបបំបាត់ស្នាមដំបៅដែលនៅក្តៅរមាស់នឹងឈឺចាប់ចេញពីផ្ទៃមុខ និងរាងកាយរបស់នាងបានទេ ។ បូផល មិនសូវហ៊ានដើរចេញទៅក្រៅទេព្រោះបងប្អូនរបស់ជនល្មើសតែងតែគំរាមកំហែង នាងមិនអោយប្តឹងអំពីរឿងនេះទៅតុលាការ ។ នាងគ្មានបានទទួលកិច្ចការពារណាមួយពីតុលាការទេ រហូតមកដល់ពេលនេះមិនទាន់បានចាប់ជនល្មើសមកផ្តន្ទាទោសនៅឡើយនោះទេ ។ នាងបូផល យល់ឃើញថាក្រិត្យច្បាប់នឹងត្រូវបានពង្រឹង ហើយជនល្មើសនឹងត្រូវនាំមកកាត់ទោសដើម្បីបង្ហាញពីការទទួលស្គាល់នៃភាពឈឺចាប់ និងទុក្ខសោករបស់ជនរងគ្រោះ ដោយទឹកអាស៊ីតនោះ ។ នាងបូផលបានបន្ថែមថា ខ្ញុំសូមអំពាវនាវដល់មន្ត្រីតុលាការ មន្ត្រីរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចដ៏ទៃទៀតអោយយកចិត្តទុកដាក់ផ្តន្ទាទោសជនល្មើស ទោះបីជននោះជាអ្នកក្រ ឬអ្នកមាន អ្នកខ្លាំង ឬអ្នកខ្សោយ អ្នកមានអំណាច ឬប្រជាជនសាមញ្ញក៏ដោយ ។*

### ▪ គំនិតផ្ដើមច្បាប់ដ៏មានសារៈសំខាន់

សេចក្ដីព្រាងច្បាប់ស្ដីអំពីអំពើហិង្សាក្នុងគ្រួសារមានចែងពីការដាក់ទោសទណ្ឌ ដល់ជនល្មើសប្រើទឹកអាស៊ីតដោយតម្រូវអោយជាប់ពន្ធនាគារពី ៥ ដល់ ១០ឆ្នាំ ។ នេះជាលើកដំបូងហើយ ដែលច្បាប់កម្ពុជាចែងអំពីបទល្មើសទឹកអាស៊ីតហើយច្បាប់នេះនឹងជួយនាំយកជនល្មើស ដែលវាយប្រហារដោយទឹកអាស៊ីតមករកយុត្តិធម៌និងបានជាការលើទឹកចិត្តអោយមានបែបបទដូចគ្នាក្នុងការកាត់ទោសជនល្មើសក្នុងតុលាការ ។ សេចក្ដីព្រាងច្បាប់នេះនឹងត្រូវតែទទួលអនុម័តយល់ព្រមដោយសភាជាតិ និងព្រឹទ្ធសភាមុនចូលជាធរមាន ។

ដើម្បីអោយច្បាប់នេះមានភាពកាន់តែរឹងមាំ ពាក្យពេចន៍មួយចំនួននៅក្នុងមាត្រច្បាប់នេះត្រូវតែមានការផ្លាស់ប្ដូរនៅមុនពេលសភា និងព្រឹទ្ធសភាធ្វើការអនុម័ត។ សេចក្ដីព្រាងច្បាប់បានចែងតែពីសមាជិករបស់គ្រួសារដែលប្រើប្រាស់ទឹកអាស៊ីត ដើម្បីធ្វើបាបសមាជិកណាម្នាក់ទៀតនៅក្នុងគ្រួសារគេតែប៉ុណ្ណោះ ហើយមិនបាននិយាយយោងទៅដល់ជនល្មើសដែលបានជះទឹកអាស៊ីតលើជនរងគ្រោះ ដែលមិនមែនជាសមាជិកគ្រួសាររបស់គេទេ គឺថាដូចជាភរិយាដែលជះទឹកអាស៊ីតទៅលើប្រពន្ធចុងប្ដីរបស់គេជាដើម ។ ការផ្លាស់ប្ដូរពាក្យពេចន៍ត្រូវធ្វើឡើងដើម្បីអោយគ្របដណ្ដប់ ទៅលើជនណាក៏ដោយដែលបានចាក់ទឹកអាស៊ីតដោយមូលហេតុអ្វីមួយដែលទាក់ទីននឹងបញ្ហាក្នុងគ្រួសារក្ដី ឬការទំនាក់ទំនងផ្ទាល់ខ្លួនក្ដីដោយមិនគិតថា តើជនល្មើស និងជនរងគ្រោះស្ថិតក្នុងគ្រួសារតែមួយ ឬផ្សេយពីនេះក៏ដោយ ។ ជាមួយគ្នានេះផងដែរ ទណ្ឌកម្មត្រូវតែរិតបន្តឹងអោយខ្លាំងបំផុត ជាពិសេសក្នុងករណីដែលបណ្ដាលអោយមានពិការភាពអស់មួយជីវិត ដូចជាពិការភ្នែក ការបាត់បង់ច្រមុះ ត្រចៀកជាដើម ។ល។

មាត្រាច្បាប់ក្នុងសេចក្ដីព្រាងច្បាប់ស្ដីអំពីអំពើហិង្សាក្នុងគ្រួសារនេះ ជាគំនិតផ្ដើមដ៏មានសារៈសំខាន់ណាស់ក្នុងការប្រឆាំងការវាយប្រហារដោយទឹកអាស៊ីត ដែលត្រូវតែបានទទួលការគាំទ្រនឹងពង្រឹងអោយមានប្រសិទ្ធិភាពខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន ។ បន្ថែមទៅលើសេចក្ដីព្រាងច្បាប់នេះ ក្រមព្រហ្មទណ្ឌដែលបានស្នើឡើងថ្មីៗនេះត្រូវតែមានការដាក់ទោសទណ្ឌអោយបានធ្ងន់ធ្ងរដូចគ្នាចំពោះឧក្រិដ្ឋជនដែលប្រើទឹកអាស៊ីតសំរាប់មូលហេតុផ្សេងទៀត ដូចជាចោរកម្មជាដើម។

## ៧_បទពិសោធនៅប្រទេសបង់ក្លាដែស

ការវាយប្រហារដោយទឹកអាស៊ីតក៏មានកើតឡើង ក្នុងបណ្ដាប្រទេសអាស៊ីដ៏ទៃទៀតដែរ ដូចជាប្រទេសបង់ក្លាដេស ឥណ្ឌា ប៉ាគីស្ថាន ម៉ាឡេស៊ី នេប៉ាល់ វៀតណាម និងឡាវ ។ បញ្ហានេះក៏មានការកើតឡើងនៅបណ្ដាប្រទេសខ្លះ នៅអឺរ៉ុប អាហ្វ្រិក និងអាមេរិកផងដែរ ។

ប្រទេសមួយដែលមានបញ្ហាខ្លាំងជាងគេក្នុងចំណោមបណ្ដាប្រទេសដូចពោលមកនេះ គឺប្រទេសបង់ក្លាដេស ដែលមានអំពើហិង្សាដោយអាស៊ីតកើនឡើងគួរអោយភ័យខ្លាចនៅប៉ុន្មានឆ្នាំថ្មីៗនេះ ។ យ៉ាងហោចណាស់ក៏មានការវាយប្រហារដោយអាស៊ីតចំនួន ៤៧ ករណី នៅឆ្នាំ១៩៩៦ ចំនួន ១៣០ ករណី ក្នុងឆ្នាំ១៩៩៧ និងលើសពី ២០០ ករណីក្នុងឆ្នាំ ១៩៩៨ ។ យ៉ាងហោចណាស់មានការវាយប្រហារដោយទឹកអាស៊ីតចំនួន ២៥០ លើកក្នុងមួយឆ្នាំបានកើតឡើង ចាប់តាំងពីពេលនោះមកដែលមានន័យថាការវាយប្រហារដោយអាស៊ីតសរុបរួមមានចំនួន ៧៥០ លើកក្នុងចន្លោះរវាង ឆ្នាំ ១៩៩៩-២០០១។

ជាដំបូង ការវាយប្រហារដោយទឹកអាស៊ីតនៅទីនោះ គឺបានកើតឡើងចំពោះមនុស្សពេញក្រមុំ និងកុមារី ដែលប្រព្រឹត្តដោយបុរសដែលមានការប្រច័ណ្ឌ ឬខឹងសំបារដល់ជនរងគ្រោះដែលបដិសេធមិនព្រមតាមការលួងលោមរួមរក្ស និងសំណើសុំរៀបការរបស់ពួកបុរសទាំងនោះ ។ នៅពេលដែលអំពើហិង្សាដោយទឹកអាស៊ីតនេះមានការកើនឡើងនោះ បុរស និងស្ត្រីក៏បានទទួលរងនូវការវាយប្រហារនេះ ហើយជាមូលហេតុនៃការវាយប្រហារនេះ ក៏មានភាពប្លែកៗគ្នាជាច្រើនដែរ ។ បច្ចុប្បន្ននេះ ជាង ៣០ ភាគរយនៃអ្នករងគ្រោះគឺជាបុរស ហើយមូលហេតុចំបងនៃការវាយប្រហារដោយទឹកអាស៊ីតនោះគឺជម្លោះដីធ្លី ។ ការកើនឡើងនៃការវាយប្រហារនេះមានការកើនឡើង ដោយសារកត្តាផ្សេងៗជាច្រើនរួមទាំងការដែលខកខានមិនបានដាក់ទោសទណ្ឌដល់ជនល្មើសផងដែរ ។ ដោយសារការដែលជនល្មើសមិនត្រូវបានទទួលទណ្ឌកម្មនោះ អ្នកដទៃទៀតយល់ថា ពួកគេអាចប្រព្រឹត្តបទល្មើសនេះ ហើយនឹងពុំមានអ្វីកើតឡើងចំពោះពួកគេនោះ ។ ក្នុងចំណោមការវាយប្រហារដោយអាស៊ីតចំនួន ៧៥០លើកមាននៅចន្លោះឆ្នាំ ១៩៩៩ និង ២០០១ មានជនល្មើសតែ ២៥ នាក់ប៉ុណ្ណោះដែលទទួលការកាត់ទោស ។ នគរបាល និងមន្ត្រីតុលាការបង់ក្លាដេសមានអំពើពុករលួយ មានការហ៊ឹកហាត់តិចតួច និងអសមត្ថភាព ។ ជនល្មើសភាគច្រើនគឺជាអ្នកមាន និងជាអ្នកមានអំណាចធំ ដូច្នេះហើយគេបានសូកលុយអោយរដ្ឋអំណាចមិនអោយចាត់វិធានការណាមួយ ឬការគំរាមកំហែងនឹងបង់ប្រាក់ដល់ជនរងគ្រោះអោយដកពាក្យបណ្ដឹងចេញពីតុលាការ ។ ជនរងគ្រោះភាគច្រើនគឺជាអ្នកក្រីក្រ ហើយមិនសូវយល់ដឹងអំពីច្បាប់ទំលាប់ ហើយក៏មិនអាចមានប្រាក់កាសគ្រប់គ្រាន់ដើម្បីចាំអោយនគរបាល និងតុលាការធ្វើការស៊ើបអង្កេតបានទេ ។ បញ្ហានេះមានភាពធ្ងន់ធ្ងរណាស់រហូតបណ្ដាលអោយរដ្ឋាភិបាលបានបង្កើតតុលាការពិសេសមួយ ដើម្បីដាក់ទោសជនល្មើសប្រើការជះទឹកអាស៊ីតនេះ ។ មូលហេតុផ្សេងទៀតទាក់ទងនឹងការវាយប្រហារដោយអាស៊ីតនេះ គឺបណ្ដាលមកពីកត្តាសង្គមបង់ក្លាដេសដែលយល់ថាបុរសមានឧត្ដមភាពលើសស្ត្រីដែលការរើសអើង និងអំពើហិង្សាលើស្ត្រីគឺជាបញ្ហាធម្មតានោះ ។ បុរសបង់ក្លាដេសភាគច្រើនចាត់ទុកស្ត្រីថាជាទ្រព្យសម្បត្តិ ហើយមិនអាចស្មើភាពនឹងបុរសបានទេ ហើយមានបុរសមួយចំនួនបានប្រើអំពើហិង្សា រំលោភបំពានផ្លូវភេទ ប្រសិនបើស្ត្រីនោះបដិសេធមិនព្រមរួមភេទជាមួយគេ ឬប្រកែកមិនព្រមរៀបការជាមួយគេនោះ។ តែទោះជាយ៉ាងណាក៏ដោយ នៅពេលការវាយប្រហារដោយអាស៊ីតកាន់តែមានការកើនឡើងនោះ បុរសក៏ដូចជាស្ត្រីដែរបានក្លាយជនរងគ្រោះដូចគ្នា ។ មូលហេតុមួយទៀតនោះ គឺអាស៊ីតត្រូវបាននាំចូលដោយ

ងាយ ហើយមានតំលៃថោកទៀតផងនៅប្រទេសបង់ក្លាដេស។ ហេតុដូច្នេះ ទើបឥឡូវនេះរដ្ឋាភិបាលរៀបចំច្បាប់មួយ ដើម្បីត្រួតពិនិត្យលើការលក់ដូរអាស៊ីតយ៉ាងតឹងរឹងបំផុត ។

# ៨. អានុសាសន៍:

ត្រូវតែប្រយុទ្ធប្រឆាំងនឹងការវាយប្រហារដោយអាស៊ីតចាប់ពីពេលនេះទៅ ។ ការវាយប្រហារដោយអាស៊ីតគឺជាការបំផ្លាញយ៉ាងតំណំមកលើសង្គម និងវប្បធម៌កម្ពុជា ហើយអាចទុកជាគំរូដ៏អាក្រក់សំរាប់កូនខ្មែរជំនាន់ក្រោយៗទៀត។ ប្រសិនបើការវាយប្រហារដោយអាស៊ីតនេះមានការកើនឡើងកាន់តែច្រើនឡើងៗ នោះមនុស្សជាច្រើនឡើងនឹងមានកាយល់ថា ការវាយប្រហារបែបនេះ គឺជាវិធីមួយដែលមានការទទួលស្គាល់ថាជាអំពើត្រឹមត្រូវ ក្នុងការដោះស្រាយបញ្ហារបស់ពួកគេ ហើយសង្គមខ្មែរនៅតែទទួលការបំផ្លាញដោយអាស៊ីតជាបន្តទៅទៀត ។ មានគំនិតផ្តើមមួយចំនួនដែលគួរយកមកប្រើប្រាស់ជាបន្ទាន់សំរាប់ការពារនឹងដាក់ទោសជនល្មើសនឹងជួយដល់អ្នករងគ្រោះដែលរួមមាន:

***ច្បាប់ផ្តន្ទាទោសជនដៃដល់:*** *សភាជាតិ និងព្រឹទ្ធសភាគួរពង្រឹងនឹងអនុម័តលើវគ្គខ័ណ្ឌប្រឆាំងនឹងការវាយប្រហារដោយអាស៊ីតដែលមាននៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ។ ច្បាប់នេះគួរប្រើទៅលើការវាយប្រហារដោយអាស៊ីតទាំងអស់ ដោយសារបញ្ហាទំនាក់ទំនងផ្ទាល់ខ្លួន ឬបញ្ហាក្នុងគ្រួសារ ។ ទណ្ឌកម្មត្រូវតែរិតបន្តឹងអោយខ្លាំងបំផុត ជាពិសេសក្នុងករណីដែលបណ្តាលអោយមានពិការអស់មួយជីវិត ដូចជាការពិការភ្នែកជាដើម ។ ក្រមព្រហ្មទណ្ឌដែលបានស្នើឡើងថ្មីៗនេះត្រូវតែមានការដាក់ទោសទណ្ឌអោយបានធ្ងន់ដូចគ្នាចំពោះឧក្រិដ្ឋជន ដែលប្រើទឹកអាស៊ីតសំរាប់មូលហេតុផ្សេងទៀត ដូចជាចោរកម្មជាដើម។ នគរបាល តុលាការ និងសាធារណៈជនត្រូវតែទទួលបានការអប់រំអំពីច្បាប់នេះបន្ទាប់ពីសភាជាតិ និងព្រឹទ្ធសភាអនុម័តលើច្បាប់នេះ ។*

***ការអប់រំសាធារណៈ*** *សារធារណៈជន ត្រូវតែទទួលការអប់រំ ជាពិសេសតាមរយៈតាមបណ្តាញដែលមានប្រជាប្រិយភាព ដូចជា វិទ្យុ ទូរទស្សន៍ អំពីភាពឃោរឃៅ និងភាពខ្វះសីលធម៌នៃអ្នកវាយប្រហារដោយទឹកអាស៊ីត។ ការអប់រំត្រូវធ្វើការសង្កត់ទៅលើការដែលថាអ្នកប្រព្រឹត្តបទល្មើសនឹងត្រូវបញ្ជូនទៅកាន់ពន្ធនាគារ ។ ការអប់រំគួរផ្តោតផងដែរទៅលើការលើកស្ទួយអោយមានការអាណិតអាសូរ មិនមែនជាការស្តីបន្ទោសដល់ជនរងគ្រោះឡើយ ។*

**ជួយអោយជនរងគ្រោះអោយហ៊ាននិយាយ:** ជនរងគ្រោះដោយអាស៊ីតនឹងមិនត្រូវបានគេដាក់អោយនៅឯកោ និងត្រូវតែបានយកចិត្តទុកដាក់ ។ វាជាការសំខាន់ណាស់ដែលអោយជនរងគ្រោះបាននិយាយអំពីបញ្ហារបស់គេ បើមិនដូច្នោះទេ អាចជួយដល់ជនរងគ្រោះបានតិចតួចណាស់អោយចាកផុតពីការវាយប្រហារនោះ ។ គួរជួយជនរងគ្រោះអោយអាចបង្កើតជាក្រុមឡើង ដើម្បីនិយាយក្នុងនាមគេផ្ទាល់ចំពោះមុខរដ្ឋាភិបាល តុលាការ និងសាធារណៈជន ។

**ការផ្តន្ទាទោសដល់ការវាយប្រហារដោយអាស៊ីត:** មន្ត្រីជាន់ខ្ពស់ មន្ត្រីនគរបាល មន្ត្រីតុលាការ គ្រូពេទ្យ ព្រះសង្ឃ និងមន្ត្រីអង្គការមិនមែនរដ្ឋាភិបាល គួរធ្វើការផ្តន្ទាទោសដល់អ្នកវាយប្រហារដោយប្រើទឹកអាស៊ីតធ្វើជាអាវុធ ។

**សេវាកម្មសុខាភិបាល និងសេវាកម្មផ្សេងទៀតសំរាប់ជនរងគ្រោះ:** ជនរងគ្រោះត្រូវការជំនួយពិសេសដើម្បីជួសជុលឡើងវិញនូវជីវិតរបស់គេ ។ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលគួរជួយយ៉ាងខ្លាំងក្លាដល់ផ្នែកព្យាបាលការឆេះ-រលាកនៅឯមន្ទីរពេទ្យព្រះកុសមៈ ។ ផ្នែកព្យាបាលការឆេះ-រលាកនេះគួរត្រូវបានបង្កើតឡើងនៅតាមខេត្តក្រុង ។ ជនរងគ្រោះគួរត្រូវបានផ្តល់ការពិគ្រោះជម្ងឺ និងសេវាកម្មខាងចិត្តសាស្រ្ត និងគួរទទួលបានជំនួយគាំទ្រក្នុងការបង្កើតក្រុមដើម្បីទ្រទ្រង់គ្នាទៅវិញទៅមក ។

**ត្រួតពិនិត្យការលក់ទឹកអាស៊ីត:** ការលក់ដូរអាស៊ីតមានឥទ្ធិពលខ្លាំងៗ និងអាស៊ីតមិនទាន់លាយត្រូវតែមានការកំណត់ដោយច្បាប់ ។ ត្រូវមានការចុះឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញអាស៊ីតទាំងអស់ ។ នៅពេលមាន ការវាយប្រហារដោយអាស៊ីត មន្ត្រីនគរបាលត្រូវធ្វើការស្រាវជ្រាវ ថាតើអ្នកប្រព្រឹត្តយកអាស៊ីតចេញពីកន្លែងណា ។ អ្នកលក់នោះ ក៏ត្រូវតែទទួលទោសផងដែរ ប្រសិនបើគេរកឃើញថាបានរំលោភច្បាប់នោះ ។